# មិត្តសាលាបាលី

No 10-11-12 Miksalapali - R. W6-3-13-

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

ចេញរាល់ខែ

INDOCHINE FR... DÉPÔT LÉGAL



ឆ្នាំទី ៣ តុលា វិច្ឆិកា ធ្នូ លេខ ១០-១១-១២

Oct. Nov. Déc. 10 11 12

ព.ស. ២៤៩៥ — គ.ស. ១៩៥២

ទស្សនាវដ្ដីអនុមាស

ផ្សាយព្រះពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

# បណ្ណាធិការ ចាប - ពិន

ទីសំណាក់ការ បណ្ដោះអាសន្ន នៅវត្តលង្កា ក្រុងភ្នំពេញ

## បញ្ជីរឿង

រឿង ទំព័រ

### ផ្នែកព្រះពុទ្ធសាសនា


ពុទ្ធតម្រាស់ . . . . . . . . . . . . . . . . ចាប - ពិន . . . . . . . . . . . . ៣៦១

ពុទ្ធសាសនានៅប្រទេសជប៉ុន . . . . . . . . ហ៊យ—ប៊ុក . . . . . . . . . . . . ៣៦៣

បដិភាណរបស់ព្រះពុទ្ធ . . . . . . . . . . . . ស៊ិន - ហ៊ាន . . . . . . . . . . . ៣៧២

សុភាសិត ៥០ បទ . . . . . . . . . . . . . . ប៊ូ - ប៉ូ . . . . . . . . . . . . . . ៣៧៧


### ផ្នែកអក្សរសាស្ត្រ


សង្គាយនា . . . . . . . . . . . . . . . . . . ចាប - ពិន . . . . . . . . . . . . ៣៨៣

អក្សរសាស្ត្រខ្មែរ . . . . . . . . . . . . . . . ហ៊យ—ប៊ុក . . . . . . . . . . . . ៣៩៦

ខេមរវេយ្យាករណ៍ . . . . . . . . . . . . . . ព្រះមហា ពេជ្រ—ម៉ាន់ . . . . . . ៤១២

អក្សរអង្គុលីលេខ . . . . . . . . . . . . . . អៀង — ថ្លាង . . . . . . . . . . . ៤២១

ប្រហែលជាលោកអ្នកភ្លេចហើយឬ ? . . . . . . . . . . . . . . . . . . . . . . . ៤២៩

រឿងព្រេង . . . . . . . . . . . . . . . . . . តែ - ជុន . . . . . . . . . . . . . ៤៣១

ត្រីមួយត្រកស្អុយតែមួយស្អុយទាំងអស់ . . . . . . . . . . . . . . . . . . . . . ៤៥១

តួសេចក្ដីសុខ . . . . . . . . . . . . . . . . . ជេង - ជ្រឹវ . . . . . . . . . . . . . ៤៥៨

ថ្នាំមិនងងុយដេក . . . . . . . . . . . . . . . ហ៊យ - ល្អុត . . . . . . . . . . . . ៤៧២

បទភ្លេងក្លៀងដើមឆ្នាំ . . . . . . . . ,. . . . ជេង - ជ្រឹវ . . . . . . . . . . . . . ៤៧៦

បញ្ចតន្ត្រ: . . . . . . . . . . . . . . . . . . ភិក្ខុ ប៉ាង— ខាត់ . . . . . . . . . ៤៧៨

ពាក្យប្រដៅ

– មិនឲ្យធ្វើអំពើអាក្រក់គ្រប់យ៉ាង,

– ឲ្យបំពេញអំពើល្អ,

– ឲ្យជំរះសម្អាតចិត្តខ្លួន,

នេះជាពុទ្ធសាសនា ។

## ពុទ្ធតម្រាស់

## ព្រះអង្គត្រាស់ថា:

– អ្នកមិនស្គាល់តថាគត ហៅតថាគតថា "ព្រះគោតម" អ្នកស្គាល់តថាគតហៅតថាគតថា "ព្រះសម្មាសម្ពុទ្ធ" ។ តថាគតបាន ដល់ព្រះនិព្វានក្នុងជីវិតនេះហើយ សរីរកាយរបស់តថាគតក្នុងជីវិតនេះ ជាសរីរកាយរបស់ព្រះគោតម, វេលាធាតុទាំង ៤ របស់ព្រះគោតមបែក ធ្លាយចាកគ្នាអស់ទៅ មនុស្សទេពតាទាំងមិនឃើញព្រះគោតមទៀតទេ, តែព្រះសម្មាសម្ពុទ្ធ ដែលមាននៅក្នុងសរីរកាយរបស់ព្រះគោតមមិន សាបសូន្យឡើយ ព្រះសម្មាសម្ពុទ្ធគេឃើញប្រាកដនៅក្នុងព្រះសទ្ធម្ម គឺសេចក្តីពិតគ្រប់កាល ។

*
* *

- តថាគតបានសុខហើយ នាំយកសេចក្តីសុខនោះមកចែកដល់ពុទ្ធបរិស័ទ ព្រោះតថាគតកើតមកក្នុងលោក ដើម្បីជួយស្រោចស្រង់សត្វលោក ។

*
* *

—អ្នកដែលបានឃើញព្រះសទ្ធម្ម គឺឃើញសេចក្ដីពិតរបស់តថាគត, ឈ្មោះថាបានចួបប្រទះនឹងព្រះសម្មាសម្ពុទ្ធ ; អ្នកដែលបានឃើញព្រះសម្មាសម្ពុទ្ធ, ឈ្មោះថាបានឃើញសេចក្ដីពិត ។

* * *

— អ្នកមិនចំពាក់ចិត្តក្នុងសេចក្ដីអាក្រក់ តែងបានទៅកើតក្នុងកពខ្ពស់ៗ គ្រប់កាល, លុះដល់ទីបំផុតបានចូលទៅកាន់ព្រះនិព្វានដែលជាកំពូលនៃសេចក្ដីសុខបំផុត ។

* * *

— សេចក្ដីល្ងង់ខ្លៅ ជាហេតុឲ្យបុគ្គលប្រកបការសម្លាប់បូជាយញ្ញ ។ ការសម្លាប់ជីវិតគោសែនព្រេន ដើម្បីយកចិត្តព្រះម្ចាស់សួគ៌ជាការឥតប្រយោជន៍ ។ ការគោរពចំពោះសេចក្ដីពិត ល្អជាងការសម្លាប់សែនព្រេន ។ កំហុសប៉ុនឹងកែកំហុសចាស់ដូចម្ដេចបាន? ការសម្លាប់នឹងឲ្យលាងបាបដូចម្ដេចបាន? ។ ពាក្យដែលឃាត់មិនឲ្យសម្លាប់, ឲ្យជម្រះចិត្តឲ្យបរិសុទ្ធ; នេះជាសាសនាដ៏ពិតប្រាកដឥតប្រកែកបានគួរជ្រះថ្លា ។ ការមិនលោភ មិនក្រោធ មិនវង្វេង នឹងមិនគិតបំផ្លាញគេជាការបូជាយ៉ាងប្រសើរ ឈ្មោះថាបូជាចំពោះសេចក្ដីពិត ។

បាប-ពិន.

# ពុទ្ធសាសនានៅប្រទេសជប៉ុន

## លោក រ៉ាយ-ប៊ុក រៀបរៀង

(តពីសៀវភៅលេខ ៧–៨–៩ ឆ្នាំ ១៩៥២)

---

ដែលដកស្រង់ពីគម្ពីរលទ្ធិពុទ្ធសាសនាពេញលក្ខណៈ (En) ដែលមានពណ៌នាថា: ‘ ឯកភាពនិងអនេកភាពបានរួបរួមទៅជាភាពមួយ ឥតមានឧបសគ្គអ្វីមករាំងរាបានឡើយ ” ។

លទ្ធិនេះបណ្ឌិតហិណ្ឌូខាងពុទ្ធសាសនាបានសរសេរទុកមកគឺ:

ក) បណ្ឌិតអស្វឃោសៈ (ភាសាជប៉ុនថាមេ-មីយ៉ូ = Mé - myô) លោកបានតែងគម្ពីរមួយនាមថា: មហាយានស្រទ្ធោត្បាទ-សាស្ត្រ (Mahàyana - çraddhot - pâda Çâstra) ដែលជាសៀវភៅអាចញ៉ាំងពុទ្ធបរិស័ទឲ្យចូលក្នុងលទ្ធិមហាយាន ។

ខ) បណ្ឌិតនាគជុន (ភាសាជប៉ុនហៅថារីយូ-ជូ Ryû - ju) បានតែងសៀវភៅមួយនាមថាមហាចិន្តេយ្យសាស្ត្រ: (Mahàcintya-çastra) ដែលពណ៌នាអំពីទសពលញ្ញាណ (Dai fou - shi - gui - ron) ។

## ២ — គណៈតិន-ដៃ-ស៊្យូ (Ten - Dai - shû)

ក) បុព្វហេតុ,

ពាក្យថាតិនដៃ (ភាសាចិនថាទៀនតាយ) គឺគិរីមួយដែលគណៈនេះបានស្ថាបនានៅប្រទេសចិនជាដំបូង ។

អ្នកស្ថាបនិកគឺតាបសម្នាក់ ដែលបានបង្កើតនូវគណៈពុទ្ធសាសនា នេះគឺលោកបណ្ឌិត ធី-ចា-ដៃស៊ី (Thi-cha-Dai-shi) បានសាងអាស្រមនៅភ្នំតិនដៃ, (ចុងសន្តតិវង្សត្ចិន (៥៥៧-៥៨៤) ហើយនឹងសន្តតិវង្សបឋមនៃសួយ (Zoui ៥៨៥-៦១៦) ។

នៅ គ. ស. ៨០៣ មានព្រះរាជបញ្ជាព្រះអធិរាជជប៉ុន ទ្រង់ចាត់ឲ្យបណ្ឌិត សៃចឺយ៉ូ (Saï-thiô ទៅប្រទេសចិន បណ្ឌិតសៃចឺយ៉ូ (ដែនគុយ៉ូ-ដៃស៊ី) បានសិក្សារៀនសូត្រនូវលទ្ធិនេះពីបណ្ឌិតដូស៊ួយ (Do-Soui) នៅប្រទេសចិន ហើយលោកវិលត្រឡប់មកកាន់មាតុភូមិវិញ ព្រមទាំងនាំគម្ពីរព្រះពុទ្ធសាសនាចំពោះគណៈនេះមកផង ។ លោកបានស្ថាបនាអាស្រមបទនៅលើភ្នំ ហ៊ីអៃ ដែលពីមុនមកលោកបានសាងនូវព្រះវិហារឥនរិយាគូ (En-Riakou); បណ្ឌិតពុទ្ធសាសនាប្រទេសចិនបានហៅភ្នំហ៊ីអៃ ថា "ភ្នំតិនដៃប្រទេសជប៉ុន" ។ បណ្ឌិតសៃចឺយ៉ូ អនិច្ចកម្មនៅ គ. ស. ៨២៣, ក្នុងជន្មាយុ ៥៦ ឆ្នាំ ហើយព្រះអធិរាជជប៉ុន សៃវ៉ា (Seï-Wa) ទ្រង់ព្រះរាជទាននាមបច្ឆាមរណៈថា ដែនគុយ៉ូ-ដៃស៊ី (Den-guyô-Dai Shi) ប្រែថាមហាគរុខាងការផ្សាយនិកាយតិនដៃ ។ នៅក្នុងពេលនោះ មានបណ្ឌិតម្នាក់ទៀតនាម គុយ-ស៊ិន (Gui-Shin) លោកបានអញ្ជើញទៅជាមួយបណ្ឌិត សៃចឺយ៉ូ ឯប្រទេសចិន បានសិក្សារៀនសូត្រពីលោកគ្រូ ដូស៊ួយ នូវលទ្ធិនេះសព្វគ្រប់ ។ លុះមកដល់ប្រទេស

ជប៉ុន បណ្ឌិតគួយ-ស្ហិន ក៏បានផ្សាយលទ្ធិនេះគ្រប់និគមជនបទភូមិភាគ ជាមួយនឹងលោកគ្រូសៃឆឺយ៉ូ ៗ ដល់លោកអនិច្ចកម្មទៅ ព្រះអធិរាជជប៉ុនទ្រង់បានព្រះរាជទាននាមបច្ឆាមរណៈថា: "ស្ហូ-សែន ដៃ ស្ហី" (Shû-Zen-daî-shi) ៗ

បណ្ឌិតដែលនិយមលទ្ធិជាលំដាប់តមកពីលោកគ្រូសៃឆឺយ៉ូ គឺបណ្ឌិត អិន-ឆឺយ៉ូ (En thiô) នឹងលោកបណ្ឌិត អិន-និន (En nyn) ៗ នៅ គ.ស. ៨៣៨ បណ្ឌិត អិន-និន បានអញ្ជើញទៅប្រទេសចិន ស្ថិតនៅក្នុងរយៈវេលាដប់ឆ្នាំ បានសិក្សារៀនសូត្រទូវលទ្ធិនេះ ៗ នៅ គ.ស. ៨៥១ មានបណ្ឌិតម្នាក់ទៀតនាមឆី-ស្ហូ-ដៃ-ស្ហី (Thi-sbô-Dai-shi) បានអញ្ជើញទៅប្រទេសចិន ដោយមានព្រះរាជឱង្ការនៅព្រះបន្ទូលសូរសីហនាទនៃព្រះអធិរាជជប៉ុន; លោកបានទៅសិក្សារៀនសូត្រក្នុងសំណាក់លោកគ្រូ រិយ៉ូ-ស្ហូ (Ryo shô) ដែលជាអ្នកគ្រប់គ្រងលទ្ធិនេះទីប្រាំបួនរាប់ជាលំដាប់តមកពីមហាគរុតិនដៃ-ដៃ ស្ហី ៗ ដល់លោកវិលត្រឡប់មកកាន់ប្រទេសជប៉ុនវិញ លោកបានបង្ហាត់បង្រៀនបណ្ឌិត រិយ៉ូ-យូ (Ryo - yu) អំពីលទ្ធិតិនដៃ ៗ តាំងពីនោះពួកបណ្ឌិតទាំងប៉ុន្មាន ក៏បានទៅមកប្រទេសចិន ហើយលទ្ធិនេះក៏ផ្សាយទូទៅពាសពេញប្រទេសជប៉ុន ៗ

ការផ្សាយនូវលទ្ធិនេះខាងប្រទេសជប៉ុនមានដំណើរពីរផ្លូវ ផ្លូវទីមួយ គឺផ្លូវហៅថា (សាន-មន ហ៊ី-អៃ-សង់) (san-mon-hi-ei-zan') ដែលមានបណ្ឌិតសៃច៊ុយ៉ូ អន-ទិន ទីងអន-ទ្យ៉ូ (En tyo) ... ល.. ជាអ្នកទេសនាផ្សាយ ។ ផ្លូវទីពីរ គឺផ្លូវ (ជី-មនមី-អ៊ី-ដេរ៉ា) (Ji-mon-mi-i-déra) ដែលមានបណ្ឌិតជី-ស៊ូទីងរ៉ៃយ៉ូយជាអ្នកឃោសនាផ្សាយ ។

## ១) សមាសភាព

លទ្ធិគិនដែររួមរួមនៅក្នុងគម្ពីរបីគឺសទ្ធម្មបុណ្ឌរិកសូត្រ (ភាសាជប៉ុនថាហុក-កេ កៀយ៉ូ) saddharma-pundarika-sûtra (Hôk-ké-kyô) គឺគម្ពីរបទុមសោភនបញ្ញតិ (le Lotus de la bonne Loi) ១; គម្ពីរនិព្វាណសូត្រ (Nirvana sutra) ភាសាជប៉ុនថា: ណេហានគុយ្យូ (Né hanguyô) ១; គម្ពីរមហាប្រាជ្ញាបារមិតាសាស្ត្រ (Maha-prajnâ-paramita-çastra) ភាសាជប៉ុនថា ដៃ-ធី-ដូ-រង់ (Dai-thi-do-ron) ១ ជាបីគម្ពីរ ។

ការសិក្សានូវលទ្ធិនេះ មានបួនបែប (ភាសាជប៉ុនថាស៊ីគីយ៉ូ (Shi-kyo) ទីងប្រាំជាក់ (ភាសាជប៉ុនថាគូជី (Go ji) ។

## ការសិក្សាបួនបែបនោះគឺ

១ – លទ្ធិពុទ្ធសាសនាព្រះត្រៃបិដក (ភាសាជប៉ុនថា សាន-ស៊ុ-គីយ៉ូ (san-zô kyô) ដែលជាលទ្ធិហីនយាន;

២ – លទ្ធិខាងឥត្ថិការសង្ឃ (Communauté) ភាសាជប៉ុនថា ត្សឺ-គុយ្យូ (Tsou-guyô) ដែលគាបយកទៅប្រតិបត្តិការ តាមត្រៃយាន ទៅក្នុងលទ្ធិមហាយាន;

៣ – លទ្ធិសមាសភាព (Distintion) ភាសាជប៉ុនថា: បេតស៊ូគីយ៉ូ (Belsou-kyô) ដែលមានតែព្រះពោធិសត្វក្នុងលទ្ធិមហាយាន ប្រតិបត្តិតាម;

៤ – លទ្ធិសន្តិសុខ (Plénitude) ភាសាជប៉ុនថា (ឥនគុយ្យូ) ដែលសំដែងមិនមែនសត្វ, មិនមែនសាបសូន្យ ។

## ប្អាក់ ៥ តោះគឺ

១ – អវតំសកសូត្រ (ភាសាជប៉ុនថា): គម្ពីរកេគង់គុយ្យូ (kégon-guyô)

២ – អាគម (Agama) ភាសាជប៉ុនថា: (A-gon);

៣ – វៃពុល្យ: Vai-pulya សាភាជប៉ុនថា: (Hô-dô)

៤ – ប្រាជ្ញា-បារមិតា Prajna para mita ភាសាជប៉ុន (Han-nya),

៥ – សទ្ធម្ម បុណ្ឌរិក (Saddharma pundarika) ភាសាជប៉ុនថា: ហុក-កេ (Hok-ké);

៦ – និព្វាណ (Nirwâna) ភាសាជប៉ុនថា: ណេ-ហាន់ (Né-han) ។

ព្រះសូត្រអវតំសកៈពណ៌នាអំពីលទ្ធិពីរយ៉ាងគឺ: សមាសភាពនៃ ធម៌និងឈានចិត្ត ។

ព្រះសូត្រអាគម សំដែងលទ្ធិហិនយាន ។

ព្រះសូត្រប្រាជ្ញា-បារមិតា អធិប្បាយអំពីលទ្ធិបីយ៉ាងគឺព្រះសង្ឃ, សមាសភាពនៃធម៌និងឈានចិត្ត ។

ព្រះសូត្រវៃបុល្យៈនិងនិរ្វាណពោលសរុបទាំងព្រះសូត្របួនយ៉ាង គឺ អវតំសកសូត្រ, អាគមសូត្រ, ប្រាជ្ញាបារមិតាសូត្រ, វៃបុល្យៈសូត្រ ។

ព្រះសូត្រសទ្ធិមបុណ្ឌរិក ពិណ៌នាអំពីឈានចិត្ត ។

ព្រះពជបំណងនៃព្រះសាក្យមុនីក្នុងពិភពលោកនេះ គឺព្រះអង្គទ្រង់ទេសនាប្រដៅសព្វសត្វឲ្យប្រតិបត្តិតាមសទ្ធិមបុណ្ឌរិកសូត្រ ដែលជាធម៌ទីប្រាំសម្រាប់ចំឡងសត្វឲ្យដល់ត្រើយពោលគឺព្រះនិព្វាន ។

## គ) លទ្ធិ

លទ្ធិតិនដៃស្ហ៊ូមានសំដែងអំពីសច្ចធម៌បី (សាន-តៃ, San-Tai) ដែលធម៌ទាំងបីពាន់ចូលទៅរួមជាចិន្តាតែមួយ ។ ធម៌ជាកុសលនិងអកុសលមានបីពាន់ ហើយធម៌ទាំងនេះស្ថិតនៅក្នុងចិន្តានៃជីវសត្វ ។ សច្ចៈធម៌បីគឺ សូន្យ (គូ) ១ ជីវិត (គេ) និងជូ ១;

លទ្ធិនេះមានសំដែងអំពីភពដប់ គឺនរក ១ ប្រេត ១ តិយាគ៌-យោនិកតៈ: បុត្តិរច្ឆានភព (Tiryag-yonigata) ១, អាសុរ ១, មនុស្ស ១ ទេវៈ ១ ស្រាវកៈ ១ ប្រត្យេកពុទ្ធ (បច្ចេកពុទ្ធ pratyeka buddhas) ១, ពោធិសត្វ ១, ព្រះពុទ្ធ ១, រួមទាំងអស់ជាភពដប់ ។

ធម៌ទាំងបីពាន់រួមចូលក្នុងក្រមបីគឺ:

១ – ក្រមបញ្ចក្ខន្ធ ស្កន្ធ - Skan dhas (សង្ខារ) ភាសាជប៉ុន គូ-អ៊ុន-សេ-កេន (Go-oun-sé-kén);

២ – ក្រមជីវសត្វ បុគ្គល = (Pudgalas ភាសាជប៉ុនថា ស៊្ហូ-សូ សេ-កេន (Shu-jô-sé-kén)

៣ – ក្រមបថវី (កូ· Bhû) ភាសាជប៉ុនថា កុគុ-ដូ-សេ-កេន (Kokou-do-sé-kén) ។

ក្រមបញ្ចខន្ធនោះ (Cinq Agrégats) នោះគឺ: រូប (Forme) ១; វេទនា ១. (Sensation) ១, សញ្ញា, (Samjnà) (idée) សង្ខារ, (Sanskàras)= Concepts )១, វិញ្ញាណ (Vijnana) (Connaissance) ១ ។

ក្រមជីវសត្វ គឺសត្វដែលមានបញ្ចក្ខន្ធប្រាំ ។

ក្រមបថវី (Terre) គឺភពដែលសត្វអាស្រ័យកកំណើត ។

ធម៌ទាំងបីពាន់មានលក្ខណៈបីយ៉ាងគឺ:

ធម្មជាតិសាបសូន្យ (Vide - ភាសាជប៉ុនថា គូ Kou) ១ ធម្មជាតិមានជីវិត (Existence - ភាសាជប៉ុនថា កេ- Ké) ១ ធម្មជាតិកណ្ដាល (Terme Moyen - ភាសាជប៉ុនថា ធូ - Thû) ដែលហៅថាសច្ចធម៌នោះឯង ។

លក្ខិនេះមាន ៦ ថ្នាក់ៈ

ថ្នាក់ទី ១ គឺថ្នាក់វិចារណញ្ញាណ ( Raison ) ភាសាជប៉ុនថា ( Ri-so-kou ) រី-សូ-គូ — : ស្ថានភាពដែលសត្វលោកស្ថិតនៅក្នុងអវិជ្ជា មិនដឹង មិនយល់នូវសច្ចៈទាំងបី, ពិតមែនតែសច្ចធម៌នោះស្ថិតនៅក្នុងហាទយវត្ថុ របស់ខ្លួន ។

ថ្នាក់ទីពីរ គឺថ្នាក់ចាត់តាំង (Désignation) បើថាថ្នាក់និស្សិតប្រ-ហែលថាស្រួលស្តាប់ជាង គឺស្ថានភាពនៃមនុស្សដែលមានប្រាជ្ញាបន្តិចតមកយល់នូវសច្ចធម៌ទាំងបីដោយបានសិក្សារៀនសូត្រ តាមភាសាជប៉ុនថា មីយ៉ូ-ជី សូគូ (Myo-ji-sokou) ដោយគ្រូនិងមិត្ត, តែមិនទាន់បានពិចារណានៅឡើយ ។ បើតាមពិនិត្យប្រែហែលជាគន្ថធុរៈ ឬ ទ្រឹស្តីវិជ្ជា ។

ថ្នាក់ទីបី គឺថ្នាក់សមាធិចិត្ត ( Méditation ) ដែលព្រះយោគាវចរពិចារណានូវសច្ចធម៌ទាំងបីភាសាជប៉ុនថា គាំង-គ្យូ-សូគូ = Kwan-guyô sokou ) ។

ថ្នាក់ទីបួន គឺថ្នាក់ធ្វើតាម ( Imitation ) បើតាមពិនិត្យគួរថាថ្នាក់ឈានចិត្ត = ភាសាជប៉ុនថា សូ-នី-សូគូ (So-ny-sokou) គឺស្ថានភាពដែលមនុស្សអាចយកមនោសញ្ចេតនាទៅពិចារណាគ្រប់អារម្មណ៍ផ្សេង ៗ ឲ្យកើតឈានចិត្ត ។

ថ្នាក់ទី ៥ គឺសច្ចធម៌មធ្យម ភាសាជប៉ុនថា ប៊ិន ស្ហិន-សុគុ គឺស្ថានភាពដែលព្រះយោគាវចរចូលទៅក្នុងទឹកហូរ ពោលគឺព្រះនិព្វានតែមិនទាន់ដល់ ។

ថ្នាក់ទី ៦ គឺថ្នាក់អវសាន ភាសាជប៉ុនថា: គុ·គិយូ·សុគុ (Kou-kyô-sokou) ។

(មានត)

# បដិភាណរបស់ព្រះពុទ្ធ

(ប្រាជ្ញារបស់ព្រះពុទ្ធ)

ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងធម៌ ដើម្បីឲ្យអ្នកសួរបានចូលចិត្ត សេចក្ដីយ៉ាងច្បាស់លាស់ ។

គ្រានោះ(១) មោឡិយសិវកបរិព្វាជក (បរិព្វាជកឈ្មោះមោឡិយ-សិវកៈ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ នាដំបន់ដែលព្រះអង្គគង់នៅ (ជិតក្រុងសាវត្ថី) លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររឭកហើយ ក៏អង្គុយកន្លែងដ៏សមគួរ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គត្រាស់ថា ធម៌គឺពាក្យប្រដៅរបស់ព្រះអង្គ ឲ្យផលដែលបុគ្គលគប្បីឃើញដោយខ្លួនឯង (សន្ទិដ្ឋិកធម៌) គឺឲ្យផលឃើញច្បាស់ នឹងឲ្យផលមិនមានកំណត់កាល (អកាលិកធម៌) នឹងគួរហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន (ឯហិបស្សិកធម៌) នឹងគួរបង្អោនចូលមកដាក់ក្នុងចិត្តខ្លួនបាន (ឱបនយិកធម៌) នឹងជាធម៌ដែលវិញ្ញូជនទាំងឡាយគប្បីដឹងបានចំពោះខ្លួនឯង (បច្ចត្តំ វេទិតព្វោ វិញ្ញូហិ) ដូច្នេះ ធម៌ទាំងអម្បាលនេះមានសេចក្ដីអធិប្បាយយ៉ាងណា សូមទ្រង់សំដែងឲ្យខ្ញុំព្រះអង្គបានដឹងផង ។

---

១ សន្ទិដ្ឋិកសូត្រ ធម្មិកវគ្គ ឆក្កនិបាត អង្គុត្តរនិកាយ ។

ព្រះ - ម្នាលសីវក: បើដូច្នោះតថាគតនឹងសួរតបទៅអ្នកវិញ ក្នុង ហេតុនុ៎ះ អ្នកយល់ចិត្តយ៉ាងណា គប្បីដោះស្រាយយ៉ាងនោះចុះ ។ ម្នាលសីវក: ដូចជាលោភ: គឺសេចក្តីចង់បាន ដែលមានក្នុងសន្តាននៃ អ្នក ៗ ក៏រមែងដឹងច្បាស់ថា អាត្មាអញមានលោភ: អាត្មាអញមិនមាន លោភ: ដូច្នេះពិតដែរឬ?

ម.- ព្រះករុណា ព្រះអង្គពិតមែនហើយ ។

ព្រះ - ម្នាលសីវក: ការដែលអ្នកដឹងច្បាស់ថា លោភ:ដែល មាននឹងមិនមានក្នុងសន្តាន នោះឯង ជាធម៌ដែលហៅថា (សន្ទិដ្ឋិកោ) ឲ្យផលដែលបុគ្គលឃើញដោយខ្លួនឯង ដោយមិនត្រូវជឿអ្នកដទៃប្រាប់ នឹង (អកាលិកោ) ឲ្យផលមិនមានកំណត់កាល នឹង (ឯហិបស្សិកោ) គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន នឹង (ឱបនយិកោ) គួរបង្អោន ចូលមកដាក់ក្នុងចិត្តខ្លួនបាន នឹង (បច្ចត្តំ វេទិតព្វោ វិញ្ញូហិ) ដែល វិញ្ញូជនទាំងឡាយគប្បីដឹងបានចំពោះខ្លួនឯង ។

ព្រះ - ម្នាលសីវក: ទោស: គឺសេចក្តីក្រោធខឹងដែលមានក្នុង សន្តានរបស់អ្នក ៗ ក៏រមែងដឹងច្បាស់ថា អាត្មាអញមានទោស: អាត្មា អញមិនមានទោស: ដូច្នេះពិតដែរឬ?

ម - ព្រះករុណា ព្រះអង្គ ពិតមែនហើយ ។

ព្រះ - ម្នាលសារិកៈ ការដែលអ្នកដឹងច្បាស់ថា ទោសៈដែលមានទឹងមិនមានក្នុងសន្តាននោះឯង ជាធម៌ដែលហៅថា (សន្ទិដ្ឋិកោ) ឲ្យផលដែលបុគ្គលឃើញដោយខ្លួនឯង ដោយមិនត្រូវជឿអ្នកដទៃប្រាប់ ទឹង (អកាលិកោ) ឲ្យផលមិនមានកំណត់កាល ទឹង (ឯហិបស្សិកោ) គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន ទឹង (ឱបនយិកោ) គួរបង្អោនចូលមកដាក់ក្នុងចិត្តខ្លួនបាន ទឹង (បច្ចត្តំ វេទិតព្វោ វិញ្ញូហិ) ដែលវិញ្ញូជនតាំងឡាយគប្បីដឹងបានចំពោះខ្លួនឯង?

ព្រះ - ម្នាលសារិកៈ មោហៈគឺសេចក្តីវង្វេងល្ងង់ខ្លៅ ដែលមានក្នុងសន្តានរបស់អ្នក ៗ ក៏រមែងដឹងច្បាស់ថា អាត្មាអញមានមោហៈ អាត្មាអញមិនមានមោហៈ ដូចនេះពិតដែរឬ ។

ម - ព្រះករុណាព្រះអង្គ ពិតមែនហើយ ។

ព្រះ- ម្នាលសារិកៈ ការដែលដឹងច្បាស់ថា មោហៈ ដែលមានទឹងមិនមានក្នុងសន្តាននោះឯង ជាធម៌ដែលហៅថា (សន្ទិដ្ឋិកោ) ឲ្យផលដែលបុគ្គលឃើញដោយខ្លួនឯង ដោយមិនត្រូវជឿអ្នកដទៃប្រាប់ ទឹង (អកាលិកោ) ឲ្យផលមិនមានកំណត់កាល ទឹង (ឯហិបស្សិកោ) គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន ទឹង (ឱបនយិកោ) គួរបង្អោនចូលមកដាក់ក្នុងចិត្តខ្លួនបាន ទឹង (បច្ចត្តំ វេទិតព្វោ វិញ្ញូហិ) ដែលវិញ្ញូជនតាំងឡាយគប្បីដឹងបានចំពោះខ្លួនឯង ។

ព្រះ ម្នាលសិវកៈ លោភធម៌ គឺធម៌ដែលជាទីតាំងនៃលោភៈ ទោសធម៌ គឺធម៌ជាទីតាំងនៃទោសៈ មោហធម៌គឺធម៌ជាទីតាំងនៃមោហៈ ដែលមានក្នុងសន្តាននៃអ្នកៗ ក៏រមែងដឹងច្បាស់ថា អាត្មាអញមានលោភ-ធម៌ ទោសធម៌ មោហធម៌ ឬដឹងច្បាស់ថា អាត្មាអញមិនមានធម៌ទាំង ៣ នេះទេ ដូច្នេះពិតដែរឬ?

ម.— ព្រះករុណាព្រះអង្គ ពិតមែនហើយ ។

ព្រះ— ម្នាលសិវកៈ ការដែលដឹងច្បាស់ថា លោភធម៌ គឺធម៌ដែលជាទីតាំងនៃលោភៈ ទោសធម៌ គឺធម៌ជាទីតាំងនៃទោសៈ មោហធម៌ គឺធម៌ជាទីតាំងនៃមោហៈ ដែលមានឬមិនមានក្នុងសន្តាននោះឯង ជាធម៌ដែលហៅថា (សន្ទិដ្ឋិកោ) ឲ្យផលដល់បុគ្គលឃើញដោយខ្លួនឯង ដោយមិនត្រូវជឿអ្នកដទៃប្រាប់ នឹង (អកាលិកោ) ឲ្យផលមិនមានកំណត់កាល នឹង (ឯហិបស្សិកោ) គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន នឹង (ឱបន-យិកោ) គួរបង្អោនចូលមកដាក់ក្នុងចិត្តខ្លួនបាន នឹង (បច្ចត្តំ វេទិតព្វោ វិញ្ញូហិ) ដែលវិញ្ញូជនទាំងឡាយគប្បីដឹងបានចំពោះខ្លួនឯង ។

សរុបសេចក្តីតាមដែលមានមកក្នុងព្រះសូត្រនេះថា មោឡិយសិវក-បរិព្វាជក ក្រាបទូលសួរចំពោះសន្ទិដ្ឋិកធម៌ មានផលដែលបុគ្គលគប្បីឃើញដោយខ្លួនឯងជាដើម ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរអំពី លោភៈ ទោសៈ មោហៈ នឹងលោភធម៌ ទោសធម៌ មោហធម៌ ដែល

មានទីងមិនមានក្នុងសន្ដាន ចំពោះមោឡិយសិវកបរិញ្ញាជក ដោយទ្រង់ប្រាថ្នាឲ្យមោឡិយបរិញ្ញាជក យល់សេចក្ដីដោយខ្លួនឯង រួចហើយទ្រង់ត្រាស់ប្រាប់ថា ការដែលអ្នកយល់ឃើញនោះឯង គឺសន្ទិដ្ឋិកធម៌ឲ្យផលដែលបុគ្គលគប្បីឃើញដោយខ្លួនឯងជាដើមមែនពិត ។ សរុបសេចក្ដីថា ព្រះអង្គទ្រង់សំដែងអកុសលមូល ៣ យ៉ាងគឺ លោភៈ ទោសៈ មោហៈ ទីងទ្រង់សំដែងធម៌ដែលសម្បយុត្តដោយអកុសលមូល ៣ យ៉ាងគឺ លោភធម៌ ទោសធម៌ មោហធម៌ដូច្នេះ ។

ពាក្យដែលមោឡិយបរិញ្ញាជកទូលសួរ អំពីសន្ទិដ្ឋិកធម៌ គឺធម៌ដែលឲ្យផលឃើញច្បាស់ដល់អ្នកប្រតិបត្តិនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រឡប់សួរចំពោះមោឡិយសិវកបរិញ្ញាជក អំពីលោភៈ ទោសៈ មោហៈ ឲ្យគេដោះស្រាយតាមសេចក្ដីចូលចិត្តរបស់គេ នេះឯងជាគ្រឿងបញ្ជាក់បដិភាណរបស់ព្រះពុទ្ធ គឺប្រាជ្ញាឈ្លាសវៃរបស់ព្រះអង្គឲ្យឃើញជាក់ស្ដែង ។

ស៊ុន-ហ៊ាន

# សុភាសិត ៥០ បទ

ស្រង់ចាកច្បាប់ផ្សេងៗ មានធម្មបទ ខុទ្ទកនិកាយជាដើម

---

១ – សៅប្រៃរមែងរក្សាអំបិលទុកឲ្យមានជាតិប្រៃជានិច្ច ដូចម្ដេច, សេចក្ដីល្អក៏រក្សាមនុស្សអ្នកប្រព្រឹត្តឲ្យជាមនុស្សល្អជានិច្ចដូច្នោះដែរ ។

២ – ផ្កាកុលាបដែលមានព័ណ៌ល្អស្រស់ ទើងមានខ្លិនក្រអូបឈ្ងុយ ជាទីសម្រើបចិត្តនៃអ្នកបានឃើញបានហិតថើប ក៏រមែងមានបន្ទាជាអាវុធការពារខ្លួនដូចម្ដេច, ស្ត្រីដែលសោភាទើងរក្សាសេចក្ដីល្អរបស់ខ្លួនទុកបាន ក៏ត្រូវមានការប្រព្រឹត្តិល្អជាគ្រឿងការពារខ្លួនដូច្នោះដែរ ។

៣ – ធម្មតាមនុស្សល្ងង់ខ្លៅ ទើងឲ្យអ្នកចេះដឹងរាប់អានដូចម្ដេចបាន, ដូចជាដើមឈើធំខ្ពស់ ទើងមកនៅក្រោមម្លប់ដើមឈើតូចទាបដូចម្ដេចកើត ។

៤ – មនុស្សដែលនៅក្នុងពួកក្រុម បើធ្វើខ្លួនឲ្យដូចជាចកទើងទឹកបានជាការល្អ ព្រោះទឹកចិញ្ចឹមរក្សាចកឲ្យលូតលាស់ស្រស់ទៀតចកក៏បែកគុម្ពបញ្ចេញស្លឹកគ្របទឹក នាំឲ្យទឹកថ្លាស្អាតទើងត្រជាក់ត្រជុំ ។

៥ – សេចក្ដីខ្ជិលច្រអូស ជាមិត្តសំឡាញ់របស់មនុស្សទាល់ក្រ ។

៦ – របស់ណាដែលបានធ្វើរួចទៅហើយ របស់ទាំងអស់នោះ ទើងឲ្យត្រឡប់ប្រែប្រួលដូចកាលមិនទាន់ធ្វើ មិនបានឡើយ ។

៧ – ថ្នាំពិសរមែងមិនជ្រាបចូលទៅក្នុងបាតដៃរបស់អ្នកឥតដំបៅដូចម្តេច, សេចក្តីក្តៅក្រហាយចិត្តរមែងមិនមានដល់អ្នកដែលមិនបានធ្វើខុសដូច្នោះដែរ ។

៨ – អ្នកដែលជាបុត្រការីនឹងបុព្វការី គួរធ្វើខ្លួនឲ្យជាគំរូដ៏ល្អ គួរជាទីគោរពស្រឡាញ់រាប់អានរបស់អនុជន ។

៩ – អ្នកដែលមានគុណដល់ខ្លួន សូម្បីទាល់ក្រក៏គួរតែរាប់អាន គឺមិនត្រូវបំភ្លេចគុណនោះឡើយ ។

១០ – មនុស្សគួរបញ្ចេញតែវាចាដែលមិនធ្វើខ្លួនឲ្យក្តៅក្រហាយ ។

១១ – ការបញ្ចេញវាចាល្អ ញុំាងប្រយោជន៍ឲ្យសម្រេចគ្រប់កាល ។

១២ – ពាក្យពិត ជាវាចាដ៏មិនស្លាប់ ។

១៣ – មនុស្សគួរពោលតែវាចាដែលពីរោះ ព្រោះមិនធ្វើអណ្តាតឲ្យរលីសឹកអស់ទេ ។

១៤ – សំដីណាដែលធ្វើខ្លួននឹងអ្នកដទៃឲ្យក្តៅក្រហាយ សំដីនោះមិនគួរនិយាយទេ ។

១៥ – ការនិយាយកុហក បើទុកជាបានប្រយោជន៍ ក៏ស្មើនឹងការនិយាយមិនកុហកមិនបានដែរ ព្រោះមិនត្រូវក្តៅក្រហាយចិត្ត ។

១៦ – មនុស្សត្រូវដឹកលក់ភាជន៍ដ៏ពេញដោយប្រេងទុកបាន ដូចម្ដេច, គប្បីតាមរក្សាចិត្តរបស់ខ្លួនទុកដោយសតិ ដូច្នោះ ។

១៧ – មនុស្សអ្នកចូលចិត្តប្រព្រឹត្តតាមអំណាចរបស់ចិត្ត រមែងបានទទួលសេចក្ដីទុក្ខលំបាកជាដរាប ។

១៨ – គ្រឿងចក្រយន្តរមែងដឹកនាំយាននាវាឲ្យលឿនទៅដល់ទីប្រាថ្នាបានដូចម្ដេច, សេចក្ដីព្យាយាមធ្វើការជាប់មិនដាច់ រមែងញ៉ាំងបុគ្គលឲ្យដល់នូវសេចក្ដីសម្រេចបាន ដូច្នោះ ។

១៩ – មិនគួរទុកចិត្តសត្វដែលមានក្រចក មានស្នែង មានចង្កូម ជាការពុំទេ ព្រោះថាបើខុសទាស់ចិត្តវាៗ នឹងធ្វើឲ្យយើងវិនាស ។

២០ – មិនគួរទុកចិត្តសត្វកាចសាហាវ និងមនុស្សមានពុតត្បុតទេ ព្រោះថាបើខុសទាស់ចិត្តវាៗ នឹងសម្លាប់យើងឥតអាណិតឡើយ ។

២១ – មនុស្សដែលរស់នៅដោយសារតែទីពឹងអ្នកដទៃ ប្រៀបដូចជាវល្លិព័ទ្ធដើមឈើ កាលបើដើមឈើរលំ ក៏ត្រូវតែរលំទៅតាមគ្នា ។

២២ – សេចក្ដីក្ដៅក្រហាយចិត្តជាគ្រឿងសំគាល់របស់បាប ។

២៣ – អ្នកដទៃដាស់តឿន មិនស្មើនឹងការដាស់តឿនខ្លួនដោយខ្លួនឯងទេ ។

២៤ – ការតាំងចិត្តមានទៅក្នុងទីណា ផលដ៏គាប់ចិត្តក៏សម្រេចទៅក្នុងទីនោះផង ។

២៥ – មានកូនល្អ បានក៏ខ្ពង់ខ្ពស់មុខមាត់ ញាតិវង្សក៏ជ្រះថ្លា សម្បូរមិត្តសំឡាញ់ជិតឆ្ងាយ ក៏ពេញចិត្តសរសើរឱ្យពរ ។

២៦ – សេចក្ដីអត់ធន់ជាគ្រឿងប្រដាប់របស់អ្នកប្រាជ្ញ ។

២៧ – ទឹកមានប្រក្រតីថ្លាស្អាតដូចម្ដេច, មនុស្សគួរធ្វើចិត្តរបស់ខ្លួនឱ្យថ្លាស្អាតដូរផង់ដូច្នោះ ។

២៨ – សេចក្ដីមេត្តាករុណា និងស្រឡាញ់រាប់អានមិនមានអ្នកណាបង្ខំបញ្ជាទេ ប៉ុន្តែជារបស់ដែលកើតឡើងដោយធម្មជាតិនៃសេចក្ដីល្អ ។

២៩ – គេធ្វើអំពើឯណាហើយមិនតាមក្ដៅក្រហាយចិត្តក្នុងខាងក្រោយ អំពើនោះឯងគេធ្វើហើយល្អ ។

៣០ – សេចក្ដីក្រោធកាលគ្របសង្កត់នរជនក្នុងខណៈណា, ឯសេចក្ដីងងឹតងងល់ រមែងកើតមានឡើងក្នុងខណៈនោះ ។

៣១ – បណ្ឌិតរមែងមិនសំដែងអាការឡើងចុះ គឺមិនសំដែងសេចក្ដីសប្បាយចិត្តនិងសេចក្ដីតូចចិត្តឱ្យប្រាកដឡើយ ។

៣២ – មិត្តសំឡាញ់ កាលសេចក្ដីត្រូវការកើតមានឡើង រមែងនាំមកនូវសេចក្ដីសុខ ។

៣៣ – ព្រះរាជាជាប្រមុខរបស់ពួកមនុស្ស ដូចទឹកមហាសមុទ្រជាប្រមុខរបស់ស្ទឹងទន្លេទាំងឡាយ ។

៣៤- មនុស្សក្រោធខឹងច្រើន រមែងដេកកើតទុក្ខ ។

៣៥- បណ្ឌិតមានសេចក្ដីមិនសំឡឹងមើលទោសអ្នកដទៃជាកំឡាំង ។

៣៦- សេចក្ដីក្ដៅក្រហាយចិត្ត រមែងមិនមានដល់លោកដែលលះបង់នូវសេចក្ដីកង្វល់ទាំងពួងចេញបានហើយ ។

៣៧- អ្នកប្រាជ្ញត្រូវរក្សាពួកគណៈ ឬមួយសូម្បីនៅតែម្នាក់ឯង គឺគប្បីវៀរចាកទោសទាំងអស់ ។

៣៨- ក្នុងកាលណា ៗ ពៀរក្នុងលោកនេះរមែងមិនរម្ងាប់ព្រោះពៀរឡើយ ។

៣៩- សង្ខារគឺរបស់ដែលតាក់តែងកើតឡើងដ៏ទៀងទាត់ថិតថេរមិនមានឡើយ ។

៤០- បណ្ដាមនុស្សទាំងឡាយ ជនអ្នកទូន្មានខ្លួនល្អហើយ ជាអ្នកប្រសើរបំផុត ។

៤១- សេចក្ដីមិនបៀតបៀនគ្នា ជាសុខក្នុងលោក ។

៤២- អ្នកបរិភោគតែម្នាក់ឯងមិនបានសេចក្ដីសុខទេ ។

៤៣- ហិរិ គឺសេចក្ដីខ្មាសផលចិត្ត និងឱត្តប្បៈ គឺសេចក្ដីក្រែងខ្លាចខុស រមែងរក្សាលោកគឺពួកមនុស្សទុកបានល្អ ។

៤៤- បើជាមនុស្សល្ងង់ ក៏ត្រូវល្ងង់គួរឲ្យគេអាណិត, បើជាមនុស្សចេះ ក៏ត្រូវចេះគួរឲ្យគេគប់អាន, កុំល្ងង់ឲ្យគេខ្ពើម, កុំចេះឲ្យគេស្អប់ ។

៤៥ – បើជាមនុស្សទន់ ក៏ចូរជាអ្នកទន់ភ្លន់ កុំទន់ខ្សោយ, បើជាមនុស្សរឹង ក៏ចូរជាអ្នករឹងប៉ឹង កុំរឹងថ្មឹងប្រចេងប្រចាំង ។

៤៦ – ចូរធ្វើខ្លួនឲ្យអ្នកតូចរាប់អាន, ឲ្យអ្នកស្មើគ្នាខ្លាចចិត្ត, ឲ្យអ្នកធំអាណិតអាសូរ ។

៤៧ – មនុស្សដែលមានបុត្រមិនល្អ ដូចជាមានធ្មេញរង្គើ ទឹងដកចេញក៏ឈឺ ទឹងទុកនៅក៏រំខាន ។

៤៨ – បុរសគប្បីហាមឃាត់ចិត្តរបស់ខ្លួន ចាកសេចក្ដីអាក្រក់ ដូចជាហ្មដំរី អាចបង្ហាត់ដំរីចុះប្រេងឲ្យនៅក្នុងអំណាចបានដូច្នោះ ។

៤៩ – ការរៀនសូត្រចេះដឹងល្អ ធ្វើការងារល្អ ប្រព្រឹត្តល្អ ទាំង ៣ យ៉ាងនេះ រមែងធ្វើមនុស្សឲ្យដល់នូវសេចក្ដីសុខបរិបូណ៌ ។

៥០ – ពាក្យដែលជាសុភាសិត ទុកដូចជាកល្យាណមិត្តជាប់តាមចាំដាស់តឿនខ្លួនគ្រប់កាល ។

ប៊ូ-ប៉ូ

ធម្មតាវាចា ជាសុភាសិត
ប្រាជ្ញទុកជាមិត្ត ដ៏ល្អកល្យាណ ។
នៅអែបនែបនិត្យ ជាប់ជិតខ្លួនប្រាណ
ដាស់តឿនឲ្យបាន សុខសាន្តសព្វកាល ។

ប. ព.

# សង្គាយនាព្រះត្រៃបិដកប្រទេសកម្ពុជា

លោក ចាប–ពិន ថ្លែងដាក់វិទ្យុប្រទេសកម្ពុជាពីថ្ងៃទី ២-១-៥៣ ព.ស. ២៤៩៥

ផ្សាយចេញពីក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

អស់លោកអ្នកទាំងឡាយ !

ខ្ញុំបាទមានកិត្តិយសបានមកប្រស្រ័យ ជាមួយអស់លោកអ្នកទាំងឡាយ ដោយសំឡេងវិទ្យុប្រទេសកម្ពុជា ក្នុងនាមនៃពុទ្ធសាសនបណ្ឌិត្យ ដើម្បីរៀបរាប់ពីសង្គាយនាព្រះត្រៃបិដកប្រទេសកម្ពុជា ចែកជូនជាសណ្ដាប់ដល់អស់លោកទាំងឡាយ ឲ្យបានជ្រាបពីដំណើរការបោះពុម្ពព្រះត្រៃបិដកនៅប្រទេសយើង ដែលអស់លោកទាំងឡាយទន្ទឹងចាំមើលផ្លូវមកអស់កាលយូរហើយ ទុកជាប្រដាប់ការបេះដូងនៅជុំវិញខ្លួន ។

អស់លោកអ្នកទាំងឡាយបានជ្រាបហើយថា: ពុទ្ធសាសនបណ្ឌិត្យ ជាមន្ទីររក្សាគម្ពីរដីកាចំណេះវិជ្ជាផ្សេង ៗ ទាំងជាមន្ទីរបោះពុម្ពផ្សាយនូវវិជ្ជាទាំងឡាយ ទាំងផ្លូវលោកផ្លូវធម៌ជាប្រយោជន៍ដល់ប្រទេសជាតិ ។

ព្រះពុទ្ធសាសនានៅប្រទេសយើង បើតាមការជញ្ជឹងមើល ឃើញថាកើតទៅជាទំនៀមទម្លាប់ប្រទេស រលាយជាសាច់ជាឈាមប្រជាជនទាំងមូលទៅហើយ ឥតមានសាសនាណាមួយអាចចូលមករំលាស់ឬកកិះ កកាយគាស់រំលើងឲ្យចេញបានសោះឡើយ, ឯការដែលយើងយកពុទ្ធ-សាសនាមកជាប្រពៃណីប្រទេសនេះ ជាការប្រពៃហើយ ព្រោះយើង

បានពុទ្ធសាសនា ដែលជាសាសនាឯកឥតប្រកែកបានមកជាគោលការប្រតិបត្តិរបស់ប្រទេសជាតិ តែយើងត្រូវដឹងទៀតថា ព្រះពុទ្ធសាសនាដែលមកប្រតិស្ឋាននៅប្រទេសយើងនេះអស់កាលយូរយារហើយ, ធម្មតារបស់អ្វីមួយដែលចាស់យូរយារ តែងមានជុះជាប្រែះស្នឹមនាំឲ្យស្រអាប់ពណ៌ ឬឃ្លៀងឃ្លាតតក់សេចក្ដីដោយអន្លើៗ ជាដរាបមិនខាន ឯតួពុទ្ធសាសនាយើងក៏មានសភាពដូច្នោះដែរ អាស្រ័យដោយការមកប្រ-តិស្ឋាននៅប្រទេសយើងយូរយារពេក ដូច្នេះគប្បីយើងចំរៀបចំតម្រឹមតម្រូវឲ្យបានត្រឹមត្រូវតាមច្បាប់ដើមវិញ ដូចនាក់ទាំងឡាយដែលយើងប្រើយូរឆ្នាំហើយចាស់គ្រាំគ្រា ត្រូវតែយើងរៀបចំជួសជុលហើយលាបលនឲ្យបានល្អដូចដើមវិញ ទុកប្រើជាប្រយោជន៍តរៀងទៅ ។

អាស្រ័យហេតុដូចខ្ញុំបានពណ៌នាមកដោយសង្ខេបនេះ ទើបព្រះរាជរដ្ឋាភិបាលបានបង្កើតមន្ទីរពុទ្ធសាសនបណ្ឌិត្យនេះឡើង កាលពីថ្ងៃទី ២៥ មករា ឆ្នាំ ១៩៣០ ដោយមានគោលបំណងច្រើនប្រការ គឺ

១ – ដើម្បីស្រាវជ្រាវរកគម្ពីរដីកាក្បួនខ្នាតខ្មែរបុរាណមករក្សាទុកកុំឲ្យវិនាសបាត់បង់ទៅ;

២ – ដើម្បីរកគម្ពីរដីកាក្បួនខ្នាតបរទេស យកមកបំពេញសេចក្ដីត្រូវការយើងដែលខ្វះខាត;

៣ – ដើម្បីបោះពុម្ពផ្សាយនូវវិជ្ជាទាំងឡាយ ទោះផ្លូវលោកឬផ្លូវធម៌ ជាប្រយោជន៍ឲ្យប្រជាជនយើងមានការចេះដឹងទូលាយបរិបូណ៌ឡើង;

៤ – ដើម្បីរៀបចំលើកពុទ្ធសាសនាឲ្យបានរុងរឿងឡើង ដោយការពង្រីកការសិក្សាព្រះបរិយត្តិធម៌ គឺមានបង្កើតសាលាបាលីរងឲ្យបានផ្សាយទូលាយនៅគ្រប់ខេត្តក្នុងព្រះរាជអាណាចក្រ;

៥ – ដើម្បីបោះពុម្ពព្រះត្រៃបិដក ឲ្យកើតមានឡើងក្នុងប្រទេសយើង ។

ពុទ្ធសាសនបណ្ឌិត្យនេះ តាំងពីបង្កើតមក បានបោះពុម្ពផ្សាយគម្ពីរដីកាធម៌អាថ៌បំពេញសេចក្ដីត្រូវការប្រជាជនខ្មែរ ឆ្លួនល្មមដល់សេចក្ដីត្រូវការហើយ ខ្ញុំបាទជឿជាក់ថា តទៅអនាគតមិនយូរប៉ុន្មាន មន្ទីរនេះនឹងធ្វើការឲ្យបានសម្រេចលទ្ធផលគួរជាទីពេញចិត្តមិនខាន ។ កិច្ចការដ៏ប្រសើររបស់មន្ទីរនេះ ខ្ញុំបាទមិនបានពណ៌នាទាំងអស់ជូនជាសណ្ដាប់ក្នុងពេលនេះទេ ខ្ញុំបាទសូមលើកយកតែការផ្សារសង្គាយនាព្រះត្រៃបិដកខ្មែរយើងតែមួយមុខមកអធិប្បាយជូនដូចសេចក្ដីតទៅនេះ :

មុននឹងពណ៌នាពីសង្គាយនាព្រះត្រៃបិដករបស់យើង ខ្ញុំបាទយល់ថាគួរលើកយករបៀបសង្គាយនាទាំងឡាយពីបុរាណ តាំងពីបឋមរហូតមកដល់សង្គាយនាទី ៥ ដែលរាប់ជាសង្គាយនាធំៗ មកពិចារណាប្រៀបធៀបគ្នាមើលសិន ដើម្បីឲ្យឃើញតម្លៃសង្គាយនាព្រះត្រៃបិដកយើង ។

តាមប្រវត្តិពុទ្ធសាសនាដែលនិយាយទាក់ទងដោយសង្គាយនា មានសេច-
ក្តីដំណាលថា ក្រោយព្រះពុទ្ធអង្គបរិនិព្វានទៅមិនយូរប៉ុន្មាន ព្រះមហា-
កស្សបត្ថេរជាប្រធានសង្ឃ ប្រជុំព្រះអរហន្ត ៥០០ អង្គ ធ្វើបឋមសង្គា-
យនា អង្គលោកជាអ្នកចោទដណ្តឹងសួរព្រះត្រៃបិដកទាំង ៣ ព្រះឧបា-
លិត្ថេរ ជាអ្នកឆ្លើយវិនយបិដក, ព្រះអានន្ទត្ថេរជាអ្នកឆ្លើយសុត្តន្តបិដក
និងអភិធម្មបិដក ។ ក្នុងការប្រជុំការកសង្ឃ ជាសង្គីតិកាចារ្យនោះ មាន
គ្រែ ២ គ្រែមួយហៅថាថេរាសនៈ សម្រាប់ព្រះមហាកស្សបត្ថេរជាអ្នកសួរ
គ្រែមួយទៀតហៅថាធម្មាសនៈ សម្រាប់ព្រះថេរៈជាអ្នកឆ្លើយ, ព្រះអរ-
ហន្តទាំងអស់អង្គគង់ចាំស្តាប់នៅក្នុងទីប្រជុំទាំងអស់ ហើយមានការហាម
ឃាត់ភិក្ខុសង្ឃដទៃមិនឲ្យចូលទៅកាន់ទីប្រជុំនោះឡើយ ។ លុះចប់ព្រះ
វិនយបិដកហើយ ព្រះសង្ឃមូលមតិព្រមគ្នាសូត្រស្វាធ្យាយបញ្ចុះត្រូវ
គ្នាទាំងអស់អង្គ ។ កាលព្រះឧបាលិត្ថេរចុះចេញពីគ្រែ, ព្រះមហា-
អានន្ទត្ថេរឡើងកាន់គ្រែនោះហើយឆ្លើយសុត្តន្តបិដក, លុះចប់សុត្តន្តបិដក
ព្រះសង្ឃស្វាធ្យាយបញ្ចុះគ្នាទៀត ឈ្មោះថាចប់បឋមសង្គាយនាព្រះពុទ្ធ-
វចនៈ គឺព្រះត្រៃបិដកតែប៉ុណ្ណោះ ។ បើយើងពិចារណាតាមសង្គាយនានេះ
យើងឃើញថា កាលនោះព្រះអរហន្តលោកចងក្រងព្រះពុទ្ធវចនៈដោយ
ព្រះឱស្ឋ មិនបានចារិកព្រះពុទ្ធវចនៈជាលាយលក្ខណ៍អក្សរទេ គឺលោក
គ្រាន់តែទន្ទេញឲ្យចាំមាត់ពល់អង្គ បានសេចក្តីថាកាលនោះព្រះត្រៃបិដក

មិនទាន់ចារឹកដាក់ស្លឹករឹតឬសៀវភៅទេ សង្គាយនាទី ២ ទី ៣ ទី ៤ ក៏មានទំនងដូចគ្នានឹងបឋមសង្គាយនានេះដែរមិនប្លែកគ្នាទេ មានប្លែកខ្លះតែហេតុនាំឲ្យកើតសង្គាយនាប៉ុណ្ណោះ ព្រោះគោលបំណងត្រឹមតែឲ្យព្រះសង្គីតិ-កាចារ្យចងចាំពុទ្ធវចនៈ រត់មាត់ស្ទាត់ដូចគ្នាទាំងអស់អង្គប៉ុណ្ណោះ ៗ ដល់មកបញ្ចមសង្គាយនា គឺសង្គាយនាទី ៥ ទើបមានការប្លែកពីកាលមុនៗ គឺការប្រជុំការកសង្ឃជាសង្គីតិកាចារ្យមកសង្គាយនាហើយ ចារឹកព្រះពុទ្ធវចនៈគ្រប់បិដកទាំង ៣ ចុះកាន់ស្លឹករឹត ៗ ហេតុដែលនាំឲ្យចារឹកលាយលក្ខណ៍អក្សរដូច្នេះ មកពីអស់លោកដែលចេះចាំព្រះពុទ្ធវចនៈរត់មាត់ស្ទាត់នោះកាន់តែក្រខ្សត់ទៅមិនសូវមានច្រើនទេ ៗ ហេតុនេះជាដើមហើយក៏លើកការចារឹកព្រះពុទ្ធវចនៈជាលាយលក្ខណ៍អក្សរឡើង បានជាព្រះពុទ្ធវចនៈឋិតថេរហូតមកដល់បច្ចុប្បន្នកាលនេះ ៗ គំនិតរបស់លោកទាំងឡាយនោះដែលចារឹកព្រះពុទ្ធវចនៈទុកជាការសំខាន់បំផុត បើប្រសិនជាមិនចារឹកទុកទេ គ្រាន់តែធ្វើសង្គាយនាហើយទន្ទេញឲ្យចាំមាត់ ដូចសង្គាយនាកាលមុនៗ មក ព្រះពុទ្ធសាសនានឹងអន្តរធានបាត់បង់ទៅហើយ ៗ បើយើងយកសង្គាយនាទាំង ៥ លើកនោះមកពិចារណាមើលតទៅទៀតយើងនឹងឃើញមានការសំខាន់ ២ ផ្នែក គឺ

១ – ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកដែលឋិតថេរហូតមកដោយអាស្រ័យព្រះថេរានុត្ថេរៈទាំងឡាយ ដែលចេះចាំមាត់ស្ទាត់ច្រើនអង្គនេះជាលើកទី ១;

២— កាលព្រះថេរានុត្ថេរៈទាំងឡាយ ដែលចេះចាំមាត់ស្ទាត់ខ្សត់ទៅ មិនមានច្រើនអន្លើ ក៏កើតមានការចារឹកព្រះពុទ្ធវចនៈទាំងអស់នោះ ចុះកាន់ស្លឹករឹតទុកតមកទៀត, នេះទុកជាលើកទី ២ ។

ការសង្គាយនាតូចៗ ត ៗ មកគ្រប់ប្រទេសកាន់ពុទ្ធសាសនា ដូច លង្កា - ភូមា - សៀម - ឬ ទុរោប (Pali Tezt Society) ក៏មិនមានការប្លែកពីសង្គាយនាទី ៥ គ្រាន់តែមានសង្គាយនា ហើយចារឹកចុះកាន់ស្លឹករឹតឬបោះពុម្ពសៀវភៅទុកតគ្នាដដែលៗ ប៉ុណ្ណោះ នៅខ្វះការសំខាន់មួយលើកទៀតជាលើកទី ៣ គឺការប្រែព្រះពុទ្ធវចនៈជាភាសារៀងខ្លួន ៗ

ការប្រែព្រះពុទ្ធវចនៈ ជាភាសារបស់ខ្លួនគ្រប់ប្រទេសនេះកើតជាប្រស្នាមួយធំណាស់ មកពីមានសេចក្ដីយល់ផ្សេងគ្នា អ្នកខ្លះយល់ថាត្រូវប្រែចេញជាភាសារបស់ខ្លួន អ្នកខ្លះយល់ថាមិនត្រូវប្រែចេញជាភាសារបស់ខ្លួនទេ, ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកនេះ ត្រូវនៅជាបាលីដដែល អ្នកណាប្រែចេញជាភាសារបស់ខ្លួនមិនសមគួរទេ; ម្ល៉ោះហើយប្រទេសណាក៏ដោយក៏បណ្ដែតបណ្ដោយ មិនបានប្រែជាភាសារបស់ខ្លួនរហូតមក បើទុកជាមានប្រែខ្លះ ក៏ចំពោះតែសេចក្ដីខ្លះ ឬសូត្រខ្លះៗ បន្តិចបន្តួចប៉ុណ្ណោះ ៗ កាលប្រទេសយើងបង្កើតពុទ្ធសាសនបណ្ឌិត្យនេះឡើង ទើបយើងផ្ដើមចាត់ការប្រែព្រះពុទ្ធវចនៈ ជាភាសាខ្មែរយើងមុនគេបង្អស់ ៗ ការដ៏ធំហើយប្រពៃនេះ ក៏ចាប់កំណើតកើតឡើងនៅក្នុងលោកដោយ

ផ្សាយទូទៅ ។ ការបោះពុម្ពព្រះត្រៃបិដកយើងនេះ យើងទុកដាក់ជាផាសង្គាយនាដែលបានឲ្យឈ្មោះថា "ឆដ្ឋសង្គាយនា" ដោយការរបស់យើងបែកវិសេសជាងសង្គាយនាមុនៗ ទាំងអស់ គឺយើងបានប្រែជាភាសារបស់យើង ហើយបោះពុម្ពជាសៀវភៅមានបាលីទំព័រម្ខាង សំរាយខ្មែរយើងទំព័រម្ខាង តែយើងមិនបានដាក់ជាផាសង្គាយនាទីប៉ុន្មានទេ ។

ដល់មកត្រង់នេះ ខ្ញុំបាទសូមរំលឹកអស់លោកទាំងឡាយឲ្យបានជ្រាប ពីរបៀបចាត់ការសង្គាយនាព្រះត្រៃបិដកនៅប្រទេសយើងដោយល្អិតល្អន់អស់ដើម ។ ឯរបៀបចាត់ការនោះដូច្នេះ :

ព្រះរាជរដ្ឋាភិបាលរបស់យើងបានធ្វើក្រឹត្យលេខ ១០៦ ចុះថ្ងៃ១៤ ខែធ្នូ ឆ្នាំ ១៩២៩ តាំងអធិបតី ១ រូបនឹងក្រុមជំនុំប្រាំរូប, តមកកែប្រែក្រឹត្យថ្មី តាំងអធិបតី១រូប អធិបតីរង២រូប ក្រុមជំនុំ ៤០ រូប រួមហៅថាព្រះសង្គីតិកាចារ្យ ។ ព្រះសង្គីតិកាចារ្យទាំង ៤០ រូបនេះបែកជា ៥ ក្រុមគឺ:

១ – លោកសរសេរចម្លង ១ ក្រុម;

២ – លោកផ្ទៀងបាលី ១ ក្រុម;

៣ – លោកប្រែជាភាសាខ្មែរ ១ ក្រុម;

៤ – លោកពិនិត្យសេចក្ដីប្រែជាភាសាខ្មែរ ១ ក្រុម;

៥ – លោកពិនិត្យសេចក្ដីប្រែភាសាខ្មែរសម្រេច ១ ក្រុមទៀត ។

ព្រះសង្គីតិកាចារ្យទាំង ៥ ក្រុមនេះ ត្រូវមកធ្វើការនៅក្នុងពុទ្ធសាសន-

បណ្ឌិត្យ មានទីកន្លែងមួយពិសេសហៅថា "ក្រុមជំនុំប្រែព្រះត្រៃបិដក", កាលប្រជុំលើកដំបូង ក្រុមជំនុំបានសម្រេចថា កិច្ចការសង្គាយនានេះ ត្រូវយកព្រះត្រៃបិដកស្លឹករឹតខ្មែរយើងជាគោល ។ លុះបានជំនុំព្រមព្រៀងគ្នាហើយ ក្រុមជំនុំអ្នកចំឡង បានចំឡងចេញពីគម្ពីរស្លឹករឹតខ្មែរ, ចម្លងហើយបញ្ជូនទៅក្រុមជំនុំផ្ទៀងបាលី ។ ក្រុមជំនុំផ្ទៀងបាលីចាត់ការផ្ទៀងផ្ទាត់ បានយកព្រះត្រៃបិដក - ភូមា - លង្កា - សៀម - ឧរោប គឺ Pali text society មកផ្ទៀងគ្នាមើល កាលផ្ទៀងបើឃើញមានការប្លែកគ្នាខ្លះ ដោយអន្លើៗ មិនហ៊ានកែប្រែលុបលាងចោលទេ បានធ្វើជាលេខយោងហៅថា នយលក្ខណៈ មកដាក់នៅខាងក្រោមទំព័រហើយដកបន្ទាត់ខាន់ ដាក់អក្សរអាទិសង្កេតថា "ម" មើលថា មរម្មញ្ញ: គឺព្រះត្រៃបិដកភូមា ; "សី" មើលថាសីហឡ: គឺព្រះត្រៃបិដកកោះលង្កា "ឧ" មើលថាឧរោប គឺព្រះត្រៃបិដក Pali text society ក្រុមជំនុំផ្ទៀងបាលី បានពិនិត្យមើលហើយ បញ្ជូនទៅក្រុមជំនុំប្រែភាសាខ្មែរ ក្រុមជំនុំប្រែចាត់ការប្រែជាភាសាខ្មែរតទៅ លុះប្រែហើយបញ្ជូនទៅក្រុមជំនុំពិនិត្យសេចក្ដីប្រែក្រុមជំនុំនេះ កាលពិនិត្យសេចក្ដីប្រែនីមួយៗ បានយកអដ្ឋកថាដីកា យោជនា មកធ្វើជាគោល មិនមែនប្រែទៅតាមទំនើងខ្លួនទេ ។ លុះពិនិត្យសេចក្ដីប្រែនេះហើយ បញ្ជូនត្រឡប់ទៅឲ្យក្រុមជំនុំអ្នកសរសេរចម្លង ឲ្យសរសេរចម្លងសម្អាត ចម្លងសម្អាតហើយបញ្ជូនទៅឲ្យក្រុមជំនុំ

ពិនិត្យសេចក្ដីប្រែវិញ ។ ក្រុមជំនុំពិនិត្យសេចក្ដីប្រែពិនិត្យមើលម្ដងទៀត ឃើញថាត្រឹមត្រូវហើយ ទើបបញ្ជូនទៅក្រុមជំនុំពិនិត្យសេចក្ដីប្រែសម្រេច ។ ក្រុមជំនុំពិនិត្យសេចក្ដីប្រែសម្រេចនេះ ពិនិត្យផ្ទៀងផ្ទាត់មើលតាមអដ្ឋកថា ដីកា - យោជនា ជាដើមទៀត ដើម្បីបញ្ជាក់ឲ្យឃើញថាត្រឹមត្រូវពិតប្រាកដ, លុះពិនិត្យមត់ចត់ហើយ ទើបបញ្ជូនទៅសុំសេចក្ដីយល់ព្រមពីព្រះសង្ឃនាយកទាំង ២ គណៈ គឺពីព្រះសង្ឃនាយកទាំង២គណៈ បញ្ជូនសំណៅនេះទៅកាន់ការជំនុំរដ្ឋមន្ត្រីជាទីបំផុត ។ កាលចេញពីការជំនុំរដ្ឋមន្ត្រីហើយ ទើបអាចផ្ញើសំណៅនេះទៅរោងពុម្ពឲ្យចាត់ការបោះពុម្ពបាន ។ តាំងពីកើតការសង្គាយនាព្រះត្រៃបិដកឡើងកាលពីឆ្នាំ ១៩២៩ មកដល់ឆ្នាំ ១៩៥២ គិតទៅ ២៣ ឆ្នាំហើយ ព្រះសង្គីតិកាចារ្យឬដែលហៅថា ក្រុមជំនុំប្រែព្រះត្រៃបិដក បានប្រែព្រះត្រៃបិដកទាំង ៣ ជាភាសាខ្មែរឡើងចប់សព្វគ្រប់អស់ហើយ បានបោះពុម្ពជាសៀវភៅស្រេច ចំនួន ៣៧ សៀវភៅហើយ គឺវិនយបិដក ១៣ សៀវភៅ; សុត្តន្តបិដក ២៤ សៀវភៅ នៅសល់ខាងមិនទាន់ឡើងកាន់ពុម្ពទៀត ចំនួន ៦៣ សៀវភៅ គឺសុត្តន្តបិដកខ្លះ និងអភិធម្មបិដកទាំងអស់ ។ ចំនួន ២៣ ឆ្នាំនេះ ឃើញថាការឡើងនេះ គឺយូរពិតមែន តែហេតុដែលយឺតយូរប៉ុណ្ណោះ មិនមែនមកពីហេតុការណ៍អ្វីទេ គឺមកពីប្រទេសកើតសង្គ្រាម; សង្គ្រាមនេះហើយដែលបំផ្លិចបំផ្លាញឲ្យខ្វះខាតគ្រឿងឧបករណ៍នាំឲ្យខកខានបោះពុម្ពមកដល់ពេលនេះ ។

តាមសេចក្ដីពណ៌នាមកប៉ុណ្ណោះ យើងឃើញថាព្រះត្រៃបិដកយើង ឧត្ដមប្រសើរជាងព្រះត្រៃបិដកប្រទេសណា ៗ ទាំងអស់ សមឈ្មោះជា ឧត្ដមសង្គាយនា ពិតប្រាកដមែន ដោយហេតុ ២ ប្រការ គឺ

១ – យើងបានផ្ទឹមលក្ខណៈ ក្នុងព្រះត្រៃបិដកយើង ប្រាប់សេចក្ដីប្លែកគ្នាដោយអន្លើ ៗ ដែលមាននៅក្នុងព្រះត្រៃបិដកនានាប្រទេស ទាំងអស់ថា ត្រង់នេះព្រះត្រៃបិដកភូមា ថាដូច្នេះ, លង្កាថា ដូច្នេះ, ឧរោប ថាដូច្នេះទៀត បើយើងបានមើលត្រឹមតែព្រះត្រៃបិដកយើងមួយប៉ុណ្ណោះ យើងអាចដឹងសេចក្ដីប្លែកគ្នាគ្រប់ព្រះត្រៃបិដក ហាក់ដូចជាយើងបានមើល ព្រះត្រៃបិដកគ្រប់ប្រទេសទាំងអស់;

២ – យើងបានប្រែជាសំរាយភាសាខ្មែរយើងមុនគេបង្អស់ ក្នុងលោក ហើយបោះពុម្ពជាសៀវភៅ ទំព័រម្ខាងជាបាលី ទំព័រម្ខាងទៀតជាសំរាយ ភាសាខ្មែរ ៗ ការធ្វើដូច្នេះប្រទេសណា ៗ ក៏មិនទាន់បានធ្វើទេ មាន តែប្រទេសយើងមួយទេដែលអាចធ្វើការនេះមុនគេបង្អស់ ទុកជាការប្រសើរបំផុត បំពេញតាមសេចក្ដីត្រូវការដែលលោកអ្នកកាន់ព្រះពុទ្ធសាសនាត្រូវការ ព្រោះមើលតាមប្រវត្តិឃើញថាលើកទី ១ ព្រះសង្គីតិកាចារ្យ សង្គាយនាមក ៤ លើក បានគ្រាន់តែចងចាំព្រះត្រៃបិដកទុកមកដោយចាំមាត់ស្ទាត់, លើកទី ២ តាំងពីសង្គាយនាទី ៤ មក ព្រះសង្គីតិកាចារ្យបាន គ្រាន់តែចារឹកព្រះត្រៃបិដកជាលាយលក្ខណ៍អក្សរភាសាបាលី មិនទាន់

ហ៊ានប្រែជាសំរាយទេ, លើកទី ៣ ប្រទេសខ្មែរយើងបានប្រែជាសំរាយភាសាខ្មែរ បំពេញសេចក្ដីត្រូវការគ្រប់ទាំង ៣ លើក ។

ដោយការយើងប្រសើរដូចពោលមកនេះ ព្រះត្រៃបិដកយើងត្រូវបានពាក្យសរសើរនានាប្រការពីប្រទេស កាន់ពុទ្ធសាសនាទាំងឡាយទីងប្រទេសដទៃខ្លះ ។ បច្ចុប្បន្នកាលនេះ ព្រះត្រៃបិដកយើងមានកេរ្តិ៍ឈ្មោះ ល្បីសុះសាយពេញសាកលលោក ទាំងអាស៊ីនឹងឥរោប គេកោតសរសើរការងារយើងជាបំផុត ។ កាលពីឆ្នាំ ១៩៣១ មានអ្នកប្រាជ្ញលង្កាមួយរូបជាភិក្ខុនាមនារទៈ បានមកកាន់ប្រទេសយើង បានដឹងការងារនេះជាក់ច្បាស់ កាលត្រឡប់ទៅទ្វីបលង្កាវិញ បានព្រះត្រៃបិដកយើងមួយភាគ គឺវិនយបិដកភាគទី ១ យកទៅជាមួយខ្លួនផង អ្នកប្រាជ្ញនេះបានសរសេរផ្សាយ តាមសារពត៌មានក្នុងលង្កាទ្វីបថា ប្រទេសខ្មែរជាប្រទេសតូច ស្ទើរតែគេមិនដែលស្គាល់ឈ្មោះសោះ អ្នកប្រាជ្ញក៏មានតិច ហ៊ានធ្វើការធំណាស់ គឺហ៊ានសង្គាយនាព្រះត្រៃបិដក ហើយប្រែជាភាសារបស់ខ្លួន ដាក់ទំព័រម្ខាងបាលី ទំព័រម្ខាងជាភាសារបស់ខ្លួន ការងារនេះប្លែកប្រសើរណាស់ មិនមានប្រទេសណាក្នុងលោកអាចធ្វើបានទេ ហើយប្រទេសនេះមិនបេះអួតខ្លួនផង ។ ក្នុងសារពត៌មាននោះគេបានគូសរូបភាពព្រះត្រៃបិដកយើងភាគទី ១ នោះដាក់ផង ។ ក្នុងឆ្នាំ ១៩៤៨ អ្នកប្រាជ្ញបារាំងម្នាក់ឈ្មោះ Jean Filliozat បានមកកាន់មន្ទីរក្រុមជំនុំព្រះ

ត្រៃបិដកយើងបានពិនិត្យមើលការងារយើងហើយពោលសរសើរជាបំផុត, ទីបំផុតលោកមានប្រសាសន៍ថា "ប្រទេសបារាំងនឹងយកតម្រាប់តាមព្រះត្រៃបិដកខ្មែរនេះ ហើយបោះជាព្រះត្រៃបិដកបារាំង, តមកមិនយូរប៉ុន្មានប្រទេសបារាំងបានចេញព្រះត្រៃបិដកមួយភាគ ទំព័រម្ខាងជាបាលីអក្សររោម៉ាំងទំព័រម្ខាង សេចក្ដីប្រែជាភាសាបារាំង ក្នុងអារម្ភកថាដាក់ថាយកតម្រាប់តាមព្រះត្រៃបិដកភ្នំពេញ ប្រទេសកម្ពុជា" ។ ក្នុងពេលថ្មីៗនេះ ប្រទេសយើងបានផ្ញើព្រះត្រៃបិដកយើងមួយចប់ ទៅដម្កល់ទុកនៅប្រទេសឥណ្ឌៀ ។ វេលាប្រគល់ព្រះត្រៃបិដកនេះ គេបានរៀបពិធីមួយ ជាហេតុនាំឲ្យមានឮដំណឹងខ្ចរខ្ចាយ ដោយពួកសារពត៌មានទាំងឡាយផ្សាយតៗគ្នា ។ តមក ប្រទេសឥណ្ឌៀបានផ្ញើបុតហ្មាយមួយប្យាប់ប្វាយចំពោះព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ដូចមានសេចក្ដីនៅក្នុងសារពត៌មាន "Cambodge" លេខ ២ ១៧៤ ចុះថ្ងៃទី ១៩-១១-៥២ នេះស្រេកប់ ។ មិនតែប៉ុណ្ណោះទេ ប្រទេសខ្មែរយើងបានផ្ញើព្រះត្រៃបិដកយើងទៅដំកល់ទុកនៅលង្កាទ្វីប ១ ចប់ នៅប្រទេសភូមា ១ ចប់ទៀត ។ នៅប្រទេសទុពេចមានអ្នកជ្រះថ្លាជាវយកទៅទុកជាសម្បត្តិរបស់ខ្លួនក៏ច្រើនគ្នា ។ ក្នុងពេលនេះបានដំណឹងថាប្រទេសភូមា នឹងធ្វើសង្គាយនាពាក់កណ្ដាលសាសនាគឺ ព.ស. ២៥០០ ឆ្នាំ ហើយគេហ៊ានឲ្យឈ្មោះសង្គាយនានេះថា សង្គាយនាទី ៦ តពីសង្គាយនាទី ៥ នោះមក

គេបានសុំយកព្រះត្រៃបិដកយើងធ្វើជាគោល ក្នុងការសង្គាយនារបស់គេផង គេបានឲ្យយើងចំរើនបោះពុម្ពព្រះត្រៃបិដកយើងឲ្យឆាប់ចប់ទៅ ឲ្យទាន់ការគេកុំខាន ។ ពាក្យសរសើរទាំងអស់នេះ ជាហេតុនាំឲ្យប្រទេសនានាដែលកាន់ពុទ្ធសាសនាដូចគ្នាក្នុងលោកស្គាល់ប្រទេសកម្ពុជាយើង កាន់តែច្រើនទុកជាគេត្រឹមឈ្មោះប្រទេសកម្ពុជាយើង ។

ទីបំផុត ពុទ្ធសាសនបណ្ឌិត្យមិនធ្វេសប្រហែសសោះឡើយក្នុងការបោះពុម្ពព្រះត្រៃបិដកនេះ ចំហើយចំទៀតគិតដូចម្តេចឲ្យខាងតែបានសម្រេចតាមគោលបំណងមិនខាន ការខកខានយឺតយូរមកដល់នេះ ជាការផុតវិស័យដោយឥតកែខៃបាន, តែពុទ្ធសាសនបណ្ឌិត្យមិនអស់សង្ឃឹមទេ ដោយការខ្នះខ្នែងរបស់មន្ទីរនេះ ទើបបានអនុញ្ញាតពីព្រះរាជរដ្ឋាភិបាលបច្ចុប្បន្ន គឺព្រះរាជរដ្ឋាភិបាលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានទ្រង់ព្រះមេត្តាប្រោសព្រមឲ្យចំណាយថវិកាជាតិ ២ លានរៀលក្នុងមួយឆ្នាំៗ គិតពីឆ្នាំ ១៩៥៣ តទៅ សម្រាប់ជាជំនួយក្នុងការបោះពុម្ពព្រះត្រៃបិដកនោះទាល់តែបានចប់សព្វគ្រប់បរិបូណ៌ ដើម្បីទុកជាដល់ពុទ្ធសាសនិកជន ។ អាស្រ័យហេតុនេះយើងសង្ឃឹមថាតទៅមុខមិនយូរប៉ុន្មាន ព្រះត្រៃបិដកយើងនឹងបានសម្រេចសមតាមគោលបំណងយើងមិនខាន សូមអស់លោកអ្នកទាំងឡាយរង់ចាំទទួលអនុមោទនាត្រេកអរ ចំពោះកុសលនេះចុះ ។

អក្សរជាអាយុជីវិត
របស់ជាតិពិត តំតឿងឃ្លាត
យើងខ្មែរគួរតែ ខំខ្មីខាត
ប្រើអក្សរជាតិ របស់ខ្មែរ,

អក្សរសាស្ត្រខ្មែរ
( តពីសៀវភៅ លេខ ៧ - ៨ - ៩ ឆ្នាំ ១៩៥២ )

---

វគ្គទី ៣

# អក្សរសាស្ត្រសាកល

## ១ — បុព្វហេតុ

អក្សរសាស្ត្រ មកពី អក្សរ ១, សាស្ត្រ ១ ៗ អក្សរ តាមភាសាមគធៈ ថាអក្ខរៈ គឺស្នាមគំនូសមានតួរាងផ្សេង ៗ សម្រាប់ប្រើសរសេរកត់ពាក្យសំដីនឹងសេចក្ដីទាំងពួងប្រើមិនចេះអស់ ( តាមវចនានុក្រមខ្មែរ ) ៗ សាស្ត្រ តាមភាសាសំស្ក្រឹតថា សាស្ត្រ, តាមភាសាមគធៈថា សត្ថៈ ប្រែថា គម្ពីរ, ច្បាប់, ក្បួនតម្រា, វិជ្ជា, ការសិក្សាពាក្យពន្យល់ ៗ អក្សរសាស្ត្រ ប្រែថាៈ គម្ពីរក្បួននិយាយពីអក្សរ ៗ

អក្សរសាស្ត្រ គឺ កិច្ចការខាងវប្បធម៌ចំពោះប្រាជ្ញា មានតម្រាខាងពួកវាគ្មិនទាំងអ្នកនិពន្ធ; ខាងពួកវាគ្មិន គឺការហាត់សំដីនិយាយ; ខាងពួកនិពន្ធ គឺ ការហាត់សរសេរតែងសេចក្តី ។ អក្សរសាស្ត្រ គឺ ផលិតកម្មនៃវិជ្ជាគ្រប់យ៉ាងចំពោះសតវត្សប្រជាជាតិសម័យ ។

អក្សរសាស្ត្រកើតមកពីភាសា; ភាសាបើតាមឯកឧត្តមអៀវ-កើស អតីតប្រធានរដ្ឋសភាកម្ពុជរដ្ឋ លោកបាននិពន្ធទុកក្នុងសៀវភៅមួយនាម "ភាសាខ្មែរ, ក្បាលទី ១" ថា: "ភាសាជាការសំដែងចិត្ត, គំនិតដោយពាក្យសំដី, តែយើងមិនបានរកឫត្តហេតុ អំពីភាសាសត្វមនុស្សនោះទេ; រឿងនេះសូមទុកឲ្យបណ្ឌិតចំណានខាងភាសាសាស្ត្រ, លោកស្វះស្វែងរកវត្ថុធាតុផ្សេង ៗ តាំងពីសំឡេងដំបូង ជាធម្មជាតិនៃភាសារហូតដល់ភាសាដែលកើតពីបញ្ចប្រសាទ មានជិវ្ហប្រសាទជាដើម, ភាសាកើតពីមនោ អាកប្បកិរិយា ភាសាសត្វលោកតាំងពីមនុស្ស គឺ, ភូត, បិសាច, ទេវតាតាមភូមិ មានកាមភូមិ ឬទេវភូមិជាដើម, ភាសាស្ងាត់ក្នុងព្រះនិព្វានជាឫត្តហេតុនៃភាសាទាំងអស់ ក្នុងលោក ។

## ២ — សមាសភាព

អក្សរសាស្ត្របែងចែកជាពីរយ៉ាង គឺ: ១– ពាក្យរាយ (prose

២– កវីនិពន្ធ (Poésie

### ១ — ពាក្យរាយ — មានប្រាំយ៉ាង គឺ:

១– រឿងព្រេង (Histoires, contes)

២– រឿងប្រលោមលោក (Romans)

៣– រឿងសម្រាប់ឲ្យនិស្សិតសិក្សានៅសាលារៀន ( Genre didactique )

៤– រឿងសភាពជាលិខិត (Genre épistolaire)

៥– រឿងវទសិល្បៈ (Genre oratoire)

២ – កវីនិពន្ធ- មាន ៧ យ៉ាងគឺ:

១– វទនកវីនិពន្ធ (Poésie lyrique)

២– វីរភាពកវីនិពន្ធ (Poésie épique)

៣– វសិក្ខភាពកវីនិពន្ធ (Poésie didactique)

៤– រឿងល្បើក (Fable)

៥– លិខិតកវីនិពន្ធ (Epitre)

៦– គាមគណ្ហកវីនិពន្ធ ( Idylle )

៧– រឿងរបាំល្ខោន (Genre dramatique)

គឺរឿងនេះ មានបរិទេវគតិ (Tragédie) ១, ហាសគតិ (Comédie) ២ ហាសសោកគតិ (Drame) ៣,

ក្រៅពីនេះ នៅមានកវីនិពន្ធឯទៀតជាច្រើន ។

អក្សរសាស្ត្របើបែងចែកទៅតាមសភាពប្រទេស ទីដែលភាសាកើតមក សាកលលោកមាន ១៩ យ៉ាងគឺ:

១ - អក្សរសាស្ត្រ ចុងបូព៌ាប្រទេស
២ - — ឥណ្ឌា
៣ - — បូព៌ាទ្វីប
៤ - — ស៊ីរី
៥ - — ក្រិក
៦ - — ឡាតាំង
៧ - — សែលទីក
៨ - — ឧត្តរប្រទេស
៩ - — ហ៊្វ័ឡាង់ទីងបាល់ទិក
១០ - — ស្លាវ
១១ - — ហុងគ្រា
១២ - — រូម៉ាន
១៣ - — អង់គ្លូសាកសុង
១៤ - — សែរម៉ានិក
១៥ - — បែល
១៦ - — ស៊ុយស

១៧ – អក្សរសាស្ត្រ សៀម

១៨ – – ខ្មែរ

១៩ – – យួន

អក្សរសាស្ត្រ ចំរើនតាមមហាសម័យមានបួនៈ ១- មហាសម័យ ពែរីគ្លេស (Siècle De Périclès)

២- មហាសម័យអូគុស្ត (Siècle d'Auguste)

៣- មហាសម័យលេអុងទី ១០ (Siècle de Léon X)

៤- មហាសម័យល្វីទី ១៤ (Siècle de Louis XIV)

ចំណែកខាងសម័យទំនើប ទំនងសម័យបច្ចុប្បន្នមិនឃើញមានអ្នកប្រាជ្ញខាងអក្សរសាស្ត្រចារឹកទុកថា មានមហាសម័យឬមិនមាននោះឡើយ ។

## ៣ – វិវត្តន៍នៃអក្សរសាស្ត្រ

អក្សរសាស្ត្រដែលនឹងវិវត្តទៅបានមកពី :

ក) មានបណ្ឌិតអ្នកនិពន្ធសៀវភៅក្បួនខ្នាត, តម្រា, ជីវប្រវត្តិច្រើន

ខ) អក្សរសាស្ត្រមានរបៀបវេយ្យាករណ៍ត្រឹមត្រូវ

គ) មានបណ្ណាល័យសម្រាប់ដំកល់ឯកសារផ្សេង ៗ

ឃ) មានបណ្ណាគារ រោងពុម្ពអក្សរ បង្កើតឲ្យមានរង្វាន់ដល់អ្នកនិពន្ធ

ង) មានអ្នកអានសៀវភៅច្រើន ជាហេតុឲ្យមានសៀវភៅ ទស្សនាវដ្ដី សារពត៌មានច្រើន

ច) បង្កើតឲ្យមានសមាគមអក្សរសាស្ត្រ ឲ្យមានការប្រជុំធ្វើ សន្និសិទ, ថ្លែងសុន្ទរកថាជាដើម ។

ឆ) ចាត់ឲ្យមានជនជាតិទៅរៀននានាប្រទេស

ជ) ចាត់គណៈកម្មការវប្បធម៌, បកប្រែសៀវភៅបរជាតិ

ក) មានបណ្ឌិតអ្នកនិពន្ធសៀវភៅក្បួន, ខ្នាត, តម្រា, ជីវប្រវត្តិច្រើន:

បណ្ឌិតប្រែថាអ្នកប្រាជ្ញ គឺអ្នកមានចំណេះវិជ្ជាគ្រប់យ៉ាង អាចតែងសៀវភៅ, ក្បួន, ខ្នាត, តម្រា, ជីវប្រវត្តិ និងរឿងរ៉ាវផ្សេងៗ ដែលមានប្រយោជន៍ដល់ជាតិ, សាសនា ជាដើម ។ វិជ្ជាជាអរិយទ្រព្យមិនចេះពុក, ផុយ, រលួយ ចេះតែឋិតថេរចិរកាលតទៅអនាគត ។ វិជ្ជាមានដូចជារសផ្សាយក្លិនក្រអូបទៅសព្វទិសានុទិស មានសូរសព្ទពីរោះអស្ចារ្យ ។ បណ្ឌិតអ្នកមានវិជ្ជាអាចទូន្មានប្រដៅជនជាតិ ដែលនៅជិតខាងបុគ្គល កុំឲ្យប្រាសចាកនូវភ័យទាំងឡាយ មានរាជភ័យជាដើមឲ្យរកមធ្យោបាយផ្សេងៗ ដើម្បីនឹងចៀសវាងនូវសេចក្ដីអន្តរាយផ្សេងៗ មានជាប់ពន្ធនាគារជាដើម ។ បណ្ឌិតអាចអប់រំនិស្ស័យជនជាតិរបស់ខ្លួនឲ្យចូលចិត្តខាងការរៀនសូត្រ ឲ្យខ្ពើមនូវសេចក្ដីខ្ជិលច្រអូសឲ្យព្យាយាមអានគម្ពីរ

សាស្ត្រា, ក្បួន, ខ្នាត, តម្រា, ដើម្បីនឹងផ្ទេរបំណោះនេះឲ្យជនជាតិរបស់ខ្លួនបានបេះដឹងកាន់តែច្រើនឡើង ជាហេតុរបនាឲ្យប្រទេសជាតិសម្បូណ៌ដោយវិញ្ញូជន នឹងពហុស្សុតព្រមទាំងពួកសុមេធាបុរសធ្វើជាតិឲ្យឡើងទៅកាន់វឌ្ឍនធម៌បាន ។ ដើម្បីនឹងធ្វើឲ្យបណ្ឌិតប្រឹងប្រែងតែងក្បួនច្បាប់ឲ្យច្រើន ត្រូវចារិកដីវប្រវត្តិលោក ធ្វើរូបសំណាកព្រមទាំងប្រមូលរឿងរ៉ាវដែលលោកបាននិពន្ធ, នាមឈ្មោះចុះក្នុងប្រវត្តិនៃអក្សរសាស្ត្រ ជាហេតុឲ្យនាមនោះមានកិត្តិសព្ទល្បីល្បាញក្នុងពិភពលោកជាមធ្យោបាយមួយដ៏ប្រសើរ ដើម្បីនឹងរក្សាអមតភាពនៃនាមនោះទុកឲ្យកូនចៅក្រោយ ។ ករណីយកិច្ចនេះគួរធ្វើពន់ពេក ព្រោះជាហេតុញុំាងឲ្យប្រទេសជាតិមាតុភូមិសម្បូណ៌បណ្ឌិតខាងអក្សរសាស្ត្រ ព្រោះប្រាថ្នានូវអមតភាពនៃនាមទុកក្នុងប្រវត្តិនៃអក្សរសាស្ត្រជាតិ ។

បណ្ឌិតបណ្តុះ ពូជប្រាជ្ញដ៏ក្លិះ ក្ដីជាតិសាសនា
មាតុភូមិថ្កើង ធ្វើជាតិបុប្ផា ឈ្មុយគ្រប់ទិសា
មហាចំរើន ។

## ១) អក្សរសាស្ត្រមានរបៀបវេយ្យាករណ៍ត្រឹមត្រូវ:

អក្សរសាស្ត្រដែលនឹងចំរើនទៅបាន មកពីមានរបៀបវេយ្យាករណ៍ត្រឹមត្រូវ គឺកំណត់ឲ្យសរសេរពាក្យតាមអក្ខរាវិរុទ្ធតាមមូលដើម កុំឲ្យសរសេរពាក្យតាមតែបាន ដូចជាពាក្យថា គុកបុត្ត: បុត្តជាដើម ។

ពាក្យណាដែលមានរបៀប ពាក្យនោះអាចធ្វើឲ្យអក្សរសាស្ត្រចំរើនតាមលំដាប់ទៅបាន ។ ក្នុងទីនេះ មិនបានពោលនូវវេយ្យាករណ៍ដោយបរិយាយទេ គ្រាន់តែសំដែងគោលបំភ្លឺនូវជាតិទាំងឡាយឲ្យជាប គឺត្រូវមាន អក្ខរៈ, ព្យញ្ជនៈ, ស្រៈ, នាម, នាមសព្ទ, គុណនាម, លិង្គ, បព្វនាម,កិរិយាសព្ទ ជាដើម ។

វេយ្យាករណ៍ចំរើន អក្សរសាស្ត្រ ធ្វើជាតិកបច្បាស់ យល់វិជ្ជានា
អក្សរមានរបៀប ធ្វើពូជជា សុរិទ្យនានា ថ្លៃឧត្តម ។

## គ) មានបណ្ណាល័យសម្រាប់ដំកល់ឯកសារផ្សេង ៗ:

បណ្ណាល័យគឺជាឃ្លាំងវិជ្ជា សម្រាប់ប្រមូលវិជ្ជាគ្រប់យ៉ាង យកមកដំកល់ទុកមានសៀវភៅ, ក្បួន, ខ្នាត, តម្រា, អក្សរសាស្ត្រជាតិ, ទាំងនានាជាតិ ។ បណ្ណាល័យជាស្ថានទី សម្រាប់ឲ្យបណ្ឌិតអ្នកនិពន្ធស្រាវជ្រាវរឿងការផ្សេង ៗ ឯកសារដើម្បីនឹងប្រមូលវត្ថុធាតុ យកទៅតែងសៀវភៅ ។ បើរកវត្ថុធាតុនេះខ្វះនោះខ្វះ បានអ្វីយកទៅតែងសៀវភៅក្បួន, ខ្នាត, បានអ្វីធ្វើជាតិឲ្យចំរើនរុងរឿង? ប្រទេសណាគ្មានបណ្ណាល័យ, ប្រទេសនោះគ្មានវិជ្ជា, ប្រទេសនោះប្រកបដោយបុគ្គលល្ងង់ខ្លៅជាហេតុវិនាសដល់ជាតិពិត ៗ ។

បណ្ណាល័យ ប្រមូលសៀវ- ភៅក្បួនខ្នាត
ធ្វើជាតិឆ្លាត ឲ្យភ្លឺឆ្លុះ តាមលំអាន
មានបណ្ឌិត មកជួបជុំ ព្យាយាមប្រាណ
សាកសួរដាន ឲ្យបានដឹង ចេះប្រាជ្ញប្រាយ ។

ឃ) មានបណ្ណាគារ រោងពុម្ពអក្សរ បង្កើតឲ្យមានរង្វាន់ដល់អ្នកនិពន្ធ:

ការដែលមានបណ្ណាគារច្រើនលក់សៀវភៅផ្សេង ៗ ដែលនិពន្ធពីអក្សរសាស្ត្រនាំឲ្យជាតិចំរើន ៗ ជាតិណាសម្បូណ៌ដោយសៀវភៅគ្រប់បែប-យ៉ាង ជាតិនោះនឹងសម្បូណ៌ទៅដោយអ្នកប្រាជ្ញជាហេតុនាំឲ្យគិតច្រើន ការគិតច្រើននាំឲ្យមានប្រាជ្ញា ៗ អាចរចនាជាតិឲ្យមានពន្លឺស្វាងរុងរឿង សមជាអារ្យជាតិ, បណ្ណាគារបង្កើតបានអាស្រ័យរោងពុម្ពជាអ្នកបោះពុម្ពសៀវភៅ ៗ បើមានតែសៀវភៅគ្មានរោងពុម្ព, អក្សរសាស្ត្រមិនអាចធ្វើដំណើរទៅបានស្រួល ៗ រោងពុម្ពជាមធ្យោបាយមួយដើម្បីនឹងចំរើនអក្សរសាស្ត្រ ៗ អ្នកប្រាជ្ញដែលនឹងមានកំលាំងសរសេរតែងសៀវភៅបានអាស្រ័យមានរង្វាន់ គឺថាបណ្ណាគារទទួលបោះពុម្ពសៀវភៅបណ្ឌិតណា ត្រូវតែឲ្យរង្វាន់ទៅបណ្ឌិតនោះ ដើម្បីនឹងញុំាងទឹកចិត្តឲ្យព្យាយាមសរសេរសៀវភៅតទៅទៀត ។ តែនៅប្រទេសកម្ពុជា អ្នកតែងសៀវភៅមិនទាន់មានកំរៃទេ ហើយគេទទួលទានសៀវភៅ

ច្រើនអត់បាយ ៗ បានតែប្រទេសខាងអឺរ៉ូបឬអាមេរិកដែលសម្បូណ៌ ដោយបណ្ឌិតអ្នកតែង គេអាចធ្វើវិជ្ជាជីវៈនេះបាន ព្រោះមានរង្វាន់ខាងបណ្ណាគារគ្រប់គ្រាន់បរិបូណ៌ ៗ

បណ្ណាគារ កេងពុម្ពពិត វឌ្ឍនា
សាងតួជា ធ្វើចិត្តជាប់ អារ្យជាតិ
អក្សរសាស្ត្រ ចំរើនសាង ជួយក្រមញាតិ
ប្រែលោកធាតុ កែសាសនា ប្រសើរឯក ៗ

ង) មានអ្នកអានសៀវភៅច្រើនជាហេតុឲ្យមានសៀវភៅក្បួន, ខ្នាត, តម្រា, ទស្សនាវដ្ដី, សារពត៌មានគ្រប់ផ្នែកជាច្រើនៈ

ព្រោះហេតុដូចនេះ សូមបងប្អូនរួមជាតិទាំងឡាយ បបួលគ្នាអានសៀវភៅភាសាខ្មែរនឹងភាសាបរជាតិឲ្យគ្រប់ ៗ គ្នាឡើង ព្រោះសៀវភៅនិមួយ ៗ សុទ្ធតែយោបល់, មតិ, គតិអ្នកប្រាជ្ញដែលអានទៅហើយ អាចបំបាត់សេចក្ដីល្ងង់ចេញពីសន្ដាន ញុំាងចិត្តឲ្យមានប្រាជ្ញាភ្លឺស្វាង; ប្រាជ្ញានេះហើយជាអាវុធតែងកាត់ផ្ដាច់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើតឲ្យមានឡើង; ប្រាជ្ញារចនាមនុស្សសាមញ្ញឲ្យទៅជាបណ្ឌិតអ្នកប្រាជ្ញ ដែលគេហៅថាពហុស្សុត ឬ វិញ្ញូជន ; ប្រាជ្ញាញុំាងជាតិ, សាសនា, មហាក្សត្រឲ្យបានចំរើនរុងរឿងរចនាកាយ វាចា ចិត្ត របស់មនុស្សប្រុសស្រីទៅកាន់វឌ្ឍនភាព ៗ ប្រាជ្ញានេះមានគុណានុភាពជាអនេកប្បការដូចមាន

ពុទ្ធការសិតជាច្រើនក្នុងមានបញ្ញាបទពោធ ប្រាជ្ញាជាបទីបបំភ្លឺលោក-តាំងមូលជាដើម ។ ប្រាជ្ញាដែលទើបកើតមានបានមកពីអ្នកអានសៀវភៅច្រើន ៗ តែងយកគតិបណ្ឌិតទៅពិចារណា ត្រិះរិះឲ្យយល់សព្វគ្រប់ទើបកើតជាគតិរបស់ខ្លួន យកទៅអនុវត្តន៍ខាងស័ង្គម, សាសនា, ជាតិ, សេដ្ឋកិច្ច, រដ្ឋបាល, តុលាការ ជាដើម ៗ

អ្នកអានច្រើន គួរគិតជ្រាប ប្រាជ្ញប្រផៅ
បំបាត់ខ្ចៅ បំណាន់ខ្ទឹម ដេញពួជខ្លាច
អ្នកគិតច្រើន បម្រើនជាតិ មានអំណាច
ហៅបេះបាច បង់លះបង់ អវិជ្ជា ៗ

ប ) បង្កើតឲ្យមានសមាគមអក្សរសាស្ត្រ, ឲ្យមានការប្រជុំធ្វើសន្និសីទ, ប្រឡងសុន្ទរកថាជាដើម:

សមាគមគឺការរួបរួមពួកក្រុមគណៈនិកាយ ដើម្បីនឹងប្រមូលគ្នាជាកម្លាំងមួយ ធ្វើកិច្ចការសព្វសារពើ ប្រយោជន៍ជាតិ, សាសនា, មហាក្សត្រ ជាដើម ៗ សមាគមនេះគឺបំណងដើម្បីបណ្តុះធម៌សាមគ្គីឲ្យកើតឲ្យមានឡើង មានការប្រជុំគ្នារាប់រកគ្នាដោយមេត្រីភាព មិនប្រកាន់បក្សពួក, គណៈនិកាយ, ទុកថាជាជនជាតិខ្មែរតែមួយ ៗ ការប្រជុំនេះហើយ ដែលនាំឲ្យមានប្រាជ្ញាដែលកើតឡើង ដោយសារការសន្ទនាគ្នាទៅវិញ-មក ការដេញដោលរកខុសត្រូវ ; ការជួបជុំគ្នាញឹក

ញ្ញាប់នាំឱ្យកើតសេចក្ដីស្និទ្ធស្នាលគ្នាទៅវិញ-មក, នាំឱ្យបញ្ចេញមតិយោបល់ផ្សេងៗ ជាគំនិតបុគ្គលម្នាក់ ៗ ; អធិបតីសមាគមអាចប្រមូលយោបល់មតិនោះទៅជ្រើសរើស, ពិនិត្យឱ្យហ្មត់ចត់ ទើបកើតគំនិតមួយថ្មី គឺលៃលកគំនិតណាដែលមានប្រយោជន៍ដល់សមាគម ត្រូវយកមកអនុវត្តឱ្យសមាគមនោះដុះដាលឡើង ៗ

សមាគមសាមគ្គី ព្រមព្រៀងគ្នា
ធ្វើជាតិជា ចិត្តចងជាប់ កបដោយជ័យ
ប្រជុំគ្នា ញឹកញយ ៗ ជាតិចាកភ័យ
ប្រមូលន័យ យោបល់បាន ស្ពានប្រឹមប្រិយ ៗ

ង ) ហាត់ឱ្យជនជាតិទៅរៀននានាប្រទេស:

ជនជាតិទាំងអស់គ្នា គ្រប់រូប ត្រូវទៅរៀនប្រទេសក្រៅ មានប្រទេសអាមេរិក, បារាំង, អង់គ្លេស, រុស្ស៊ី ជាដើម ដើម្បីនឹងក្រេបយករសជាតិពីប្រទេសក្រៅមានវិជ្ជាទាំងផ្លូវលោកទាំងផ្លូវធម៌មក អប់រំជនជាតិរបស់យើងឱ្យបានចំរើនគ្រប់ថ្នាក់ ជាន់ ខាងសេដ្ឋកិច្ច, ខាងអក្សរសាស្ត្រ, ជាដើម ៗ ប្រទេសនីមួយ ៗ តែងមានឧបាយសព្វ ៗ ខ្លួន ដើម្បីធ្វើប្រទេសជាតិគេឱ្យចំរើន គឺគេតែងហាត់ឱ្យពួកនិស្សិតទៅរៀនវិជ្ជានៅប្រទេសក្រៅ ; ប្រមូលវិជ្ជាទាំងនោះយកមកជ្រើសយកវិជ្ជាណាដែលអប់រំជាតិគេឱ្យបានចំរើន ៗ ធម្មតាប្រទេសជាតិនីមួយ ៗ តែងមានចរិត

ជាតិមួយនិស្ស័យជាតិ ៗ ខ្ពស់ឆ្លាតវាងវៃខាងច្បាប់, ខាងពាណិជ្ជវិទ្យា, ខាងវិទ្យាសាស្ត្រ, ខាងសន្តិបាលជាតិជាដើម ; និស្សិតទាំងនោះតែងនៅក្រេបយករសជាតិនៃស៊ីវិល័យនានាប្រទេស ដូចជាកន្ទង់ឃ្មុំតែងទៅក្រេបគេសរបុប្ផាមកធ្វើសំបុកដូចនោះ ៗ ឧបាយនេះគេហៅថាលួចវិទ្យា ; ព្រោះហេតុដូចនេះ ប្រទេសនីមួយ ៗ តែងមានទំនៀមទម្លាប់អាមេរិក អឺរ៉ុបចូលមកលាយឡំជាមួយ ដូចជាគ្រឿងស្លៀកពាក់ខ្លួនហត្ថកម្មជាដើម ៗ កិច្ចការទាំងនេះដែលកើតឡើងបាន លុះត្រាតែនិស្សិតទាំងនោះទៅរៀនភាសានានាប្រទេស ទើបអាចស្រាវជ្រាវក្បួនខ្នាតរបៀប, ប្រពៃណី, ទំនៀមទម្លាប់ ដែលចារឹកទុកក្នុងសៀវភៅនានាជាតិបានចេះដឹងសព្វគ្រប់ ; ការចេះភាសាបរជាតិនេះ ជាយានដ៏ប្រសើរសម្រាប់ទៅកាន់វឌ្ឍនធម៌របស់ជាតិទាន់កាលសម័យសាងលោក ៗ ព្រោះហេតុដូចនេះ ការចេះភាសាច្រើននាំឲ្យមានប្រាជ្ញាច្រើនរបៀប ដូចជាកណ្ដុរមិនស្គាល់ត្រឹមតែរន្ធរបស់ខ្លួន គឺស្គាល់រហូតដល់គេហដ្ឋានទាំងមូល នឹងគេហដ្ឋានដទៃទៀត ព្រមទាំងព្រៃ, ភ្នំ, ជ្រោះ, គុហា, ស្ទឹង, បឹង, ទន្លេ, សមុទ្រផង វិជ្ជាគ្មានព្រំដែនទេ, គ្មានទំហំជំរៅទេ ៗ

អ្នកដើរច្រើន ស្រុកចេះជ្រាប ធម្មាលោក

កបដំយជាគ ភាសាចេះ ក្ដីបាំងបែង

មករបទា ប្រទេសជាតិ រស្មីបែង

ចាត់ចារចែង វឌ្ឍនា សុខសួស្ដី ៗ

## ង) ខាត់គណៈកម្មការវប្បធម៌បកប្រែសៀវភៅបរជាតិជាដើម៖

អក្សរសាស្ត្រដែលនឹងចម្រើនទៅបាន មកពីមានពាក្យប្រើគ្រប់គ្រាន់បរិបូណ៌ គឺ ពាក្យតិកនិក, ពាក្យសម្រាប់ប្រើគ្រប់ក្រសួង, ក្រុម, ពាក្យខាងវិទ្យាសាស្ត្រវាដើម, បានជាក្រសួងសិក្សាធិការប្រទេសកម្ពុជា បានស្ថាបនានូវគណៈកម្មការវប្បធម៌ ដើម្បីនឹងប្រមូលពាក្យទាំងប៉ុន្មានយកមកអនុវត្តតាមផ្លូវការ ។

គួរឲ្យមានគណៈកម្មការបកប្រែសៀវភៅបរជាតិ ដើម្បីនឹងប្រមូលក្បួនខ្នាត សៀវភៅជាច្រើន ទុកជាឃ្លាំងវិជ្ជាសម្រាប់យកមកប្រើប្រាស់តាមត្រូវការ; ការនេះនឹងធ្វើឲ្យសម្រេចបាន អាស្រ័យពួកនិស្សិត ដែលចេញទៅសិក្សារៀនប្រទេសក្រៅ ទើបចេះភាសាបរជាតិ ចេះដឹងជ្រៅជ្រះ ៗ មួយយ៉ាងវិញទៀត គួរចាត់ឲ្យបកប្រែសៀវភៅសម្រាប់ឲ្យកូនសិស្សសាលារៀនតាំងពីបឋមភូមិ រហូតដល់ឧត្តមភូមិ ព្រមទាំងសៀវភៅសម្រាប់រៀនខាងមហាវិទ្យាល័យ រហូតដល់បរិញ្ញា បុបណ្ឌិត តាមត្រូវការ ៗ បើធ្វើយ៉ាងនេះហើយ គង់អក្សរសាស្ត្រនឹងបានឡើងទៅកាន់វឌ្ឍនភាពមិនខាន ៗ

## ៤ — ការវិនាសអក្សរសាស្ត្រ

អក្សរសាស្ត្រ ដែលនឹងវិនាសទៅបានមកពី៖

ក) កើតសង្គ្រាម

ខ) គ្មានតម្លៃ

គ) គ្មានអ្នកតែងសៀវភៅក្បួន, ខ្នាត

ឃ) មានតែអ្នកនិយមប្រើភាសាដទៃ

ង) គ្មានអ្នកស្រាវរកបណ្ឌិតខាងអក្សរសាស្ត្រ តាមកាលដើម្បីនឹងរក្សាទុកនូវដំណើរប្រវត្តិរូបចតនឹងស្នាដៃបណ្ឌិតទាំងនោះ ព្រមទាំងគ្មានអ្នកវេយ្យាករណ៍ រចនាអក្សរសាស្ត្រឲ្យមានរបៀប អក្ខរៈ ព្យញ្ជនៈ, ស្ថានភាពផ្សេងៗ ទៅតាមផ្លូវការ ។

ក) កើតសង្គ្រាម — ប្រទេសណាដែលកើតសង្គ្រាមធ្លាក់ទៅនៅក្រោមបង្គាប់បញ្ជាប្រទេសដទៃ ច្រើនវិនាសអក្សរជាតិ ព្រោះប្រទេសដទៃគេច្រើនប្រើសិទ្ធិរំលោភហួសហេតុ បង្ខិតបង្ខំឲ្យប្រទេសអនិស្សរភាពសិក្សារៀនសូត្រភាសាអក្សរជាតិគេ ទាល់តែភ្លេចភាសាជាតិរបស់ខ្លួន ដូចជាប្រទេសអណ្ណាមដែលជាប្រទេសចាមពីដើម ឬភូមិភាគបាត់ដំបងកាលសៀមចូលមកកាន់កាប់ការ ឬភូមិភាគអាល់សាស់ឡូរែន ខាងប្រទេសបារាំងដែលភាសាអាល្លឺម៉ង់ចូលមកលុកលុយជាដើម ។

ខ) គ្មានតម្លៃ — អក្សរដែលមិនចម្រើនទៅបានមកពីគ្មានតម្លៃ គឺអក្សរគេ មិនសូវនិយមប្រើជាផ្លូវការ ដល់យូរទៅមុខជាសាបសូន្យមិនខាន ។ ព្រោះហេតុដូចនេះ ត្រូវខេមរជាតិកុំប្រមាទ ប្រញាប់ប្រញាល់ប្រើអក្សរជាតិជាផ្លូវការ ឬឲ្យតម្លៃដល់អ្នកចេះភាសាខ្មែរ ដល់អ្នក

មានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ឲ្យស្មើនឹងអ្នកមានសញ្ញាប័ត្រ បឋមសិក្សាខាងភាសាបារាំង ។

**គ) គ្មានអ្នកតែងសៀវភៅក្បួនខាត** — ការដែលគ្មានអ្នកតែងសៀវភៅក្បួនខាត មកពីគ្មានអ្នកអានច្រើន, ប្រទេសដែលនឹងសម្បូណ៌ដោយសៀវភៅច្រើន មកពីប្រទេសនោះមានអ្នកនិយមអានច្រើន ; ព្រោះហេតុដូចនេះ សូមខេមរជាតិនិយមទាំងបុរស-ស្ត្រី ក្មេង ចាស់ និយមអានសៀវភៅ, ពិចារណារកហេតុផលគតិយោបល់អ្នកតែង, គំនិតអ្នកនិពន្ធ, ដើម្បីនឹងឲ្យកើតប្រាជ្ញាភ្លឺស្វាងឡើង ។

រ៉ាយ-ប៊ុក

(មានត)

( តពីសៀវភៅលេខ ៧-៨-៩ ឆ្នាំ ១៩៥២ )

---

## វិធីប្រើសង្ខ្យាសព្ទ

(១៧) ដែលនឹងរាប់វត្ថុ ៗ គេដាក់សង្ខ្យារៀងភ្ជាប់ពីក្រោយនាម-នាមឬភ្ជាប់ខាងមុខនាមនាម តាមទំនងស្រួលមាត់ជាក្នុងភាសាដូចរាប់ថា: មួយរៀល, ពីររៀល... មួយពាន់នាក់, មួយសែនហាប, មួយលាននាក់,... គោពីរ, សេះមួយរយ, ឥដ្ឋមួយម៉ឺន, ទាហានមួយកោដិ, កណ្ដាប់មួយស្លឹក,.. កូនដំបូង, ថ្នាក់បន្ទាប់, សេចក្ដីគំរប់ប្រាំ,.. បឋមជ្ឈាន, បឋមាសាឍ, ទុតិយាសាឍ, បញ្ចមីឧបោសថ, អដ្ឋមីឧបោសថ... ជាដើម ។

## និបាតសព្ទ

(១៨) និបាតសព្ទសម្រាប់ផ្សំដំតែងឃ្លាល្បះមួយ ៗ ជាជំនួយនាមសព្ទនឹងកិរិយាសព្ទឲ្យមានសេចក្ដីស្រឡះច្បាស់លាស់ពីរោះស្រួលស្ដាប់ ដូចពាក្យថា ក៏, ក៏ដោយ, ក៏ដែរ, ដែរ, ក្ដី, ផង, ឯ, បើ, ទោះ, ទោះបី, បើទុកជា, ពុំនោះសោត, លើកតែ, ព្រោះថា, ដ្បិតថា.. ជាដើម; និបាតសព្ទនោះមានច្រើនយ៉ាងដូចតទៅនេះ :

### និបាតប្រាប់ពេល, ប្រាប់កាល

គ្រានោះ, លំដាប់នោះ, ដងនោះ, កាលនោះ, ក្សណនោះ, ព្រឹក, អំពីព្រឹក, ថ្ងៃ, ក្នុងវេលាថ្ងៃ, ល្ងាច, ពេលល្ងាច, ម្សិល ម្សិលមិញ.

ពីម្សិលមិញ, ស្អែក, ខានស្អែក ខានស្អែកមួយ, អម្បាញមិញ, ភ្លាម, មួយរំពេច, ស្រិន, តទៅ, កន្លងមុខ ។

## និបាតប្រាប់ទី

ខាងលើ, ខាងក្រោម, ខាងក្រោយ, ខាងក្នុង, ខាងក្រៅ, ចន្លោះ, រវាង, ស្ងាត់, ទីស្ងាត់, កំបាំង, កំបាំងពីមុខ, ចំពោះមុខ, នៅមុខ, ឯមុខ ឯអាយ, ខាងអាយ, ខាងនាយ, ឯនាយ... ។

## និបាតប្រាប់សេចក្តីប្រៀបប្រដូច

ដូច, ដូចជា បីដូច, ហាក់ដូច, ប្រដូច, ប្រហែលដូច, យ៉ាងណា, យ៉ាងណាមិញ, ដូចម្តេចមិញ, យ៉ាងនេះ, យ៉ាងនោះ, ដូច្នេះ, ដូច្នោះ ។

## និបាតប្រាប់ប្រការ

ម្តេច ដូចម្តេច, ដោយប្រការដូចម្តេច, ដោយប្រការយ៉ាងណា, ដោយប្រការយ៉ាងនោះ, ដោយប្រការដូច្នោះ... ។

## និបាតប្រាប់សេចក្តីហាមឃាត់

កុំ, ពុំ, មិន, ឥត, ខាន, ពិត មែន, តែប៉ុណ្ណោះ, គ្រាន់តែ, មិនមែន, មែនពិត, វៀរលែង, វៀរលែងតែ លើកលែងតែ, កុំឡើយ, ល្មមហើយ, ណ្ហើយ... ។

## និបាតប្រាប់សេចក្ដីតាមឮ

ឮថា, បានឮថា, ឮដំណឹងថា, មានដំណាលថា, មានសេចក្ដីដំណាលថា ... ។

## និបាតប្រាប់សេចក្ដីជញ្ជឹងប្រមើល, ស្មាន

បើ, បើជា, ប្រសិនបើ, ទោះបី, ទោះយោបី, ល្គឹកតែ, បើដូច្នោះ មានតែ, ធ្វើដូចម្ដេចអេះ ... ។

## និបាតប្រាប់សេចក្ដីសួរដណ្ដឹង

ឬ, ឬអ្វី, ឬទេ, ដូចម្ដេច, ដូចម្ដេចហ៎, ដែរឬ, ទេដឹង, យ៉ាងដូចម្ដេច, យ៉ាងណា, ដូចម្ដេចខ្លះ ។

## និបាតប្រាប់សេចក្ដីឆ្លើយទទួល

អឺ, បាទ, ព្រះបាទ, ព្រះបាទម្ចាស់, ករុណា, ព្រះករុណាពិសេស, ចះ, ចាះ, ពរម្ចាស់, ចំរើនពរ, ថ្វាយព្រះពរ ... ។

## និបាតប្រាប់សេចក្ដីតឿន

ហ៎, ឆាប់ៗ, ដូចជាតឿន ... ។

## និបាតប្រាប់សេចក្ដីច្រើនយ៉ាង

ក៏. ឯ. ផ្សិត. ក្ដី. ផង. ខ្លះ. អើក៏, ពីព្រោះ ក៏ដោយ. ក៏បាន. មួយវិញទៀត. ចំណែកខាង. ប៉ុន្តែ. ប៉ុន្តែថា. ក្រែង ក្រែងលោ. ថ្វីបើ ... ។

## និបាតប្រាប់សេចក្ដីគ្រាន់តែបំពេញបទ

ទទេ. ទៀតវិញ. ដោយពិត. ហ្វឹយៗ. ញឹកញយ. ផាក់លាក់. ពីចម្ងាយ. ក៏មែនហើយ. សូម្បី. តិចតួច. ចាប់ដើម តាំងពី. ពីដូច. ម្ដង. មួយគ្រា. ញើបៗ. ចួម. សំរៀម. សន្សឹម. តិចៗ. ជាមួយ. មួយអន្លើ ៗ

## និបាតប្រាប់សេចក្ដី (ជាអាលបនៈ)

សម្រាប់អ្នកគ្មានតេជៈនិយាយទៅរកអ្នកមានតេជៈ ឬអ្នកមានតេជៈនិយាយទៅរកអ្នកគ្មានតេជៈ

សូមព្រះតេជៈ, សូមព្រះតេជៈដ៏កល់លើត្បូង, សូមទ្រង់មេត្តាប្រោស, សូមទានមេត្តាប្រោស, ទានប្រោស បពិត្រព្រះអង្គ. បពិត្រព្រះករុណា. បពិត្រលោកដ៏ចំរើន, នែនាយ, នែចៅ, នែព្រះសង្ឃ, រឺ, រឺយ, នែអ្នកដ៏មានអាយុ នែអ្នកដ៏ចំរើន. (នែអា. នែអាចង្រៃ. នែហង, នែមេចង្រៃ)... ។

## ឧទានសព្ទ

(១៩) ពាក្យដែលត្រាប់នូវសំឡេង បញ្ចេញឡើងព្រោះអាក្រក់ខ្លះ ល្អខ្លះ សេចក្ដីស្លុតរន្ធត់ញាប់ញ័រខ្លះ ជាសំឡេងដែលមិនមែនជាភាសាខ្លះ ហៅថា "ឧទានសព្ទ" បានដល់ពាក្យថា អ៊ូយ!. អ៊ា! ប៉កៗ. ប៉ុងៗ. អាបៗ. ចេបៗ. ហេៗ. កឹងៗ. ទូងៗ, គ្រាំងៗ, ខ្ញុកៗ, យី!, យីអើ!, ឱ!. ពុទ្ធោ!. អុញ្ញន!... ជាដើម ។

## បរិវារសព្ទ

(៦០) មានពាក្យខ្លះឥតសព្ទប្រែ សម្រាប់តែបន្ថែមសំដី ពាក្យទាំងនោះហៅថាបរិវារសព្ទ បរិវារសព្ទនេះតែងភ្ជាប់នឹងនាមឬនឹងគុណនាម មានលំនាំដូចអតិរេកសគុណនាម ឧ. មនុស្សម្នា, សត្វពន្ទាត់. នំនែក, ស្គុសស្គាយ. ក្មេងក្មាត់. ចានក្បាន. ផ្ទះសម្បែង. ប្រអប់ប្រអូង. ស្វស្វុក, បំណីបំណុក, ដំណាំដំណោប, ក្មេងក្មាង, ឆ្នាំសង្ក្រូវ. ព្រៃផ្សៃ. ស្មៅស្រៅ. ម៉្ទេះម៉្ទា. អីវ៉ែអីវ៉ាន់. ឥឡូវឥឡា. បន្ទុបង្ការ. គោអំពែ. សេះអំពែះ. ផ្អឹង ផ្អែង. យំយែក. រយីរយ៉ៃ. រយីករយាក. រំយីករំយាក. រំដេករំដាក...

ជាដើម ។

## ឯកសព្ទនានាវចនៈ

(៦១) ពាក្យដែលមានស្នូរសំឡេងកានឮដូចគ្នា តែអក្សរតួប្រកបខាងចុងនឹងន័យរបស់ពាក្យផ្សេងៗ គ្នាហៅថាឯកសព្ទនានាវចនៈដូចឧទាហរណ៍ថា:

អ - ប៊ីអ, ផ្ទុំប៊ីអ, ប៉ាយអ.

អរ - អ្នកឯងរៀនបានច្រើន ខ្ញុំអរណាស់

អក - សត្វអក, កើតទុក្ខធំយំប្រះប្រាណដូចជាអក

អក៌ អ្នកមិនធ្វើការអ្វី, អ្នកព្រះអក៌ធីតាធិរម្យ

អគ្គា - អគ្គ, រូបកាយ, អវយវៈ

អង្គារ - ជ្បូង. ព្រះអង្គារ ថ្ងៃអង្គារ

អា - អាហ្នឹង. អាណុប, អានាង. អានេះ. អាចោរខូច

អារ - អារឈើ. ខ្ញុំមិនបានអារកាត់សេចក្ដីនេះទេ

វត្ត - មនុស្សមានវត្តល្អ. លោកសង្ឃគង់នៅក្នុងវត្ត

វត្សរ៍ - វត្សរ៍, ឆ្នាំ, សតវត្សរ៍, (មួយខួបរយឆ្នាំ) បៀវត្សរ៍ប្រាក់រង្វាន់ឆ្នាំ

វ័តិ របង. ព្រះរាជវ័តិ

វង បៀតបៀន. សម្លាប់, ក្របីវង;

វាត់ - វាត់សន្ទូច, វាត់ដោយរំពាត់, អន្ទាក់វាត់

អប្ឋាវ័ទ - គំនាប់, គោរព. ការគំនាប់. ធ្វើអប្ឋាវ័ទ

វិវដ្ដ - ការវិលត្រឡប់, ការត្រឡប់ធ្វើជាថ្មីទៀត

វិវឌ្ឍន៍ សេចក្ដីចំរើន, ការលូតលាស់, ដំណើរដុះដាល

វា - កូនខ្ញុំវាឈើ ការុងវាគួបបែកអង្ករមិនអស់

វារ - កូនតូចទើបនឹងចេះវារ. មូវារតាមជន្ទល់. ស្រមោចវារស្ការ

ស្នើ - សួរឲ្យដឹងសិន. ប្រឹក្សាមុនសិន. ទូលស្នើ. ស្នើការ

ស្នើរ - ស្រទាប់. ស្នើរក្រដាស, មួប្រាំស្នើរ, វគ្គស្នើរ

ឥត - ឥតដឹង, ឥតបានញុ, ឥតដើមទុន

ឥដ្ឋ - ដុះឥដ្ឋ. ឥដ្ឋក្រមាល. ឡឥដ្ឋ. ដាន់ឥដ្ឋ. បោះឥដ្ឋ. ប៉ុណ្ណោះ

ជាដើមជាតួយ៉ាង ៗ

## វេវចនៈ

(២២) ពាក្យដែលប្រើផ្លាស់ប្តូរគ្នាឬជំនួសគ្នាបានគឺពាក្យដែលមានសូរសំនៀងខុសគ្នា តែមានសេចក្តីត្រូវគ្នាឬស្រៀងគ្នា ដូចជា: ពេស្យា. វេសិយា. វេសី, នគរសោភិនី. លញ្ជិកា. រូបជីវិនី រូបជីវា. រូបូបជីវិនី, វណ្ណទាសី, គណិកា, "សំផឹង. ស្រីពឹងពាង ស្រីបន. ស្រីពេនវែង, ស្រីផ្កាមាស", ពាក្យទាំងអស់នេះបានសេចក្តីដូចគ្នា ប្រើពាក្យណាមួយក៏បាន តាមសមគួរដល់ការលៃលក, ហៅថា វេវចនៈ ។

## សទិសសព្ទ

(២៣) សព្ទដែលមានសេចក្តីលាំគ្នា. ស្រដៀងគ្នា. ដែលដូចគ្នា. ត្រូវគ្នា. ប្រហែលគ្នា ដូចជា: ឧត្តម. ខ្ពង់ខ្ពស់. ថ្លៃថ្នូ. ប្រសើរជា សទិសសព្ទ ប្រើជំនួសគ្នាបាន ។

## អញ្ញត្រសព្ទ

(២៤) សព្ទដោយឡែក គឺពាក្យខ្លះដែលសរសេរខុសពីបែបប្រើអក្សរខុសពីសំឡេងនិយាយ ដើម្បីរក្សាបែបដើមឲ្យគង់នៅដូចជា: នេះ, នោះ, ស្តេច. សម្តេច. ស្រេច. សម្រេច. អ្នក: អញ. ហោង (មានសំឡេងជា: និះ. នុះ. ស្តាច់. សំដាច់. ស្រាច់. សំរាច់. នាក់, អាញ់. អ្ហង)! ហៅថាអញ្ញត្រសព្ទ ។

## បុព្វបទ

(២៩) និបាតសព្ទឬអក្សរដែលភ្ជាប់ពីខាងដើមនៃសព្ទឯទៀតជាជំនួយសព្ទនុះឲ្យមានសេចក្ដីប្រាកដដោយឡែក ឬបំបែរសេចក្ដីឲ្យឃ្លាតផ្សេងពីប្រក្រតីដើម ហៅថាបុព្វបទ ។ ភាសាខ្មែរយើងច្រើនប្រើតួអក្សរជាបុព្វបទ, ប្រើមួយតួក៏មាន ពីរតួក៏មាន ដូចជា: ទាស់ទែង, ទ្រែតទ្រោត. ដាក់អក្សរ ទ (បុព្វបទ) ថែមមកជា: ទទាស់ទទែង. ទទ្រែតទទ្រោត ។ ខូច. ឈប់. ដុះ. ដូរ, ពោល ដាក់អក្សរ ប-ង. ប-ញ. ប-ណ. ប-ន. ប-ម បុំ (បុព្វបទ) ថែមមកជា: បង្ខូច. បញ្ឈប់. បណ្ដុះ បន្ដូរ. បម្ពោល. បុំពោល; បុព្វបទ ទាំងនេះបំបែរសេចក្ដីរបស់សព្ទឲ្យឃ្លាតឡែកពីប្រក្រតី... ។

ភិក្ខុមហា ពេជ្រ-ម៉ាង

(មានត)

# អក្សរអង្គុលីលេខ

(តពីសៀវភៅលេខ ៧–៨–៩–ឆ្នាំ ១៩៥២)

---

## ៨– ព្យាង្គ

អក្សរមួយតួ ឬអក្សរច្រើនតួ ដែលអានចេញសម្លេងបានមួយម៉ាត់ៗ=(សង្កត់ពាក្យ) ហៅថាព្យាង្គ ។

ពាក្យដូចជា "ក, កេង, ចាស់, ទៅ, ឯ" ជាដើម ហៅថាពាក្យមួយព្យាង្គ ។

– កសាង, លំនៅ, ប្រមាណ, ចំណាយ, ចំណាស់ ជាដើម ហៅថាពាក្យពីរព្យាង្គ ។

– "ចង្អុលដៃ, ដៃវែណង, អនុញ្ញាត, កម្មករ" ជាដើម ហៅថាពាក្យបីព្យាង្គ ។

– "តតឹងតតាង, វែតករគោក, ទោសានុទោស, ករណីយកិច្ច," ជាដើម ហៅថា ពាក្យច្រើនព្យាង្គ ។

ព្យាង្គនេះ ជាគោលការណ៍មួយសំខាន់ សំរាប់កុំឲ្យសរសេរតំណពាក្យខុសទើបអានពាក្យខុស ។

តាមរបៀបអក្សរអង្គុលីលេខនេះ ពាក្យមួយៗ ត្រូវសរសេរដាច់ពីគ្នា ទោះជាពាក្យមួយព្យាង្គក្ដី ពាក្យពីរព្យាង្គក្ដី ពាក្យបីព្យាង្គក្ដី ពាក្យច្រើនព្យាង្គក្ដី ។

- ពាក្យមួយព្យាង្គ ជាការងាយសរសេរ ព្រោះមានដំណើរមិនសូវប្រទាំទឹងគោលការណ៍ដទៃ ដូចពាក្យ " ខ្ចី ទឹង ខំ ជរៃ ចុំ មាត់ " ប៉ុណ្ណះជាដើម ។ ឃើញមានទំនាស់ខ្លះចំពោះពាក្យដូច " កាយ , ជាន , ធាន , សាម " ជាដើម តាមសូរដែលលាន់ឮឡើង គួរតែប្រើរស្សសញ្ញា បុស្សគ៌ ( ់ ) ដាក់នៅលើស្រៈ ( ា ) ប៉ុន្តែ មិនឲ្យប្រើដូច្នេះទេ ព្រោះថាជាពាក្យមកពីបាលី សំស្ក្រឹតយើងមុន ក៏មិនឲ្យសរសេរដាក់រស្សសញ្ញាបុស្សគ៌ដែរ ។

- ពាក្យតាំងពីពីរព្យាង្គឡើងទៅ មានពាក្យខ្លះនាំឲ្យមានប្រទាំខ្ទបសេចក្ដី :-

១ - ប្រទាំត្រង់គោលការណ៍បង្គាប់ឲ្យប្រើ រស្សសញ្ញាបុស្សគ៌ ( ់ ) ដូចពាក្យ " កាញ្ដៃ , កាណ្ដឹង បាង្គាប់ , សាម្ងាត់ " ជាដើម ទឹងប្រទាំថាព្យាង្គទី ១ ត្រូវសរសេរដាក់រស្សសញ្ញា បុស្សគ៌ពីលើស្រៈ ( ា ) ព្រោះថាបើមិនដាក់អាចអានបានថា " កញ - ដៃ, កណ - ដឹង, បង - គាប, សម ងាត់ " ។ ពាក្យបែបនេះមិនត្រូវប្រើដាក់រស្សសញ្ញា បុស្សគ៌ជាដាច់ខាត ព្រោះមានព្យញ្ជនៈសរសេរជើងភ្ជាប់នៅនោះ ទុកជាផ្ចិត

បុគ្គលម្រួត ជាគ្រឿងសំរាប់ឲ្យព្យាង្គទី ១ មានសម្លេងខ្ទើសាប់ហើយ គឺត្រូវសរសេរដូចឧទាហរណ៍ ដែលពោលហើយខាងលើ ។

២ – ប្រយ័ត្នគន់គោលការណ៍ផ្ដើម បុគ្គលម្រួត ដូចពាក្យ “– **សស្រេសស្រាវ , រីកក្រាយ , ង៉ិកង៉ក់ , ង៉េកង៉ោក ចចិកចចុក ”** ជាដើមអាចទឹងអានថា “ស–ស្រេវ, រី-ក្រាយ, ង៉ិ-ក្ង៉ក់, ង៉េ-ក្ង៉ោក, ចចិ-ក្ចុក” ដូច្នេះក៏បានជាហេតុនាំឲ្យខូចសេចក្ដី ព្រោះវិធីផ្ដើមបានសំដែងហើយថា តួព្យញ្ជនៈមួយគ្មានស្រៈ ហើយដាក់តួព្យញ្ជនៈមួយទៀតកៀកពីខាងមុខ ឬខាងស្ដាំ កំណត់ទុកថាជាផ្ដើម ។ បើយ៉ាងនេះ តើទឹងត្រូវសរសេរដូចម្ដេច ?– ដើម្បីកុំឲ្យមានការភាន់ច្រឡំដូច្នេះ គួរប្រើសហសញ្ញា ( – ) ដែលជាគំនូសខ្វី ១ គូសបន្ទាត់ព្យញ្ជនៈ ដែលនាំឲ្យច្រឡំទឹងផ្ដើម ( – ) នោះ ដូចសរសេរតទៅនេះ– “ **សស្រេ- សស្រាវ , រីក-ក្រាយ , ង៉ិក-ង៉ក់ , ង៉េក-ង៉ោក , ចចិក-ចចុក ”**

ដូច្នេះតើពាក្យតាំងពីពីរព្យាង្គឡើងទៅ ក្នុងព្យាង្គមួយៗ ត្រូវប្រើគំនូសមួយៗទៅឬ? មិនមែនទេ, ត្រូវប្រើគំនូសតែត្រង់ព្យាង្គណា ដែលនាំឲ្យអានច្រឡំទឹងវិធីផ្ដើម ដែលជាហេតុនាំឲ្យខូចសេចក្ដី ។ **ករណីនេះ**

គឺពោលទៅតាមសេចក្ដីសន្និដ្ឋាន ដែលត្រូវការប្រញាប់ នឹងប្រើអក្សរអង្គុលីលេខ ។ បើពោលយោលទៅអនាគតកាល សំរេចនឹងអ្នកប្រាជ្ញដែលយកអក្សរនេះទៅប្រើជាពាក្យជាក់ក្នុងវចនានុក្រម កាលបើមានកំណត់យ៉ាងណា កំណត់នោះទើបប្រាកដលែងរើរុះបាន ។

ពាក្យខ្មែរយើង មានពាក្យមួយព្យាង្គខ្លះប្រើតែឯងក៏បាន ប្រើរួមជាមួយនឹងពាក្យដទៃទៀតក៏បាន ជួនណាប្រមូលពាក្យមួយព្យាង្គពីរបីរួមបញ្ចូលគ្នាទៅជាពាក្យមួយបានសេចក្ដីតែមួយបែបទៅក៏មាន ។ ដូច្នេះឃើញថាអ្នកសរសេរនឹងពិបាកសរសេរឲ្យបានត្រឹមត្រូវជាទីបំផុត ។ ត្រង់នេះ សូមបញ្ជាក់ថា ត្រូវមើលវចនានុក្រមខ្មែរយើង មេពាក្យទាំងប៉ុន្មាន ដែលរៀបរៀងជាលំដាប់ ត្រូវទុកជាពាក្យមួយ ៗ ។

---

## ៩ — សញ្ញា

គំនូសជាគ្រឿងសម្គាល់ ឬជាគ្រឿងកំណត់នូវប្រភេទនៃរបៀបប្រើអក្សរ ក្នុងទីនេះ ហៅថាសញ្ញា ។

(បានជាឲ្យឈ្មោះថាសញ្ញាដូច្នេះ ដោយសេចក្ដីយល់ឃើញថាជាគំនូសមួយផ្នែកដែលមិនបានប្រើផ្ទាល់ជាមួយតួអក្សរ ។ ប៉ុន្តែគប្បីដឹងថាសញ្ញានេះជាសម្មតិនាមមួយយ៉ាងតូចនៅក្នុងវណ្ណយុត្តិ ព្រោះជាគ្រឿងសម្គាល់ដែលដកចេញមកពីវណ្ណយុត្តិ ) ។

សញ្ញាសម្រាប់ប្រើក្នុងរបៀបអក្សរនេះគឺ:

| | |
|---|---|
| - | សហសញ្ញា ( គ្រឿងសំគាល់ថាជាមួយគ្នា ) |
| ៗ | លេខទោ, អាមេណ្ឌិតសញ្ញា |
| – | វដ្ដលេខា |
| ( ) | វង់ក្រចក, នខសញ្ញា |
| % | សតភាគ |
| = | សមភាគ |
| × | សញ្ញាគុណ |
| ! | អច្ឆរិយសញ្ញា, វិម្ហសញ្ញា, សង្វេគសញ្ញា |
| : | ទ្វេភាគ, សញ្ញាចែក |
| , | ចុល្លភាគ |
| ; | មហព្ភាគ |
| ? | បុច្ឆនសញ្ញា |
| ។ | ខណ្ឌ, ល្បះ |
| / | ភាគសញ្ញា |
| + (១) | ភាគបាទ, ជើងក្អែក; សញ្ញាបូក, នឹង |
| ៈ | វិសជ្ជនីយ បុរះមុខ |
| . | ចំណុច |

(១) កាលបើប្រើសាភាគបាទ ដាក់លើតួអក្សរផ្ទាល់ គប្បីសម្គាល់ថាជាវណ្ណយុត្តិពេញទីទៅវិញ ។

សញ្ញាទាំងអស់នេះ មានសញ្ញាខ្លះមិនទាន់មានឈ្មោះប្រាកដ តែបានកំណត់ឈ្មោះឱ្យមានឡើង ដោយសម្គាល់យកដំណើរដែលបានប្រើហើយក្នុងរបៀបអក្សរយើងមុនមកឱ្យឈ្មោះ ដើម្បីទុកជាទិដ្ឋានុគតិ ។

វិធីប្រើសញ្ញាទាំងឡាយនេះ មិនបាច់ពន្យល់ក្នុងទីនេះទៀតទេ ព្រោះមានដំណើរត្រូវប្រើដូចរបៀបអក្សរយើងមុនដែរ ។

---

## ១០ — សេចក្ដីផ្សេង ៗ

បានអានមកអស់ ៩ មូលបទហើយ ឃើញថាស្គាល់អក្សរអង្គុលីលេខ ព្រមទាំងរបៀបត្រូវប្រើដោយសព្វគ្រប់ អ្នកអានគ្រាន់តែនៅមិនទាន់បានប្រទះភ្នែកឃើញនូវការសរសេរ ឱ្យសុទ្ធតែអក្សរអង្គុលីលេខប៉ុណ្ណោះ ។ ដូច្នេះនឹងសរសេរគោលការណ៍ខ្លះជាអក្សរនេះសុទ្ធ ដើម្បីឱ្យអ្នកអានបានប្រទះភ្នែក ដូចតទៅនេះ :–

ក្នុង របៀប អក្សរ នេះ របាប់(៤) មិន
មាន បុរី ១៩ ពា-កប ឯបច ជា ក្នុង របៀប
អក្សរ ប្រើ មាន ស្រៈ_ស្រៈ "ធម៌, ពណ៌, គតិ
ពត៌មាន, អាជីវ" ជា ដើម អាច នឹង បុរី តប
អក្សរ " រ " បាន ពារៈ តប " រ " កាល បើ
គមាន ស្រះ ក៏ មាន សបរ សំរេង តាខម ត

ฃวร ฝบฉ คสา นะง รฯบาจ ฝฮง สโก บาน
กฯํ ผวฺ่ค บุรไ มฯก ทใบ นะ
คส บุรี สาร-สอร รฮใ คพ มะน มะน
สฯร-สอร ฝ่าก ตะ สไ คพ กบาฯอฝวนฯ
ฝบฉ รฯบาจ จอ ฯ ฝบฉนอะ หเจาบารงร์ผ
ฉาไ สไ นอะ ครบร สฯร-สอร ฝา "ธฯรม,
ตฯรผ,, คฯรก, ตฯรคฯยาน, หารธ" ฝบฉนอะ
รัะฃ ฯ

---

บเคฯสฯตะนจเ บาน สฯํฝฮไ ทใบ ฝา
สรอฉ ฉาบาน บ่ฯไกใค สรฯ ‹ ฯ › บุรี
ฝพส บุเนคส ฝ่ส มฯก คนเไ กพค
สฯอฉา บุรฯทอส ฝา หนฯก หาน นะไ มาน
ฉไ่ส ฉาหคค์เ ฝบฉ มฝอฉ บาน ฝา มาน
รบ่บ ฉํ่ผเฉ ตะร ฝบฉ รบบ บเคฯสฯตะนจเ
คสมาน สมะ ฝสอไ สํร่าบ บรี คนเไ
รฯบอบ หฯคสร นอะ จอค ฯ สฯอฉา
ผสส มาน สมะ ฉา จรอภาค นอะ มะน มะน
ผ่าก มฯก หรบ บุรี ฝบฉ ฝา บเคฯสฯตะนจเ
จค คะ หรบ บรี ฝา อฯผะาสฯอฉา สํร่าบ

บุร่บ ผอบ-กผะ ครบรร่บ บ่อนพร คๆ ๑๕
๑ฮิก ระ๓บ ผอบ-กผะ บๆยผ่า ร๓บ
รร่ส คๆ ๑๕ ๑ฮิก ฯ

---

รบบ ผอะ ผรผ ครบริ บุรริ ผา ผๆไฮยกา ร่เร
ยำนพร กรเง ราบฮิบ รๆกผรร ระ รรก
ษาร กร บุรสี ๑อ รร์ บุรรี คาย รบบ ผอะ ย่าส
คะ ๑.๒.๓-๔-๕-๖.๗.๘-๙.๐-ผๆคลึง ฯ

---

การ รร่ะ ก็ ผริบ คร์ บะร ษ่าร ยรรก บะร
ษ่าร ผิำ ๑ร์ ผา ๑ๆษผ่าบ ผเยย ครี ตะบาก
๑ำง รร่ส ผบย ผา การ บุรรีรๆกผร ยษะ ระะ
ระง ตะบาก คำงตะ บไผ ผไง ๑ร์ บุเรคร
ผะ อำ บุรรง บุรรี ผริบ บาร ผา ๑ๆษผ่าบ ๑ร์
ก็ ผร่าบ คร ผาบ ผรพผ ๑ร์ รรย ฯ

---

รระผะ รฮิบ รๆกผรร ยษะ ระะ ผ่าก ผำร่าบ
บุรร รรๆห คเผะผอ ษาร ผๆผษาร ผบย
การ่าง ผรผ บุรๆอะค อาง กริบ บำผเค ระะ



បញ្ហា

# ប្រហែលជាលោក-អ្នកភ្លេចហើយឬ?

---

១ – ពីថ្ងៃខែឆ្នាំប៉ុន្មាន ដែលសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត និមន្តទៅសំដែងសន្និសីទអំពីរឿងសមាជពុទ្ធិកសមាគមពិភពលោក នៅវត្តលង្កា ភ្នំពេញ ?

២ – ពីថ្ងៃខែឆ្នាំប៉ុន្មាន ដែលសម្តេចព្រះបិតុច្ឆាស៊ីសោភ័ណទ្រង់លាលែងពីព្រះតំណែងជាអធិបតីនីនៃសមាគមខេមរៈសហជីវិនី ?

៣ – ពីថ្ងៃខែឆ្នាំណា ដែលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទ្រង់ព្រះរាជទានងារនាងប៉ុសប្អូនអ្នកម្នាងប៉ុនណាក (ប៉ុសនាគ) ជាព្រះនាងចមផល ទិព្វសុគាបន្ធ ?

៤ – ព្រះរាជបុត្រីរបស់អ្នកម្នាងប៉ុន - ណាក ទ្រង់ព្រះនាមជាអ្វី ?

៥ – វត្តមហានិកាយនឹងធម្មយុត្តិកក្នុងកម្ពុជរដ្ឋមានប៉ុន្មាន ?

៦ – តើព្រះសិរីទេពកុញ្ញាព្រះទីទាំងគជសារព្រះករុណាជាអម្ចាស់ជីវិតលើត្បូងរបស់យើងទ្រង់ព្រះនាមអ្វី ?

៧ – តើពុទ្ធសាសនិកជនមានប៉ុន្មាននាក់ក្នុងពិភពលោក ?

៨ – តើភាសាអ្វីដែលមានមកពីបឋមសម័យចាស់ជាងគេ ?

៩ – សិស្សដែលបានចូលរៀននៅសាលាទីក្រុងភ្នំពេញក្នុងឆ្នាំ- ១៩៥១ - ៥២ មានប៉ុន្មាននាក់ ?

១០ – ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមទ្រង់ព្រះទិវង្គតពីថ្ងៃ ខែ ឆ្នាំណា ?

# វិសជ្ជនា

## ប្រហែលជាអស់លោក-អ្នកភ្លេចហើយឬ?

១– ថ្ងៃទី៥សីហា ១៩៥០ ។

២– ថ្ងៃទី៤មេសា ១៩៥០ ។

៣–ថ្ងៃ ១ ៗ ១២ ឆ្នាំឆ្លូវត្រីស័ក ព.ស. ២·៤០៨. ច.ស. ១២២៧ គ.ស. ១.៨៦៨ ។

៤–ព្រះរាជបុត្ររបស់អ្នកម្នាង ប៊ុន-ណាក ទឹងព្រះបាទនរោត្តម ទ្រង់ព្រះនាមថា ព្រះបាទយុគន្ធរ ។

៥ - វត្តមហានិកាយមាន២·៦៦៣, វត្តធម្មយុត្តិមាន ១០១ ។

៦ – ព្រះសិរីទេពកុញ្ញារបវរសេតវង្សប្រមពង្សឯករតន៍វិវឌ្ឍន៍មង្គល ពង្សុត្តពតលវិមលគតេជន្ម នរេន្ទ្រវាហនៈ វរកម្ពុជវរង្គ តិរេកឯកហត្ថិពជធានី បូររម្យ ឧត្តមសុស្តិ៍ ។

៧–ពុទ្ធសាសនិកជនមាន៥៥០.០០០,០០០នាក់ក្នុងពិភពលោក

៨– អរិយកភាសា ។

៩– ៦.១៣០ នាក់ ។

១០– ថ្ងៃទី ២៤មេសា១៩០៤ ពេលម៉ោង ១៧ ។

# រឿងព្រេង

## ត្រកួននឹងកំពេត

នាកាលព្រះសុរិយាជ្រៀងជ្រេរ បែរទន្ទាប បំបាំងខ្លួន បញ្ចេញនូវរស្មីយ៉ាងស្រទន់ តាមចន្លោះនៃពពករសាត់មកកាន់ទិសឧត្តរ ដោយកំឡាំងនៃពាយោផ្សាយជំនោរចេញពីទិសទក្ខិណា ៗ ជុំពពកទាំងឡាយ មានសណ្ឋានប្លែក ៗ យ៉ាងអស្ចារ្យ មានសន្ទុះលឿនសន្សើម ៗ បន្ត ៗ គ្នា ជាហេតុនាំឲ្យសុរិយប្បភា ចិបញ្ចេញនូវរស្មីមានពណ៌ផ្សេង ៗ បញ្ចាំងបញ្ចាក់ដល់ទស្សនីយភាព នៃមនុស្សសត្វទាំងឡាយ ឲ្យមានសម្បជញ្ញៈថា ខ្លួនលោកនិងលោកអ្នកទាំងឡាយចូលទៅកាន់ទីសម្រាកហើយ គឺថាខ្លួនលោកជិតអស្តង្គតហើយ ៗ វេលានៃសាយណ្ហសម័យ ដែលមានសភាពដូច្នេះ អាចឲ្យយើងដឹងបានថា មានប្រាកដតែនៅក្នុងវស្សានរដូវ ៗ

ទីវាលមួយមេដែលធម្មជាតិបានក្រាលដេរដាសទៅដោយស្មៅ មានពណ៌ខៀវខ្ចី នៅជាចន្លោះនៃជួរកំភ្នួតប៉ី ជំលំអទៅដោយគុម្ពឬស្សី និងគុម្ពោតឈើទាំងឡាយ ដែលដុះឡើងខុកឲ្យមានចន្លោះផែនព្រះធរណី វាលទំនេរ ជារមណីយដ្ឋាននៃម្រឹគបក្សាទាំងឡាយ សព្វកាលវេលា ៗ

ទីនោះដីប្រដាប់ទៅដោយទ្រនាំងទឹកមួយ មានទឹកហូរខ្សែងដក់ទៅទាំងរដូវប្រាំងរដូវវស្សា ត្រង់ទីឱកាសមួយនៅជាចន្លោះ នៃគុម្ពឬស្សីនិង

គុម្ពោតឈើទាំងឡាយនោះ បើតាមយើងស្មាន ថាត្រពាំងទឹកនោះនៅចំកណ្ដាលទីវាលនោះឯង ។

នាកាលមហាមេឃបង្អុរទឹកភ្លៀង ចំនួនជា ៤-៥ មេ ក្នុងខាងដើម នៃវស្សានរដូវ បង្កជាតិនឹងគិណជាតិទាំងឡាយ មានត្រកួន, កញ្ឆែត, ព្រះក្រាបនឹងព្រះខ្លបជាដើម បានបញ្ចេញពន្លក ធ្វើខ្លួនយ៉ាងស្រស់ញញឹម បក់ត្រយលូតលាស់ តាមថាមភាពនៃខ្លួន ដោយអំណាចទឹករបស់មហាមេឃ បានស្រោចស្រប់ដោយទឹកថ្លាត្រជាក់ថ្មី ៗ នោះឯង ។ បង្កជាតិ គឺត្រកួននឹងកញ្ឆែតដែលមានគិណជាតិ គឺព្រះក្រាបនឹងព្រះខ្លបជួយផងនោះ នៅវេលាដែលបានទទួលទូរប្រិយកាលដ៏ថ្ងៃថ្លានេះ ក៏កើតមានសេចក្ដីលោភចង់ហួងហែងយកទីនោះតែម្នាក់ឯងរៀងខ្លួន បណ្ដាលទៅជាមានហេតុឈ្លោះទាស់ទែងខ្វែងគំនិតគ្នា អាងឥទ្ធិពលតែរៀងខ្លួន មកអំពីការជែករកផ្លូវទីពឹង ។

ត្រកួន.- យើងត្រូវតែទីពឹងខ្លួន មិនត្រូវទីពឹងអ្នកដទៃ ដោយហេតុខ្លួនយើងគ្មានគ្រឿងជាទីពឹង ល្មមឲ្យគេទីពឹងបានផងនោះសោះឡើយ ។

កញ្ឆែត.- គ្មាននរណាមួយអាចទីពឹងតែខ្លួនឯងបានឡើយ ។ នៅក្នុងលោកនេះ បើមិនមានអ្នកទាំងឡាយដទៃជាទីពឹងទេ នរណាមួយក៏មិនអាចតាំងខ្លួនឲ្យនៅជាសុខបាន ដោយហេតុទីពឹងតែខ្លួនឯងនោះឡើយ ។

ត្រកួន.– អ្នកទាំងឡាយដទៃ ដែលថាត្រូវទុកជាទីពឹងនៃខ្លួននោះ ក៏ពិតមែនហើយ តែបើខ្លួនមិនមានគុណសម្បត្តិនិងសមត្ថភាព ឬគុណជាតិអ្វីមួយ ល្មមនឹងឲ្យអ្នកដទៃគេទីពឹងវិញផងបានទេ អ្នកទាំងឡាយដទៃ ដែលខ្លួនទុកជាជាទីពឹងនៃខ្លួននោះជាអសារបង់ ។

កញ្ឆែត.– ការដែលយើងធ្វើអ្នកទាំងឡាយដទៃ ឲ្យជាទីពឹងនៃខ្លួនបាននោះ គ្រាន់តែយើងចេះធ្វើខ្លួនឲ្យគេអាណិត ឲ្យគេស្រឡាញ់ទៅ មុខជាគេនឹងស្មគ្រចិត្តជួយយើងណាស់ទៅហើយ ចុះបើគ្មានកិរិយាទាំងពីរនេះទេ នោះធ្វើម្តេចគេនឹងមានទឹកចិត្តជួយយើងបាន ។

ការជជែកគ្នា រកគោលទីពឹងរវាងត្រកួននិងកញ្ឆែកនេះ ជាទីសណ្តាប់នៃបក្ខជាតិ, តិណជាតិ និងមច្ឆជាតិទាំងឡាយយ៉ាងគុះគរ ដោយក្រៃលែង មានតែអណ្តើកមួយទេ ជាអ្នកកាន់ជើងខាងត្រកួន ឯអ្នកទាំងឡាយដទៃ គេកាន់ជើងខាងកញ្ឆែតទាំងអស់ ។ ទិដ្ឋិកម្មនេះបណ្តាលឡើងទៅជាជំលោះមួយយ៉ាងធំ ។

កញ្ឆែតប្រកាសឡើងថា បើឯងចង់ដឹងគំនិតឯងត្រូវ ឬគំនិតអញត្រូវ នោះគប្បីចាត់វិធានការពិសោធល្បងមើល ទើបឃើញការពិត ។

ត្រកួន.– វិធានការនោះ តើឯងនឹងចាត់របៀបណា?

កញ្ឆែត.– ចាត់តម្រូវទៅតាមគោលការណ៍ ដែលយើងបានពិភាក្សាគ្នានេះ ។

ត្រកួន.– ចុះបើបដិសេធការនេះ ទុកជាអសារបង់ត្រីមានេះទៅ តើបានឬទេ? ។

កញ្ចែត.– មិនបានទេ ព្រោះការនេះនាំឲ្យកាន់ប្រឡំគំនិតអ្នកស្លាប់ខ្លាំងណាស់ បើមិនបានធ្វើពិសោធមើលឲ្យដឹងខុសត្រូវ នោះនឹងនាំឲ្យមានការជជែកគ្នា រកទីបំផុតគ្មាន ។

ត្រកួន.– ការធ្វើពិសោធនេះ នឹងធ្វើដោយបញ្ញាឬដោយឥទ្ធិពល?

កញ្ចែត.– ធ្វើដោយការទីពឹង ដែលអញយល់ឃើញនឹងដោយការទីពឹងដែលឯងយល់ឃើញ ។

ត្រកួន.– បើធ្វើពិសោធដោយពិធីនេះ ខ្ញុំសុំទទួលចាញ់តែម្តងទៅចុះ មិនបាច់ធ្វើទេ ។

កញ្ចែត.– បើឯងសុខចិត្តចាញ់ ត្រូវតែថយពីទីនេះចេញ ទើបអញព្រម, បើមិនថយទេ នឹងឲ្យអញខានធ្វើពិសោធមិនបាន ។

ត្រកួន.– ខ្ញុំមិនថយទេ ព្រោះទីនេះជាកំណែលរបស់ខ្ញុំតាំងពីដូនតាមក ។

កញ្ចែត.– ចុះឯងថាទីនេះ ជាកំណែលរបស់ឯងតាំងពីដូនតាមក តើឯងយកអ្វីជាទីតាំងឲ្យឃើញជាក់ស្តែង ។

ត្រកួន.– ដូនតាខ្ញុំបានមកតាំងទីនៅក្នុងត្រង់នេះ តាំងតែអំពីកាលដែលមានយប់នឹងថ្ងៃជាដំបូង ។

កញ្ចែត — បើដូច្នេះ ឃើញថាដូនតាអាឯងមកតាំងទីត្រង់នេះ ក្រោយដូនតាអញទេ ។ ដូនតាអញមកតាំងទីត្រង់នេះ តាំងពីមិនទាន់មានយប់នឹងថ្ងៃម្ល៉េះ ។

ត្រកួន.— ឱ! លោកអើយ! គ្មានអ្នកកើតមុនយប់នឹងថ្ងៃនេះទៀតទេ ព្រោះពេលដែលភ្លឺគេហៅថាថ្ងៃ ពេលដែលងងឹតគេហៅថាយប់, បើលោកថា មានពេលមិនមែនជាងងឹត មិនមែនជាភ្លឺនេះទៅទៀត នោះខ្ញុំថាមិនមែនជាពាក្យពិត ។

កញ្ចែត.— អើ! បើឯងថាពាក្យអញមិនពិត ត្រូវតែប្រាំងគ្នាពិសោធមើល បើអញចាញ់ ទើបឯងថាពាក្យអញមិនពិត បើអញឈ្នះ ពាក្យអញទាំងប៉ុន្មាន សុទ្ធតែពិត ។ ចំណែកពាក្យឯងទាំងប៉ុន្មាន ឈ្មោះថាមិនពិត ។ កំហុសនៃការពោលពាក្យមិនពិតនេះ ត្រូវអញដាក់ទណ្ឌកម្ម រំលាយឯងចោលមិនឲ្យមាននៅទីនេះ ។

ត្រកួន.— ឱ! កញ្ចែត! ប្រើការរំលោភយកឈ្នះដោយអាងកំលាំងហើយតើ មើលទៅអញនឹងចៀសឲ្យផុតពីសេចក្តីរំលោភនេះមិនបានឡើយ ។ បើដូច្នេះ ត្រូវអញពិគ្រោះនឹងបងអណ្តើក ដែលជាមហាមិត្តរបស់អញមើល តើគេយល់យ៉ាងណា ។

លុះត្រកួនគិតដូច្នេះហើយ ក៏ស្រដីទៅកាន់អណ្តើកថា នែ! បងអណ្តើក! បើគេនៅតែចង់ប្រព្រឹត្តរំលោភលើយើងយកឈ្នះដូច្នេះ តើបងឯងគិតដូចម្តេច?

អណ្តើក.- ណ្ហើយប្អូន! កុំគិតច្រើន បើគេមិនព្រមបន្ធូរបន្ថយសេចក្តីរំលោភរបស់គេទេ យើងមុខជាគេចមិនរួចដែល ហេតុនេះ ត្រូវតែទ្រាំតស៊ូទៅចុះ ព្រោះសេចក្តីស្លាប់ដោយកិច្ចការពារនាទីរបស់យើងនេះ ទុកជាសេចក្តីស្លាប់ដ៏ប្រសើរ ។

ត្រកួន.- បើដូច្នេះ បងឯងមានមធ្យោបាយគ្រប់គ្រាន់នឹងការពារសត្រូវបានទេ?

អណ្តើក.- បងមានខ្លះដែរ, តែនឹងឆ្លើយប្រាប់ប្អូនឯងតែម្តងមិនបាន ព្រោះមិនដឹងជាគេនឹងប្រតិបត្តិការបំផ្លាញយើងបែបណានៅឡើយ ៗ ចាំគេចាត់ការមកសិន ទើបយើងបញ្ចេញនូវមធ្យោបាយរបស់យើងកំចាត់ទៅតាមទំនងនោះបាន សូមប្អូនកុំព្រួយ ។

ត្រកួនដោយបានស្តាប់ពាក្យអណ្តើកជាមិត្តនិយាយប្រាប់ដូច្នេះ ក៏ធូរស្រាកស្រាន់សេចក្តីតក់ស្លុតក្នុងចិត្ត ហើយនៅស្ងៀមលែងមានសំដីតបតទៅកកញ្ចែតទៀត ៗ ប្រឹងខំចាំតែការពារភ័យអន្តរាយ ដែលនឹងកើតមកអំពីពពួកកញ្ចែតតែម្យ៉ាង ។

ចំណែកកញ្ចែតមានគ្នាបីនាក់ ទាំងព្រះក្រាប ១ ព្រះខ្លុប ១ ផង បានដើរសំពះល្អងលោមអង្វរ បក, កំផ្លាក, ត្រកៀត, សារពយ នឹងខ្យង-ខ្ចៅ ឲ្យព្រមព្រៀងព្រួតដៃគ្នាជួយកំចាត់ត្រកួន ដោយសេចក្តីឃោសនាថាត្រកួននេះជាមច្ឆាទិដ្ឋិ នឹងបណ្តោយឲ្យនៅជាមួយនឹងពួកយើងទាំងអស់គ្នាជាសម្មាទិដ្ឋិមិនបាន ។

ដោយសេចក្ដីយល់ឃើញ នឹងសេចក្ដីឃោសនារបស់អ្នកតាំងប៉ី នោះ ពពួកបង្កជាតិនឹងខ្យង - ខ្មៅ បានមូលមតិគ្នាជាឯកច្ឆ័ន្ទថា ត្រូវវាយត្រកួនឲ្យខ្ចាត់ខ្ចាយចេញពីទីនោះ កុំឲ្យមានសេសសល់ឡើយ ក៏តាំងរៀបប្រជុំពួកពលឡើងភ្លាម ។

កញ្ចែតបានលើកទ័ពវាយត្រកួនមួយរំពេចឥតបង្អង់ឡើយ ដើម្បីឲ្យបានសំរេចតាមសេចក្ដីលោភរបស់ខ្លួន ។

ត្រកួនពិគ្រោះជាមួយនឹងអណ្ដើកថា សំឡាញ់អើយ! ឥឡូវនេះគេលើកទ័ពវាយកំចាត់យើងហើយ តើបងឯងគិតធ្វើដូចម្ដេច?

អណ្ដើក.— ប្អូនអើយ! កិច្ចការពារខ្លួននៅទីនេះ យើងមានកំលាំងទន់ខ្សោយណាស់ ដោយយើងមានគ្នាតែ ២ នាក់ ។ ប៉ុន្ដែយើងត្រូវវាយត្រឡប់ទៅវិញ ដើម្បីទប់ខ្លួនសិន ព្រោះយើងមានគ្នាតិចមិនងាយនឹងវាយយកជ័យជំនះក្នុងពេលនេះភ្លាមបានឡើយ តែសូមប្អូនឯងកុំភ្លេចនូវឧត្ដមគតិរបស់ខ្លួន ដែលយើងបានដៅទុកមកហើយនោះឲ្យសោះ ។

ត្រកួន.— ឧត្ដមគតិរបស់យើងមានតែមួយ គឺការទីពឹងខ្លួន សូមបងឯងដាស់សតិយើងផង ព្រោះប្អូនមានសេចក្ដីភិតភ័យណាស់ វង្វេងស្មារតីអស់ទៅហើយ ។

អណ្ដើក.– សូមប្អូនឯងប្រតិបត្តិខ្លួនឲ្យមានគោលជាទីពឹងដូច្នេះ :–

១.– ត្រូវចាក់ឫសឲ្យបានជ្រៅទៅក្នុងដី ដើម្បីឲ្យមានជីវិតរស់នៅជាយូរអង្វែង ;

២.– ត្រូវចំរើនលូតលាស់ត្រួយ និងបំបែកខ្នែងឲ្យយ៉ាងច្រើន ដើម្បីជាកំលាំងទប់ពួកបច្ចាមិត្ត កុំឲ្យលុកលុយមកបានដោយងាយ ;

៣.– ត្រូវបំប៉ោងខ្លួនឲ្យមានប្រហោង ហើយឲ្យមានសន្លាក់ថ្នាំងយ៉ាងច្រើន គ្រាន់នឹងដកដង្ហើម ហើយបណ្ដែតខ្លួនបានដោយងាយ ។

ត្រកួន.– ចុះចំណែកខាងខ្លួនបងឯង ត្រូវតាំងប្រតិបត្តិដូចម្ដេច ដើម្បីឲ្យមានទីពឹងមុតមាំដូចគ្នា ។

អណ្ដើក.– ខ្លួនបងបានប្រុងប្រៀបរួចហើយ តែនៅខ្វះត្រង់អាហារ និងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបានបរិបូណ៌ ។ បងសូមប្រស្រ័យជីវិតនឹងប្អូនឯងផង ចូរប្អូនឯងញ៉ាំងពលភាព នៃខ្លួនឲ្យប្រព្រឹត្តទៅដោយមាំមួន គ្រាន់បងនឹងផ្ញើជីវិតផង ។

ត្រកួន.– មិនអីទេបង! រឿងនេះប្អូនក្លីសេចក្ដីទៀងវិញហើយ ៖ ការដែលយើងនឹងកំចាត់បង់នូវសត្រូវបាន លុះត្រាតែខ្លួនយើងកំចាត់បង់នូវការទន់ខ្សោយរបស់យើងឲ្យបានជាមុនសិន ។

សេចក្ដីក្សាងនេះ បានញ៉ាំងត្រកួនឲ្យចាក់ឫសនៃខ្លួនចុះជ្រៅទៅក្នុងព្រះធរណី, ឲ្យបង្កើតជាថ្នាំងច្រើនពាន់ទៅតាមដងខ្លួន, បំប៉ោងខ្លួន

ឲ្យមានប្រហោងតាមចន្លោះនៃថ្នាំងទាំងឡាយនោះ នៅត្រង់ថ្នាំងនីមួយ ៗ បង្កើតជាសន្ទឹក ជាផ្កា នឹងជាខ្នែងតៗ ទៅទៀត ។

កាលដែលត្រកួនបានញុំាងខ្លួនឲ្យមានពលភាពដូច្នេះហើយ ក៏ក្លាយបកត្រឡប់ទៅកងទ័ពកញ្ជ្រោងវិញ ។

ពួកកញ្ជ្រោងរឹងរិតតែលើកទ័ពយ៉ាងសំបើម មកវាយលុកយកទឹកដែនរបស់ត្រកួន ៗ ត្រកួននឹងអណ្ដើកទាំង ២ នាក់ក៏បានវាយតស៊ូបកត្រឡប់ទៅវិញ ដោយពេញទំហឹង ។

ឯកងទ័ពខាងកញ្ជ្រោង ដែលមានកំផ្លោក, ត្រកៀត, សាវាយ, បក, កំពីងពួយ, ខ្យង, ខ្ចៅ នឹងព្រះក្រាប ព្រះខ្ចប ជាអគ្គបញ្ជាការ បានវាយប្រយុទ្ធនឹងត្រកួនដោយសេចក្ដីក្លាហានជាទីបំផុត បេះតែនាំគ្នាលុកចូលដកបទាល់តែពេញណែនតាន់តាប់រកចន្លោះគ្មាន ។

ចំណែកខាងត្រកួនក៏ខំប្រឹងវាយទប់មកវិញយ៉ាងអស្ចារ្យណាស់ដែរ តែមិនអាចនឹងទប់ទល់បានឡើយ ព្រោះខ្លួនមានគ្នាតិច ក៏ពិចារណានឹងអណ្ដើកថា ចុះបងឯងនឹងរិះរកមធ្យោបាយដូចម្ដេច តទៅទៀតបានទេ បើទ័ពគេចូលមកណែនតាន់តាប់ដូច្នេះទៅហើយ ?

អណ្ដើក .– មិនអីទេប្អូន! ទុកឲ្យបងជាអ្នកចាត់ការខាងផ្លូវក្រោម ៗ ចំណែកខាងប្អូនឯង បើទប់ទល់នឹងគេមិនឈ្នះទេ ត្រូវសុំចុះចាញ់គេសិនទៅចុះ ដើម្បីនឹងយកសុខមួយលើកសិន ។

ត្រកួន.— បងឯងមានប្រសាសន៍ដូច្នេះ ខ្ញុំមិនទាន់ចូលចិត្តផងទេ ព្រោះថាធម្មតាអ្នកចាញ់គេ មិនដែលបានទទួលសេចក្ដីសុខទេ សូម្បីគ្រាន់តែគេផ្ចាញ់ត្រឹមតែរូបកាយ ហើយយើងសុខចិត្តចាញ់ ក៏នៅតែមិនបានសុខ ចំណង់បើផ្ចាញ់ដើម្បីយកទីកន្លែងដូច្នេះ ធ្វើម្ដេចនឹងបានសុខ ហេតុនេះសូមបងឯងពិចារណាមើលតទៅទៀត កុំឲ្យថាខុសមកពីខ្ញុំ ។

អណ្ដើក.— ដែលបងថាឲ្យប្អូនឯងសុខចិត្តចាញ់យកសុខនេះ មកពីបងយល់ថា បើគេចង់ផ្ចាញ់យើងយកអំណាច យើងគ្រាន់តែប្រគល់អំណាចឲ្យគេទៅ នឹងបានសុខទៅហើយ បើគេផ្ចាញ់ដើម្បីភោគទ្រព្យ យើងគ្រាន់តែប្រគល់ទ្រព្យឲ្យគេទៅ នឹងបានសុខទៅហើយ រួមសេចក្ដីថា បើគេផ្ចាញ់យើងដើម្បីអ្វី យើងគ្រាន់តែប្រគល់នោះ ឲ្យគេទៅនឹងបានសុខទៅហើយ សូមប្អូនឯងជ្រាប ។

ត្រកួន.— សូមឲ្យបងឯងពិចារណាថែមទៀត ការណ៍ដែលគេផ្ចាញ់យើងពេលនេះ មិនមែនគេផ្ចាញ់ដោយគ្រាន់តែយកទ្រព្យរបស់យើងប៉ុណ្ណោះទេ គឺគេប្រមុងនឹងព្យាបាទយើងថែមទៀត បើដូច្នេះ សូមបងឯងពិចារណាមើលចុះ តើគួរឲ្យប្អូនគេចទៅច្រកណា ?

អណ្ដើក.— ណ្ហើយចុះប្អូន! បើការយ៉ាងនេះ ត្រូវប្អូនឯងវាយតទៅបច្ចាមិត្រតាមកម្លាំងយើង ដែលអាចធ្វើបានទៅចុះ ។

ត្រកួនលុះបានស្តាប់ពាក្យអណ្តើកដូច្នេះហើយ ក៏ចាប់ប្រយុទ្ធតទៅទៀត អស់ពារៈ ១ សប្តាហៈគត់ ទើបកញ្ឆែតដណ្តើមយកជ័យជំនះអំពីត្រកួនបាន ។

ពួកកញ្ឆែតទាំងឡាយ ក៏កើតមានសេចក្តីសប្បាយរីករាយច្រៀងកំលេងទន្ទេរទន្ទាំពាសពេញតែត្រពាំងទឹកនោះ ។ កន្លងបានមក ចំនួនជា ១០ ថ្ងៃ កាលនៃវស្សានរដូវបានញ៉ាំងមហាមេឃឲ្យបង្អុរនូវទឹកភ្លៀងធ្លាក់ចុះ ឥតមានអាក់ ជាហេតុនាំឲ្យពួកកញ្ឆែតរីករាយសប្បាយឥតឧបមា បានបញ្ចេញនូវត្រួយព្រមទាំងសន្លឹកនិងផ្កា ជាទីលំអដ៏រីពាសដេរដាសត្រពាំងទឹកនោះឯង ។ ដំនន់នៃទឹកភ្លៀង ក៏កាន់តែជោរជន់ខ្លាំងឡើង ៗ បន្លិចទីទំនាប ទីទួលទាំងឡាយអស់ហើយ ឃើញមានតែទឹកល្ហល្ហាបកាត់ដើមមេឃ ។ គុម្ពឫស្សីនិងគុម្ពោតឈើទាំងឡាយ ដែលគេក្រឡេកមើលទៅតាមចន្លោះពីមួយទៅមួយ ក៏ហាក់ដូចជាបណ្តែតខ្លួនលេងលើខ្នងទឹកនោះ ហើយតាំងខ្លួននៅនឹងតែមួយកន្លែង មិនញាប់ញ័រទៅដោយរលកនិងខ្យល់ ដែលបក់រំកើយ ៗ បុកកំហុកម្តង ៗ សោះឡើយ ។ ពួកកញ្ឆែតដែលមានជ័យជំនះ ក៏តាំងនាំគ្នាហែលលេងបណ្តែតខ្លួនទៅតាមខ្យល់ដំនោរ ដែលបក់មកផ្ទន់នឹងស្រាល ឥតបាននឹកនាដល់សេចក្តីវិនាសនៃខ្លួន ដោយហេតុឯណាមួយឡើយ ។

ត្រកួន .– បងអើយ ! ខ្លួនប្អូនចេះតែឈ្លក់ទឹក ១ លើក ៗ ទៅហើយ ដោយឫសរបស់ប្អូនធាក់ទៅមាំពេកផង ដោយពួកគេចេះតែមកបៀតផង ៗ

អណ្តើក .– មិនអីទេប្អូន ! សូមប្អូនឯងធាក់ឫសដូចម្តេចឲ្យខានតែជ្រៅមាំទៅចុះ ហើយខំលូតត្រួយបន្តិចឡើង កុំឲ្យលិចក្បាលបាត់ទៅក្នុងទឹក ៗ

ត្រកួន .– ទេបងអើយ ! ប្អូនលូតតាមទឹកមិនទាន់ទេ ព្រោះជំនន់នេះឡើងរហ័សណាស់ ៗ

អណ្តើក .– បើដូច្នេះ ប្អូនឯងអាចដកដង្ហើមយកខ្យល់តាមបំពង់របស់យើងបានឬទេ?

ត្រកួន .– អើមែន ! ប្អូនភ្លេចស្មារតីទៅ ! មិនអីទេ ! ប្អូនអាចដកដង្ហើមយកខ្យល់តាមនោះបាន ៗ

អណ្តើក .– បើដូច្នេះ សូមប្អូនឯងញុំាងកិច្ចនេះ ឲ្យសំរេចឆាប់ទៅ កុំឲ្យដាច់ដង្ហើមស្លាប់ ៗ

ត្រកួន .– លុះបានស្តាប់ពាក្យអណ្តើកប្រាប់ដូច្នេះហើយ ក៏ខំបំប៉ោងខ្លួនយកខ្យល់ ដកបទាល់តែដកដង្ហើមបាន ៗ អានុភាពនេះ បានញុំាងជីវិតានៃត្រកួន ឲ្យប្រព្រឹត្តទៅដោយប្រពៃនៅក្នុងទឹក ៗ

លុះជំនន់ទឹកកាន់តែខ្លាំងឡើង ៗ ដកបទាល់តែលិចគុម្ពោតឈើទាំងឡាយ ជិតអស់ហើយ ៗ អណ្តើកក៏មុជចុះទៅខាងក្រោម ហើយខំ

ផ្កាប់ទ្រូរបស់នៃបក្សីជាតិទាំងឡាយ ជាពួកខាងកញ្ញែតទាំងប៉ុន្មាន នៅតែកំពឹងព្រួយនឹងព្រះក្រាបព្រះខ្វប ដោយផ្កាប់មិនទាន់ ៗ បក្សីជាតិទាំង-ឡាយនោះ ក៏អណ្តែតត្រសែតទៅតាមរលកទឹកដោយកម្លាំងខ្យល់ដែលបោកបក់មកអំពីទិសផ្សេង ៗ នាំគ្នាឡើងទៅលើគុម្ពឈើ នឹងឡើងទៅលើគុម្ពឫស្សីទាំងឡាយ ដែលលិចទឹកនៅសល់តែចុងប៉ប្រិម ៗ ៗ ចំណែកខាងកំពឹងព្រួយព្រះក្រាបនឹងព្រះខ្វប ដែលអណ្តើកផ្កាប់ប៉ុសមិនទាន់ ក៏លិចទៅក្នុងទឹកឈ្ងក់ស្ទើរស្លាប់ស្ទើររស់ ៗ នៅវេលាដែលទឹកជំនន់ឡើងខ្លាំងនោះ អណ្តើករកអាហារបរិភោគមិនបាន ត្រូវស៊ូបរិច្ចាគខ្លួនឲ្យអណ្តើកបរិភោគនូវអវយវៈដ៏សេសទាំងឡាយ ៗ

កាលណោះកញ្ញែតព្រះក្រាបនឹងព្រះខ្វប លើកដៃឡើងសំពះសុំឲ្យព្រះឥន្ទឲ្យជួយស្រោចស្រង់ជីវិតខ្លួន នឹងពួកពលទាំងប៉ុន្មាន កុំឲ្យស្លាប់នៅក្នុងទឹក ព្រះឥន្ទ្រក៏មានសេចក្តីអាណិត បានចុះមកជប មិនឲ្យបក្សីជាតិនឹងតិណជាតិទាំងឡាយនោះ ស្លាប់ដោយអំណាចទឹក តែទ្រង់បានប្រាប់ថា ជំនួយរបស់ទ្រង់បានតែត្រឹមប៉ុណ្ណោះទេ នឹងជួយតទៅទៀតមិនបាន ព្រោះពួកឯងនេះ មានកំហុសធំណាស់ ត្រង់រំលោភលើគេមុន ៗ

ក្រោយដែលព្រះឥន្ទជបខ្លួនហើយ ពួកកញ្ញែតស្មានថាខ្លួនអស់ស្លាប់ហើយ នាំគ្នាត្រាប់ផ្អាក់ហែលលេងសប្បាយ តាមអំពើចិត្តនៅទី

នោះ  ឥតទឹកនាដល់សេចក្តីវិនាសនៃខ្លួនឡើយ  ហើយក៏ស្រែកច្រៀង
បំអកឲ្យត្រកួនទឹងអណ្តើកថា :–

អនិច្ចាប្អូនប្អូនក្នុងផលសែ
លាស់ត្រយ៉ែ ៗ ស្មើរខ្យ័យផ្ទ
កំព្រាកំប្រានកាយទុរន់
ទុក្ខធ្ងន់ព្រោះតែបកជ័យ ៗ
ត្រែលត្រោលតែលតោលអនាថា
ទៅក្នុងផលសាកើតទុក្ខភ័យ
ពង្សូបផ្ងុំកំអភ័យ
កើតមានទុក្ខភ័យព្រោះពឹងខ្លួន ៗ

ចំណែកខាងត្រកួនទឹងអណ្តើក  លុះបានស្តាប់ចម្រៀងនេះហើយ គំគិតគ្នាថា  យើងទាំង ២ នាក់  ត្រូវគេមើលងាយដោយហេតុយើងបកជ័យនេះហើយ ៗ  ប៉ុន្តែយើងមិនត្រូវតក់ស្លុតដោយហេតុនេះឡើយ យើងត្រូវតាំងចិត្តឲ្យមាំ កុំបោះបង់នូវគោលគំនិតរបស់យើងចោលឲ្យសោះ ព្រោះការចាញ់ទឹងការឈ្នះនេះ  គេអាចស៊ីសងទៅតាមកាល.ទេសៈខ្លះ ទៅតាមឧបាយនៃប្រាជ្ញាខ្លះ  ទៅតាមឥទ្ធិពលខ្លះ  កុំឲ្យតែខ្លួនយើងចាញ់ខ្លួនយើង ៗ  បើយើងចាញ់ខ្លួនយើងហើយ  យើងមិនបាច់សង្ឃឹមថា យើងទឹងឈ្នះគេបានឡើយ ៗ បើយើងឈ្នះខ្លួនយើងហើយ យើងត្រូវ

សង្ឃឹមថា  យើងមុខជានឹងបានឈ្នះគេ  ក្នុងកាលណាមួយដោយពិត ឥឡូវនេះខ្លួនយើង  បានឈ្នះខ្លួនយើងហើយ  គឺយើងបានកំចាត់បង់នូវសេចក្តីទន់ខ្សោយអំពីខ្លួនយើងចេញបានហើយ  យើងនៅតែមិនទាន់ឈ្នះគេប៉ុណ្ណោះទេ  នេះសូមប្អូនឯងកុំភ័យឲ្យសោះ ៗ

នាកាលជិតដល់ទីបំផុតនៃវស្សានរដូវ  មហាមេឃក៏បញ្ឈប់នូវការបង្អុរនូវទឹកភ្លៀង  ដុំពពកធំ ៗ  ដែលតែងតែបក់សោតទៅកាន់ទិសខាងជើង  ក៏បែកកាយទៅជាកំទេចកំទី  នៅដេរដាសពាសពេញផ្ទៃអាកាស  ចំហាយនៃព្រះអាទិត្យក៏បញ្ចេញនូវកំដៅយ៉ាងខ្លាំងក្លា  ប្លែកពីពេលមុន,  មនុស្សនិងសត្វទាំងឡាយ  ក៏មានសេចក្តីសុះស្អាប់  ដោយចំហាយនោះ ប្រែប្រួលខុសធម្មតា ៗ  ទឹកដែលមានពណ៌ល្អក់  ក៏ប្រែត្រឡប់ទៅជាមានពណ៌ថ្លា  មច្ឆជាតិទាំងឡាយ  ក៏នាំគ្នាត្រាចទៅរកទីជំរៅ ៗ  សម័យនេះហើយ  ដែលគេហៅថារដូវទឹកស្រក ៗ

កាលដែលជារទឹកកំពុងតែនៅនឹងតាមកំណត់ធម្មតា  ពពួកកញ្ចែតដែលកំពុងតែត្រេកសប្បាយ  ខ្លះនៅសំណាក់ដោយគុម្ពឫស្សី  ខ្លះនៅសំណាក់លើគុម្ពោតឈើទាំងឡាយ  ខ្លះបណ្តែតខ្លួនទៅកាន់ទីវាលតាមប្រាថ្នា ៗ

ជារទឹកក៏ស្រកស្រុតបន្តិចម្តង ៗ ពពួកបង្កាជាតិដែលនៅលើគុម្ពឫស្សីនឹងនៅលើគុម្ពោតឈើទាំងឡាយ  លុះទឹកជំនន់ស្រកអស់  ក៏ទើរជាប់នៅ

ទីនោះតែម្តង ពពួកបក្សជាតិដែលអណ្តែតទៅតាមជំនន់ទឹក ក៏រសាត់ខ្លួនទៅក្នុងទីវាល ដែលជាទីទួលនឹងជាទីរាបស្មើ ។

លុះត្រូវចំហាយព្រះអាទិត្យ នឹងដំណោរខ្យល់ ដែលបក់ផ្សាយចេញអំពីទិសខាងជើងត្រឡប់មកវិញ បក្សជាតិដែលនៅទេរលើគុម្ពឫស្សី នឹងគុម្ពោតឈើទាំងឡាយនោះ ក៏ស្វិតស្រពោនក្រៀមក្រញង់ បង់ជីវិតអស់រលីង ។ ចំណែកខាងបក្សជាតិដែលនៅនាទីទួល នឹងព្ធដីទីទំនាបស្មើ ក៏ស្វិតស្រពោនក្រៀមក្រញង់បាត់បង់ជីវិត ដូចជាបក្សជាតិទាំង-ឡាយនោះដែរ នៅសល់តែកំពីងពួយ នឹងព្រះក្រាប ព្រះខ្ទប ដែលរលួយខ្លួនទៅសល់តែឫសគល់ ក៏ប្រឹងលូតលាស់ឡើង ក្នុងត្រពាំងទឹកនោះ ហារជាថ្មី មានសេចក្តីកិតភ័យឥតឧបមា ហើយសុំចុះចាញ់នៅក្រោមអាណាព្យាបាលត្រកួននឹងអណ្តើកតទៅ ត្រង់នេះហើយ ដែលមានពាក្យបុរាណថា ត្រកួនឈ្លក់ទឹក ឬកំពីងពួយឈ្លក់ទឹក, អណ្តើកស៊ីត្រកួន ថែមទាំងមានគេបង្កើតបទភ្លេងមួយ ហៅថា "បទអណ្តើកស៊ីត្រកួន" មកដំនាន់ក្រោយនេះទៀត ។ ឯកញ្ចែតដែលភ័យខ្លួន ក៏ជាប់សំពះតាំងពីកាលណោះរហូតមកដល់សព្វថ្ងៃនេះ ។ ចំណែកខាងព្រះក្រាប ក៏ចេះតែក្រាបសំពះ ព្រះខ្ទប ក៏ចេះតែលើកដៃសំពះខ្ទបខ្ទាប តាំងពីកាលនោះមកដែរ ។

លុះដល់គិម្ហរដូវ ចំហាយនៃព្រះអាទិត្យ ក៏បានញុំាងគិណជាតិឲ្យស្ងិតស្រពោនក្រៀមក្រោះ ទឹកដែលដក់នៅក្នុងត្រពាំង បឹងបួទាំងឡាយ ក៏រីងថយចំនួន ស្ទើរតែអស់ ។ ត្រកួនទឹងអណ្តើក ក៏នាំគ្នានៅអាស្រ័យក្នុងត្រពាំងទឹកនោះ ដោយសេចក្តីរីករាយ គឺជាអ្នកបាននូវជ័យជំនះ ដោយស្វ័យប្រវត្តិ ដែលកើតមកអំពីសកម្មភាពនៃខ្លួន ។ ត្រកួនទឹងអណ្តើកបានស្រែកច្រៀងឡើងថា :-

ការកើតបានមកជារូបអង្គ
ត្រូវផ្ចង់គំនិតនឹងប្រាជ្ញា
ព្រមទាំងសេចក្តីខ្នះស្វាហ៍
រៀនវិជ្ជាការឲ្យចេះស្ទាត់ ។
ថែមទាំងឲ្យមាននូវឧបាយ
កិច្ចកលទាំងឡាយឲ្យច្រើនបទ
ត្រូវគិតជញ្ជឹងឲ្យម៉ត់ចត់
នូវការកំណត់ខ្លួនអាត្មា ។
ថាគួរជាទីពឹងហើយនៅ
កិច្ចការរាក់ជ្រៅផងក្តីណា
សម្រាប់ខ្លួនឯងបងប្រាថ្នា
កុំឲ្យនរណាសង្កត់បាន ។

នេះទើបពេញជាអ្នកពូកែ
ផុតគេបំបែរឲ្យបាញ់បាន
រស់នៅមានជ័យសព្វទីស្ថាន
បានក្ដីក្សេមក្សាន្តជាភិយ្យោ ។

មិនយូរប៉ុន្មានភ្លើងព្រៃ ក៏បណ្ដាលឆេះឡើងពាសពេញនៅទីនោះ ពួកខ្មោចកញ្ញោតនិងខ្មោចបង្កជាតិទាំងឡាយនោះ ត្រូវភ្លើងព្រៃឆេះខ្ទិចខ្ទីរអស់ នៅសល់តែអ្នកដែលរសាត់ខ្លួនទៅជិតជើងភ្នំ ដែលមានសំណើមបន្តិចបន្តួច ហើយភ្លើងព្រៃឆេះរាលទៅមិនដល់ ។

ពួកខ្យង-ខ្ចៅនិងក្ដាមទាំងឡាយក៏តាយសាក នៅទីវាលនោះជាច្រើន រួចតែពួកខ្យង-ខ្ចៅនិងក្ដាមឯណា ដែលរសាត់ខ្លួនទៅក្នុងទីបឹងត្រពាំងដទៃ ឬដែលកប់ខ្លួនទៅក្នុងដីយ៉ាងជ្រៅ ។

ដោយមានឧបត្តិហេតុពីព្រេងនាយមកយ៉ាងនេះ បានជាខ្យង-ខ្ចៅនិងក្ដាមមានតាយសាក នៅទីវាលនីមួយៗ ដែលគេឃើញមានមកដល់សព្វថ្ងៃនេះ ។

រឿងព្រេងនេះ សឲ្យឃើញជាគតិ ៤ យ៉ាង :–

១ – ជនណាមួយដែលនៅក្នុងគ្រួសារ ហើយតាំងគំនិតផ្អែកទៅលើម្ដាយឪពុកបង-ប្អូន ញាតិសាច់សាលោហិតឬទៅលើមិត្ត ដោយស្មោះ គ្មានគំនិតដុះអំពីខ្លួន ថានឹងធ្វើខ្លួនឲ្យទៅជាមនុស្សមានគុណ

សម្បត្តិ នឹងសមត្ថភាពគួរជាទីពឹងនៃខ្លួនបាន ហើយត្រេកត្រអាល ទៅដោយផលដែលចេញអំពីសមត្ថកិច្ចនៃអ្នកដទៃក្រៅអំពីខ្លួននោះ លោកទុកថាជាអំពើនាំខ្លួនឲ្យវិនាសទៅក្នុងអនាគត ;

២.— អ្នកដែលនៅក្នុងសង្គមនីមួយ ៗ ទោះបីសង្គមនៃខ្លួនមានគ្នាតិចយ៉ាងណាក៏ដោយ មិនត្រូវបណ្ដោយឲ្យមានគំនិតប្រាថ្នាអូនថយជាងគេទេ បើទុកជាចាញ់កម្លាំងកាយគេក៏ដោយ មិនត្រូវឲ្យចាញ់ទាំងកម្លាំងប្រាថ្នាថែមទៀតទេ ៗ បើចាញ់កម្លាំងប្រាថ្នាគេហើយ សង្គមនោះបើទុកជាមានគ្នាច្រើនយ៉ាងណាក៏ដោយ មិនអាចធ្វើឲ្យមានអធិប-តេយ្យបានឡើយ ;

៣.— កិច្ចការទាំងឡាយ ដែលយើងមិនអាចធ្វើដោយខ្លួនឯងឬដែលយើងមិនអាចនឹងយល់ដោយខ្លួនឯងបាន ទោះបីយើងបេះអង្វរករសំពះសំពនឲ្យគេអាណិតមេត្តាជួយធ្វើ ឲ្យបានសំរេចផលតាមប្រាថ្នាក៏ដោយ ការនោះឈ្មោះថា មិនប្រសើរឡើយ ដោយជំនួយនោះនឹងវិនាសទៅក្នុងកាលណាមួយមិនខាន មកអំពីកិច្ចដែលអ្នកដទៃគេធ្វើឲ្យ មិនមែនចេញមកអំពីខួរក្បាលនៃខ្លួនពិត ៗ នោះ នឹងទុកជាស្ថាពរមិនបាន ;

៤.— ការឈ្នះឯណា ដែលមិនមែនជាការឈ្នះដោយឥទ្ធិពលនៃខ្លួន គេមិនទុកថាជាការឈ្នះដ៏ប្រសើរឡើយ ព្រោះការឈ្នះនោះ គេហៅ

ថាឈ្នះខាងក្រៅ ៗ កិច្ចដែលឈ្នះខាងក្រៅនេះ មិនអាចធ្វើខ្លួនអ្នកដែលបានឈ្នះហើយនោះ ឲ្យប្រាសចាកការដែលគេត្រូវឈ្នះខ្លួនវិញបានឡើយ ៗ

ដូចមានសុភាសិតថា:

កិច្ចការទីពឹង　　　នៃខ្លួនទួននឹង
ប្រសើរគួរគាប់　　　ត្រូវតែប្រឹតប្រៀន
ខ្លួនឯងឲ្យជាប់　　　បំណេះគួរគាប់
ប្រាជ្ញាស្មារតី ៗ　　　មារយាទគំនិត
ឲ្យបានល្អពិត　　　តាមសិទ្ធិប្រុសស្រី
មិនឲ្យថ្លោះធ្លោយ　　　ដោយអបាយបី
គឺល្បែងស្រា ស្រី　　　មិត្តបាបជាបួន ៗ
នេះហៅជោគជ័យ　　　តែងកើតប្រពៃ
មានទៅក្នុងខ្លួន　　　នៃអ្នកបង់ឈ្នះ
សត្រូវទាំងបួន　　　ទិសទឹងគេចពួន
ចាលចាញ់ឯង ៗ ៗ　　　មិនបាច់ខំប្រឹង
កាយតប់តាមខឹង　　　កំហល់កំហែង
ស្រាប់តែខ្ជបខ្ជាប　　　អំណាចព្រះស្គង
យើមខ្លួនចាញ់ឯង　　　ព្រោះយើងមានជ័យ ៗ

កែ-ដុន

# ត្រីមួយត្រកស្អុយតែមួយស្អុយទាំងអស់(១)

## រឿងអ្នកបួសក្លែងក្លាយ

កាលពីព្រេងនាយ ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ។ ព្រះពោធិសត្វសោយព្រះជាតិជាព្រះឥន្ទ្រ ។ គ្រានោះមានបុរសម្នាក់តាំងខ្លួនថាជាអ្នកចេះដឹង អាចសំដែងឫទ្ធិផ្សេង ៗ មានហោះហើរដើរលើអាកាសជាដើម ។ អាស្រ័យហេតុនេះបានជាគេក្លាយទៅជាអ្នកក្លែងខ្លួនយ៉ាងសំខាន់ គឺក្នុងវេលាថ្ងៃក្លែងខ្លួនជាអ្នកបួសប្រព្រឹត្តយ៉ាងស្ងប់ស្ងាត់ វេលាយប់ធ្វើជាចោរ លួចទ្រព្យរបស់គេខ្លះ ករួចដេកនឹងប្រពន្ធកូនគេខ្លះ ទាល់តែល្បីឈ្មោះសុះសាយគេដឹងឮគ្រប់គ្នា ។

សម័យមួយ មនុស្សក្លែងខ្លួននេះ ស្រឡាញ់ព្រះអគ្គមហេសីនៃព្រះបាទពារាណសី ដល់វេលាពាក់កណ្ដាលអធ្រាត្រក៏ក្លែងភេទជាស្ដេចលបចូលទៅដល់ក្រឡាបន្ទំរបស់ព្រះនាង លុះរួមសំវាសតាមចិត្តប្រាថ្នារបស់ខ្លួនរួចហើយ ក៏លបគេចចេញទៅវិញ ។

ខាងក្រោយមក ពួកស្រីស្នំរបស់ព្រះនាងដឹងរឿងនោះ ក៏ក្រាបទូលដល់ព្រះរាជា ។ ព្រះនាងជ្រាបរឿងនោះហើយក៏តក់ស្លុតព្រះទ័យរត់ទៅក្រាបទូលទទួលទោសខុសចំពោះព្រះរាជស្វាមី យ៉ាងប្រញាប់ថា សូមព្រះរាជតេជះដំកល់លើត្បូង ! ព្រះរាជអាជ្ញាមិនទាន់គ្រប់គ្រាន់ទេ រឿងដែលកើតឡើងគ្រានេះមកអំពីខ្ញុំម្ចាស់ចូលចិត្តខុស ។

---

• ស្រង់ចាកធម្មចក្ខុភាគទី ២៤ ។

ព្រះរាជាត្រាស់ថា បើឯងចូលចិត្តខុសមែនអញនឹងលើកទោសឲ្យ ប៉ុន្តែអញចង់ដឹងណាស់ថាអ្នកណាដែលមកធ្វើដូច្នោះ ? ឯងអាចនឹងធ្វើគ្រឿងសំគាល់ណាមួយក្នុងខ្លួនបុរសនោះបានឬទេ ?

ព្រះនាងក្រាបទូលថា ធ្វើបាន ទើបឲ្យនាំគ្រឿងលាបព្រះហស្តមកបម្រុងទុក ៗ កាលបុរសនោះមកក្នុងវេលាយប់ ព្រះនាងក៏ទទួលរាក់ទាក់ដូចសព្វដង លុះបានឱកាសហើយក៏យកព្រះហស្តដែលប្រឡាក់ដោយគ្រឿងលាបនោះស្ទាបខ្នងបុរស ឃើញជាស្នាមម្រាមទាំង ៥ ច្បាស់លាស់ ៗ ព្រឹកឡើងព្រះនាងទៅគាល់ព្រះរាជស្វាមី ក្រាបទូលការនោះឲ្យទ្រង់ជ្រាបគ្រប់ប្រការ ៗ

ព្រះបាទពារាណសីទ្រង់បង្គាប់ពួករាជបុរសថា ចូរអ្នករាល់គ្នាត្រាច់ទៅរកមើលឲ្យគ្រប់មនុស្សប្រុស បើថាឃើញអ្នកណាមានស្នាមម្រាមដៃនៅត្រង់ខ្នង ចូរចាប់ខ្លួនអ្នកនោះនាំយកមកឲ្យយើងយ៉ាងប្រញាប់ ៗ

ចំណែកបុរសនោះ លុះធ្វើអនាចារក្នុងវេលាយប់រួចហើយ ដល់ពេលថ្ងៃក្លែងភេទជាអ្នកបួស ឈរតែជើងម្ខាងសំពះព្រះអាទិត្យក្នុងព្រៃខ្មោចមួយកន្លែង ៗ ពួករាជបុរសដែលស្វែងរកមនុស្សក្លែងក្លាយនោះបានទៅជួបប្រទះឃើញគ្រឿងសំគាល់នៅត្រង់ខ្នង ក៏ចូលទៅចាប់ ៗ បុរសនោះដឹងខ្លួនថា វេលានេះ ច្បាស់ជាមានរាជភ័យដល់ខ្លួន

អញហើយ ទើបស្រែកយមន្តហោះរត់បាត់ទៅ ៗ ពួករាជបុរសចាប់មិនបាន ក៏ចូលទៅក្រាបទូលព្រះរាជាថា បុរសអាក្រក់នោះជាកេទបណ្ឌិត ឥឡូវហោះរត់បាត់ទៅហើយ ខ្ញុំព្រះអង្គចាប់មិនបានទេ ៗ តែតាមពិតបុរសនោះមិនមែនជាបណ្ឌិតដូចអាមាត្យឃើញនោះទេ ៗ

បំណែកព្រះរាជាព្រះអង្គជាអគ្គសាសនូបត្ថម្ភ ទ្រង់ស្រឡាញ់រាប់អានទឹងលើកដំកើងទំនុកបម្រុងពួកបណ្ឌិតទាំងអស់ លុះទ្រង់ជ្រាបដូច្នោះហើយក៏ទ្រង់ព្រះចិន្តាថា យើងស្រឡាញ់រាប់អានទំនុកបម្រុងពួកបណ្ឌិតទាំងនេះដោយចូលចិត្តថាជាអ្នកប្រព្រឹត្តល្អត្រឹមត្រូវ សមទឹងភាពខ្លួនជាអ្នកបួស ប៉ុន្តែបែរជាពួកបណ្ឌិតទាំងនេះ ប្រព្រឹត្តមិនត្រឹមត្រូវតាមធម៌វិន័យទៅវិញ ជាអ្នកបួសតែពេលថ្ងៃ ដល់វេលាយប់ធ្វើជាមនុស្សអាក្រក់ធ្វើជាចោរ បើយើងនៅស្រឡាញ់រាប់អានទំនុកបម្រុងពួកបណ្ឌិតទាំងនេះតទៅទៀត ក៏ដូចជាយើងទំនុកបម្រុងមនុស្សអាក្រក់ឲ្យរឹតតែកើតមានច្រើនឡើង ៗ ព្រះអង្គទ្រង់ព្រះពិរោធនឹងពួកបណ្ឌិតយ៉ាងខ្លាំង ត្រាស់បង្គាប់ឲ្យប្រកាសប្រាប់ប្រជាជនពេញដែនព្រះអង្គថា ត្រូវឲ្យធ្វើទោសដល់ពួកបណ្ឌិតក្នុងទីដែលខ្លួនបានជួបប្រទះ ដោយតាំងក្នុងព្រះរាជហឫទ័យថា ពួកបណ្ឌិតទាំងអស់ត្រូវចេញពីដែនរបស់អញទៅ ៗ ពួកបណ្ឌិតដែលឥតប្រព្រឹត្តខុសសោះ ត្រូវរាជភ័យគម្រាម ក៏នាំគ្នារត់ចេញទៅសំណាក់អាស្រ័យនៅដែនដទៃ ៗ ទាល់តែអស់ ៗ.

រឿងនេះ បណ្ដាលមកពីមានមនុស្សអាក្រក់តែម្នាក់ក្នុងខ្លួនជាអ្នកបួសប្រព្រឹត្តខុសធម៌វិន័យប៉ុណ្ណោះ ក៏នាំឲ្យកើតសេចក្ដីទុក្ខក្ដៅក្រហាយដល់ពួកបព្វជិតអ្នកប្រព្រឹត្តត្រឹមត្រូវតាមធម៌វិន័យទូទៅឥតសល់ម្នាក់ ។ ដែលអាក្រក់ក្រៃលែងនោះគឺត្រង់ការធ្វើឲ្យវិនាសព្រះពុទ្ធសាសនា ដឹកនាំអ្នកមានសទ្ធាជ្រះថ្លាឲ្យត្រឡប់ទៅជាមនុស្សមិច្ឆាទិដ្ឋិវិញ ដូចជាព្រះបាទពាកណសិទ្ធិងបណ្ដាពស្ត្រប្រិននាក់ បើសេចក្ដីអាក្រក់យ៉ាងនេះ

មាននៅក្នុងខ្លួនបព្វជិតបរិសុទ្ធមិនជាអ្នកក្នុងក្លាយទេ ម្ល៉េះសមមនុស្សទាំងអស់ទឹងក្លាយទៅជាមិច្ឆាទិដ្ឋិមិនខានឬទេ? រឿងនេះមិនត្រូវសង្ស័យឡើយ កាលបើពួកបព្វជិតដែលជាអ្នកទ្រង់ធម៌វិន័យពិតប្រាកដមែន ត្រូវពជភ័យសង្កត់សង្កិនហើយនាំគ្នារត់ចេញទៅនៅប្រទេសដទៃអស់ហើយ សេចក្ដីអាក្រក់គ្រប់យ៉ាង ក៏ចូលទៅនៅក្នុងដួងចិត្តរបស់ពួកមិច្ឆាទិដ្ឋិទាំងឡាយ ព្រោះមិនបានស្ដាប់ឱវាទរបស់អ្នកប្រព្រឹត្តធម៌ នាំគ្នាសំគាល់ថាគំនិតគិតឃើញរបស់ខ្លួនត្រឹមត្រូវល្អ អ្នកណាយល់ឃើញដូចម្ដេចក៏ប្រព្រឹត្តទៅតាមគំនិតរបស់ខ្លួនដូច្នោះ ឥតមានគោលចារិកឡើយ ទានសីលដែលធ្លាប់ធ្វើមកក៏យល់ឃើញថាឥតមានផលប្រយោជន៍អ្វី ត្រឡប់ក្លាយទៅជាមនុស្សឃើញតែខ្លួនឯង ចេះតែសន្សំសេចក្ដីអាក្រក់ លុះស្លាប់ក៏ទៅកើតក្នុងអបាយភូមិជាច្រើន ឥតអ្នកណាទៅកើតក្នុងសុគតិឡើយ ។

គ្រានោះ ព្រះឥន្ទ្រាធិរាជមិនឃើញមានទេវបុត្រទេវធីតាមកកើតថ្មីទៀត ក៏អន់ព្រះទ័យ ទ្រង់ពិចារណាមើលថា ព្រោះហេតុអ្វីបានជាគ្មានទេវបុត្រទេវធីតាមកកើតថ្មីក្នុងពិភពអញ បានទ្រង់ជ្រាបរឿងនោះជាក់ច្បាស់ហើយក៏ស្ដេចទៅឯកំទន្ទមូលក:និមន្តព្រះបច្ចេកពុទ្ធ ១ ព្រះអង្គមកក្រុងពារាណសី ទ្រង់និម្មិតព្រះអង្គជាមាណពកំឡោះមានរូបល្អស្អាតកាន់បាត្រនិងចីវររបស់ព្រះបច្ចេកពុទ្ធ ផងអញ្ជើញស្ដេចទៅខាងក្រោយលុះទៅដល់ប្រទក្សិណនគរពារាណសី ៣ ជុំ ហើយទ្រង់ឈរលើអាកាសត្រង់ទ្វារព្រះរាជវាំង ទ្រង់ត្រាស់ទូន្មានព្រះមហាក្សត្រថា បពិត្រមហារាជធម្មតាបព្វជិតទាំងឡាយជាទីគោរពរាប់អានរបស់ប្រជុំជន យើងមិនត្រូវប្រមាថមើលងាយលោកទេ ខ្ញុំនេះជាព្រះឥន្ទ្រមករំឭកព្រះអង្គថា បើអ្នកណាឃើញបព្វជិតដែលមានមារយាទរៀបរយល្អ ដល់ព្រមដោយសីលាចារវត្តនិងតាំងនៅក្នុងសមណសញ្ញា គឺការសំគាល់ថាខ្លួនជាសមណៈឬជាអ្នកបួស ដូច្នោះហើយផ្គងអញ្ជលីនមស្ការលើកលោកទុកក្នុងឋានៈជាឧបរិមទិសគឺទិសខាងលើ អ្នកនោះរមែងបានពាក្យសរសើរអំពីបណ្ឌិតក្នុងបច្ចុប្បន្ននិងបរលោក ក៏រមែងបានទៅកើតក្នុងសុគតិភពជាទីរីករាយសប្បាយចិត្ត ។

ព្រះរាជាបានទ្រង់ព្រះសណ្ដាប់ឱវាទព្រះឥន្ទ្រហើយ ក៏កំចាត់សេចក្ដីឃើញខុសពីដើមចេញអស់ ទើបត្រាស់ថា ខ្ញុំបានស្ដាប់ពាក្យរបស់

ព្រះអង្គក្នុងថ្ងៃនេះ ធ្វើឲ្យខ្ញុំមានស្មារតីដឹងផលនៃការល្អនឹងអាក្រក់យ៉ាងជាក់ច្បាស់ បពិត្រទេវរាជ បើខ្ញុំបានជួបប្រទះឃើញបណ្ឌិតក្នុងព្រះពុទ្ធសាសនា ដល់ព្រមដោយសីលាចារវត្ត មានសមណសញ្ញាដូចព្រះអង្គជានេះ ខ្ញុំក៏មិនក្លាយទៅជាមនុស្សមិច្ឆាទិដ្ឋិនឹងមិនវិនាសបុណ្យកុសលដែលគួរបាននោះទេ តាំងអំពីថ្ងៃនេះទៅ ខ្ញុំនឹងខំបំពេញបុណ្យកុសលមិនខាន ៗ ខ្ញុំបាត់ក្រោធខឹងហើយ មានចិត្តជ្រះថ្លាជានិច្ចនឹងបណ្ឌិតដែលល្អបរិសុទ្ធ ព្រោះខ្ញុំយល់ឃើញថា បណ្ឌិតដែលប្រព្រឹត្តល្អក៏មាន ខ្លួនខ្ញុំជាមនុស្សត្រចៀកស្រាលជឿគេងាយៗមិនបានពិចារណា សំដីរបស់អាមាត្យដែលឥតពិចារណាដូចគ្នា តាំងពីថ្ងៃនេះទៅ ខ្ញុំនឹងព្យាយាមប្រកបបុណ្យកុសលសម្មាបដិបត្តិ ក៏ចាត់មានៈប្រកាន់ខ្លួនថាជាក្សត្រចេញហើយ គោរពកប់អានបណ្ឌិតអ្នកទ្រទ្រង់ធម៌ទាំងឡាយ ខ្វល់ខ្វាយដឹកនាំប្រជាជនឲ្យតាំងនៅក្នុងកុសលសុចរិត គ្រប់គ្រងវជ្ជសីមាអាណាចក្រ ប្រកាន់គោលទសពិធរាជធម៌ក្នុងចិត្តដរាបដល់អវសានកាលនៃជីវិត លុះត្រាស់ចប់ហើយក៏ចុះចាកប្រាសាទឈរអភិវាទព្រះបច្ចេកពុទ្ធនៅទីម្នាង ៗ

ព្រះបច្ចេកពុទ្ធគង់លើបល្ល័ង្កក្នុងអាកាសហើយ ប្រទានឱវាទដល់ព្រះរាជាថា មហាបពិត្រ សេចក្តីក្តៅក្រហាយដែលកើតដល់វជ្ជសីមារបស់ព្រះអង្គក្នុងគ្រានេះ មានមូលហេតុ ២ ប្រការគឺមកអំពីមានមនុស្សអាក្រក់ក្លែងខ្លួនធ្វើជាអ្នកបួសប្រការ ១ តាមពិត អ្នកនោះឯងក្លែងខ្លួនធ្វើ

ជាអ្នកបួសដើម្បីរកស៊ីចិញ្ចឹមជីវិត គេធ្វើឧបាយនេះដោយមិនបានទឹកឃើញ ថាទឹងវិនាសដល់ពួកគណៈដែលប្រជាជនរាប់អានទេ សូមព្រះអង្គប្រយ័ត្ន កុំឲ្យមានបព្វជិតក្លែងក្លាយដូច្នោះទៀត ព្រោះទឹងកើតមានភ័យដល់ព្រះសាសនា នាំឲ្យមហាជនពួកខ្លះយល់ឃើញថា បដិបទារបស់បព្វជិតមិនល្អប្រពៃទេ ប្រការមួយទៀត កើតក្តៅក្រហាយមកពីព្រះអង្គមានព្រះទ័យស្រាលឥតពិចារណា ចេះតែទ្រង់ជឿពាក្យអាមាត្យអ្នកយល់ខុស ទាល់តែសព្វព្រះទ័យថាបព្វជិតទាំងអស់សុទ្ធតែអាក្រក់ដូចគ្នា តាំងពីនេះតទៅ សូមព្រះអង្គតាំងព្រះទ័យថា ក្នុងលោកនេះមិនមែនគ្មានបព្វជិតអ្នកទ្រទ្រង់ធម៌វិន័យទេ ផលរបស់ទាន,សីល ទឹងមេត្តាភាវនាក៏មាន សូមព្រះអង្គព្រមទាំងប្រជារាស្ត្រ ខំបំពេញទានទឹងរក្សាសីលចំរើនមេត្តាភាវនាចុះ ដើម្បីឲ្យបានសេចក្តីសុខចំរើនគ្រប់គ្នា ។

ចំណែកព្រះឥន្ទទូន្មានស្តេចទឹងមហាជន ឲ្យខំប្រព្រឹត្តល្អតាំងផ្លូវលោកទឹងផ្លូវធម៌ហើយបង្គាប់ ឲ្យព្រះមហាក្សត្រលុបព្រះរាជប្រកាសដែលបណ្តេញពួកបព្វជិតមិនឲ្យនៅក្នុងដែននោះចោលចេញ ប្រាប់ឲ្យខំចាត់អ្នកបួសបួមចេញ ឲ្យខំទំនុកបម្រុងអ្នកបួសទ្រទ្រង់ធម៌វិន័យហ្មត់ចត់ លុះទូន្មានរួចហើយក៏និមន្តព្រះបច្ចេកពុទ្ធវិលទៅលំនៅដើមវិញ ។

ឯព្រះរាជាព្រមទាំងអាណាប្រជារាស្ត្រ ក៏បានតាំងនៅក្នុងឱវាទនៃព្រះបច្ចេកពុទ្ធទឹងព្រះឥន្ទ្រ បានបំពេញកុសលមានទានជាដើម លុះរំលាយខន្ធក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោកហោង ។

# តួសេបក្ដីសុខ

ប្រូហ្វែត(១) អេលី នឹងសិស្សឈ្មោះអេលីហ្ស៊ី បានត្រាច់ចរកាត់ស្រុកភូមិក្នុងប្រទេសអ៊ីស្រាអែល ។

ថ្ងៃមួយ កាលលោកកំពុងដើរកណ្ដាលវាលស្រែ លោកបានឃើញបុរសម្នាក់កំពុងភ្ជួរស្រែមានទឹកមុខអាក្រក់ពេក ។ បុរសនោះដេញគោដោយវាយនឹងរំពាត់ ហើយចេះតែថ្ងូរហ៊ឹះ លុះពេលបាយជិតមកដល់ នាងជាប្រពន្ធបានរៀបចំស្លដណ្ដាំទុកសម្រាប់ឲ្យ ហើយនាងជាម្ដាយក៏មិនព្រងើយកន្តើយដែរ នាងបានយកក្រឡស្រាមកទុកបម្រុងឲ្យ ។ អ្នកស្រែបញ្ឈប់ការងារ គេទទួលទានបាយហើយផឹកផង ប៉ុន្តែ ទាំងអាហារមានឱជារស ទាំងស្រាល្អពិសា ទាំងបិយវាចានៃភរិយានិងម្ដាយក៏មិនអាចញុំាងមុខក្រៀមក្រំនៃបុរសនោះឲ្យកម្រើកបាន ។

អេលីសំឡឹងមើលបុរសនោះដោយស្ងៀមស្ងាត់ រួចក៏ដណ្ដឹងថា:

– នែបុរស! ប្រការម្ដេច ក៏អ្នកមានទឹកមុខអាក្រក់ម្ល៉េះ? យើងយល់ថា មិនមែនការស្រេកឃ្លានទេ ដែលធ្វើអ្នកឲ្យមានទុក្ខព្រួយ ។ អ្នកមានប្រពន្ធជាទីស្នេហា ចិត្តក៏ស្លូតត្រង់ ហើយមានវាសនាល្អដោយម្ដាយ

១ ប្រូហ្វែតៈ ក្នុងសាសនាអ៊ីស្រាអែល ប្រូហ្វែតជាបំរើព្រះអាទិទេពសម្រាប់ប្រាប់ដំណឹងសុខទុក្ខដល់មនុស្សលោក ប្រហែលគ្នានឹងចតុលោកបាលក្នុងព្រះពុទ្ធសាសនា ។

មានជីវិតរស់នៅ ៗ តើវត្ថុដ៏ថ្លៃថ្លាទាំងនេះមិនធ្វើឲ្យអ្នកសប្បាយចិត្តឬ? អ្នកមានទឹកមុខអាក្រក់ដូច្នេះ តើមកពីដំណើរអ្វី?

បុរសក្លូវស្រែឆ្លើយថា:

– ដូចម្ដេចក៏មិនឲ្យខ្ញុំមិនសប្បាយចិត្តនឹងវាសនារបស់ខ្ញុំ បើមួយថ្ងៃៗ ខ្ញុំដើរតែពីខាងក្រោយនង្គ័ល តាំងពីព្រលឹមទល់ព្រលប់ ហើយចិញ្ចឹមជីវិតតែដោយផលដែលកើតឡើងពីខំធ្វើការយកញើសតាំងទឹក? ចំណែកជនដ៏សេសនៅតែក្នុងគ្រឹះស្ថានយ៉ាងត្រជឹម កល់ថ្ងៃគេសប្បាយចិត្ត ដេកលើគ្រែស្ពុទតែពូកទន់ល្មើយ គេរស់នៅកណ្ដាលសុខុមភាពក្រៃបំផុត គ្មាន ៗ ឧបំជាអាក្រក់មែន ដែលដូនតាដើមរបស់យើងបណ្ដាលសេចក្ដីទុក្ខលំបាកឲ្យមានដល់ខ្ញុំ ព្រោះតែការបះបេសមុខរឹងរបស់លោក ៗ ដ្បិតថា បើលោកកុំតែទទួលទានផ្លែឈើដែលគេហាម នោះសមយើងនឹងមានសេចក្ដីសប្បាយនៅលើផែនដី ដូចជានៅស្ថានសួគ៌ដែរ ៗ យើងមិនចាំបាច់រកស៊ីដើម្បីចិញ្ចឹមជីវិតផង ៗ ជីវិតយើងនឹងប្រព្រឹត្តទៅនាកណ្ដាលនៃសេចក្ដីសុខ ៗ បើប្រសិនខ្លួនខ្ញុំជាអាដាំវិញ នាងអេវមិនមែនអាចទួចអង្វរខ្ញុំបានទេ ទោះបីចង់យ៉ាងណាក៏ដោយ ខ្ញុំត្រូវធ្វើជាគ ជាថ្លង់ ខ្ជាប់ក្រងខ្ជួបសេចក្ដីសុខរបស់ខ្ញុំ ៗ

ចំណែកនាងជាភរិយាក៏អនុម័តតាមប្ដី ហើយពោលថា:

— ខ្លួនខ្ញុំក៏មិនបណ្ដោយឲ្យ[១]សត្វពស់បញ្ឆោតបានឡើយ ។ ខ្ញុំត្រូវខំតស៊ូទប់នឹងចំណង់គ្រប់យ៉ាង នោះបើគេយកពាក្យផ្អែមដូចទឹកឃ្មុំមកលួងលោមក៏ដោយ ។ ប្រាកដមែន រឿងនេះរាប់ពិតណាស់ទៅហើយ ដែលថាអាដាំនឹងនាងអែវជាមេបង្កើតសេចក្ដីទុក្ខដល់មនុស្សជាតិ ។

នាងម្ដាយនិយាយថា:

— អ្នកទាំងពីរនេះហាក់និយាយដូចមនុស្សល្ងង់ ។ អ្នកនឹងធ្វើដូចដូនតាយើងដែរជាមិនខាន គឺថាអ្នកមិនអាចទប់នឹងចំណង់ដ៏ធំនោះបានដែរ ។ ចូរដឹងថាជាតិមនុស្សមានចិត្តទន់ខ្សោយ ហើយរមែងទោរទន់ទៅរកតែអំពើអាក្រក់ នៅលើផែនដីគេរកមនុស្សធ្វើនូវអំពើជាកុសលស្ទើរគ្មានម្នាក់ទេ ។ មិនត្រូវយើងថ្កោលទោសអ្នកដទៃឡើយ វេលាដែលយើងមុខជាចៀសវាងមិនបានដែរ បើប្រសិនជាយើងនៅត្រង់កន្លែងនោះ ។

អេលីដែលបានស្ដាប់នូវសំដីឆ្លងឆ្លើយនៃជនទាំងពីរ ដោយស្ងៀមស្ងាត់ជាយូរមកហើយ ក៏មានវាចាចំពោះយាយតាស់ថា :

— ក្នុងរវាងអាយុយាយតាំងពីក្មេងដល់ចំណាស់នេះ គេយល់ច្បាស់ថាយាយបានមានការពិសោធន៍យ៉ាងជាក់លាក់អំពីរឿងមនុស្សជាតិ ។ តាមការពិត យាយទើបនឹងបង្ហាញនូវគុណសម្បត្តិដ៏ថ្លៃថ្លារបស់យាយ

---

១ មិនដឹងសត្វពស់បានប្រព្រឹត្តបទប្រការម្ដេចចំពោះនាងអែវកាលក្នុងបឋមកប្ប? ។

ឲ្យឃើញថា យាយមានការអត់ឱនចំពោះសេចក្ដីទន់ខ្សោយនៃអ្នកដទៃ ។ រួចងាកឆ្ពោះទៅរកបុរសប្ដីប្រពន្ធ លោកនិយាយតទៅទៀតថា: ចំណែកអ្នកទាំងពីរ មិនយូរទេ គង់នឹងប្រទះនូវឱកាសណាមួយដែលបញ្ជាក់ឲ្យឃើញថាតើអ្នកនឹងអាចទប់នឹងចំណង់បាន ឬមិនបាន ?

លុះនិយាយដូច្នោះរួចហើយ លោកអេលីនឹងសិស្សដើរចៀសចេញទៅ ។

រហ័សភាពតាំងនៅអស់មួយស្របក់ធំ រួចទើបម្ដាយនៃបុរសចាប់ពោលទៀតថា:

– មនុស្សដែលទើបនឹងនិយាយជាមួយនឹងយើងអម្បាញ់មិញនេះ មិនគឺជាមនុស្សសាមញ្ញទេ ។ សំដីសំដៅមានទំនងដូចជាអ្នកមកពីស្ថានលើ ។

កូនឆ្លើយតបមកវិញ ដោយសំដីចំអកឲ្យថា:

– ពីព្រោះគេសរសើរម៉ែឯង ចឹកម៉ែឯងមិនស្មានថាគេជាអ្នកស្ថានលើ ខ្ញុំទាស់សោះដោយមិនបាននិយាយពាក្យល្អទៅរកគេ ។ ខ្ញុំសួរម៉ែឯង តើអ្នកទាំងពីរមានសិទ្ធិពីណាមកលាយឡំនឹងយើង ធ្វើហាក់ដូចជាគ្រូអាចារ្យ ? ខ្ញុំគ្មានត្រូវការនឹងដំបូន្មានរបស់គេសោះ !

ម្ដាយឆ្លើយថា:

– នែកូន ស្ងៀមទៅ កុំខឹង ។ គេនឹងប្រាប់ថាសេចក្ដីអាក្រក់ដល់ឯងក៏ទេដែរ ។ យើងអាចទុកគេជាមិត្តភក្ដិរបស់យើងបាន ព្រោះគេចេះធ្វើយើងឲ្យស្គាល់ទោសរបស់យើង ។

បុរសនោះនៅងឿង ។ តែម្នាក់ឯង រួចក៏ចាប់ផ្លូវដើរទៅទៀត រឹតតែឆ្ងាយ គោឥតត្រាប្រណី ឯស្ត្រីទាំងពីរនាំគ្នារៀបប្រដាប់ប្រដាដើម្បីវិលត្រឡប់ទៅផ្ទះ ។

នគ្គលក្ខរមិនទាន់ទាំងបានកន្លះគន្លងផង ស្រាប់តែទាក់ជ៊ក់ អ្នកស្រែក្រឡេកទៅឃើញហិបដែកមួយក្នុងដីអាចម៍បំណាះ ។ ងឿងឆ្ងល់ពេក គេឈរមើលកំណាប់នោះ ហើយឃើញមានអក្សរចារឹកនៅលើគម្រប ។ គេចាប់យករបស់នោះឡើង មានលេខហិបទីពីរមកទៀត រួចទី ៣ ! ។ ខណៈនោះ គេស្រែកហៅស្ត្រីទាំងពីរ រួចបង្ហាញរបស់ ។ មិនយូរប៉ុន្មាន គេមើលដឹងសេចក្ដីនៅលើគម្របហិបទីមួយថាដូច្នេះ :–

“ អ្នកណាបើកអញ នឹងទៅជាអ្នកមានសម្បត្តិ ”

ម្ដាយស្រែកថា :

– មើច ! អញមិនមែនបានប្រាប់ឯងថា មនុស្សដែលទើបនឹងចេញពីយើងទៅ គឺជាអ្នកបំរើព្រះអាទិទេព ! លោកមកធ្វើឲ្យយើងមានហើយ ។ ឯងបើកហិបទៅមើល មុខជាប្រទះកំណាប់ទ្រព្យមិនខាន ។

បុរសនោះឥតបង្អង់យូរ ហើយក៏ឆ្កឹះគម្របចេញ ។

គេស្រែកដោយសេចក្ដីរីករាយថា:

– ម៉ែថាត្រូវមែន គឺទេព្ដាបញ្ជូនសម្បត្តិទ្រព្យមកឲ្យយើងប្រាកដ ៗ ឃើញឬទេ សុទ្ធតែប្រាក់រៀលភ្លឺចិញ្ចាច! យើងមានហើយ! ខ្ញុំមិនជឿសោះ ថាមនុស្សចំឡែកនោះផ្ដល់ភោគទ្រព្យដល់យើង ៗ យើងមើលទៅទឹកមុខគេមិនសមជាអ្នកមាន ៗ ការណ៍នេះគឺជាវាសនាយើងទេ មិនគឺអ្វីដទៃឡើយ ៗ ឥឡូវអញគិតសង់ផ្ទះមួយ តូចល្មម យ៉ាងល្អ ណោះមនុស្សម្នាក់មកឲ្យធ្វើការជំនួស រួច ពីថ្ងៃនេះទៅអញអស់ព្រួយហើយ ៗ

ប្រពន្ធនិយាយថា:

– បំណែកខ្ញុំ ៗ គិតទិញសំពត់យ៉ាងល្អ ៗ និងណោះឈ្នួលស្រីម្នាក់ដែរ មកឲ្យធ្វើការផ្ទះជំនួស ៗ

ប្ដីនិយាយកាត់ថា:

– ណ្ហើយឈប់គិត យើងពិនិត្យហិបទីពីរ តើមានអ្វី!

ឯហិបនេះធ្ងន់ជាងហិបមុន ហើយមានចំណងជើងថា:

“ បើមាសអាចធ្វើឲ្យឯងសប្បាយចិត្ត ចូរបើកអញចុះ ”

អ្នកស្រែក៏ស្រែកថា:

– យ៉ើអើប្រស្នាអីចេះ! ដូចជានៅមានការណ៍សង្ស័យ! បើគេមានទ្រព្យកាលណា ទៀងតែគេសប្បាយកាលនោះ ៗ

ម្ដាយនិយាយកាត់ទៀងថា.

– នែកូន ! សំដីដែលឯងនិយាយនេះ នឹងយកជាត្រឹមត្រូវមិនទាន់បានទេ ។ សុខភាពមិនទុកជាទ្រព្យមួយដ៏វិសេសជាងមាសក្នុងលោកទេឬ? “ការគ្មានរោគជាបរមលាភ” (ព្រះពុទ្ធ) ។ មានទ្រព្យច្រើនប្រយោជន៍អ្វី បើយើងមិនសប្បាយចិត្ត ?

ប៉ុន្តែកូនឥតមានឆ្លើយថាអ្វីសោះ ។ អត់ទ្រាំមិនបាន គេបើកហិបទីពីរក្រោម ។

គ្រាន់តែគម្របខ្ទាតចេញ គេសប្បាយស្ទើរបាត់ស្មារតី ។ គេរាំខ្ទេងដើរជុំវិញហិប ពេញដោយមាសក្រហមព្រាលភ្លឺចាំងនឹងរស្មីព្រះអាទិត្យ ។ ឃើញដូច្នោះ ប្រពន្ធចេញរាំដូចប្ដីដែរ ។ ម្ដាយភ័យតក់ស្លុតនឹងកូនខ្លាចក្រែងឆ្កួត ក៏ទៅស្ងៀមស្រឡាំងកាំងតែម្នាក់ឯង ។ គាត់ខំរកឧបាយស្ទើរតែនឹងមិនបានសម្រេច ដើម្បីបង្អង់នូវចិត្តឈ្លក់នេះ ។

ជាទីបំផុតបុរសនោះមុខក្រហមដូចភ្លើង ស្រែកឡើងថា:

– អម្បាញ់មិញ អញនិយាយថាម៉េច ? ផ្ទះមួយល្អ ? ទេ គឺប្រាសាទទេតើ ប្រាសាទស្អាតល្អដូចរបស់ស្ដេច ក្រាលថ្មកែវ ជញ្ជាំងធ្វើពីឈើបេង ។ អញចេញទៅណាស្លៀកពាក់យ៉ាងល្អឆើត ក្នុងរថមួយមានក្បាច់រចនាយ៉ាងវិសេស មានមនុស្សនាំមុខហាសិបនាក់ ។

ប្រពន្ធនិយាយថា:

ចំណែកខ្ញុំ ៗ ស្លៀកពាក់ដូចប្រពន្ធស្ដេច ខ្ញុំពាក់សុទ្ធតែចិញ្ចៀនពេជ្រ ពាក់ក្បាំងមាសប្រដាប់ដោយត្បូងដ៏មានដំឡៃអស្ចារ្យ ។

ម្ដាយស្រែកឲ្យថា:

– នែកូនកល់គ្នា! នែកូនកល់គ្នា! ទេព្ដាបានប្រទានដល់អ្នក នូវកំណាប់ទ្រព្យដ៏ធំ ដែលមានសភាពមិនគួរដល់អ្នកសោះ ។ ឥឡូវ កូនពប់ចូលជាអ្នកមានទ្រព្យនឹងគេមួយក្នុងស្រុកហើយ ។ ប៉ុន្តែម្ដាយបានឮកូននិយាយ ហាក់ដូចជាកូនចង់ប្រើប្រាស់សម្បត្តិនេះតែម្នាក់ឯង ។ អីកូនមិននឹកដល់អ្នកកំសត់ទុគ៌តផងទេឬ?

ប៉ុន្តែបុរសប្ដីប្រពន្ធមិនអើពើនឹងប្រឹងស្ដាប់សំដីខាងលើនេះសោះ ។

ក្នុងទីបំផុត ប្ដីស្រែកថា:

– ឥឡូវត្រូវមើលហិបទីបីទៀត !

គេចាប់ផ្ដើះគម្របមួយរំពេច តែបើកមិនរួច ។ គេពោលថា:

– នៅក្នុងហិបនេះ ប្រហែលសុទ្ធតែពេជ្រដាំងគ្រាប់ និងត្បូងមានដម្លៃហើយមើលទៅ យើងទៀងតែមានទ្រព្យច្រើនជាងស្ដេចផែនដីជាប្រាកដ ។ ចុះហេតុអ្វីអញក៏មិនទៅជាស្ដេចតែម្ដងឲ្យស្រេចទៅ? មានមកុដមាសយ៉ាងចិញ្ចែងនៅលើក្បាលទៅ ! មានអាណាប្រជារាស្ដ្រលុតជង្គង់នៅពីមុខ មានខ្ញុំកំដរជាអនេក ប្រុងអាត្មាចាំតែធ្វើតាមការស្ម័គ្ររបស់អញ បើគ្រាន់តែមានកូនសញ្ញាមកដល់ . . . ។

ប្រពន្ធស្រែកកាត់ឡើងថា:

— អ្នកមិនទុកឲ្យខ្ញុំនិយាយផងទេឬ? សម្បត្តិនេះសម្រាប់តែអ្នកម្នាក់ឯងទេឬ ? អ្នកពេញជាអត្តទត្ត[១]បុគ្គលប្រាកដ ៗ ទ្រព្យពាក់កណ្តាលត្រូវបានខ្ញុំ ៗ មានសិទ្ធិយកមកប្រើប្រាស់តាមអំណាចចិត្តខ្ញុំ ៗ ខ្ញុំរើសយកពេជ្រ អាណាដែលល្អជាងគេមកបំពាក់ដៃនឹងកខ្ញុំ ហើយត្បូងអាណាគ្រាប់ធំ ៗ មកចាត់ចែងធ្វើជាម្កុដមួយល្អចិញ្ចែង ៗ ខ្ញុំស្លៀកតែសំពត់ណាដែលព្រះមហេសីនៃព្រះករុណាមិនដែលទ្រង់ ៗ ខ្ញុំផ្ចាញ់ព្រះមហេសីទាំងឡាយលើផែនដីទាំងមូល ដោយពន្លឺរស្មីនៃគ្រឿងអលង្ការរបស់ខ្ញុំ ៗ

ចំណែកប្រពន្ធកំពុងតែស្រវឹងដោយសំដីអាត្មា យ៉ាងដូច្នេះ ប្តីខំប្រឹងកកេះកកាយគ្រប់ហិប ហើយបានឃើញអក្សរចារិកនៅនោះ ៗ គេស្រែកឲ្យប្រពន្ធថា:

— មេចំកួត កុំមាត់ ! បំណងដែលឯងនឹកនោះ ប្រហែលមិនបានសម្រេចទេ ៗ ឯងចាំស្តាប់អញអានចារិកអក្សរនៅលើគ្រប:

“ អ្នកណាបើកអញ ត្រូវវិនាសបាត់ទ្រព្យដែលបានរួចហើយ ” អញមិនមែនភ្លើទៅបើកឲ្យខូចមាសនឹងប្រាក់អញទេ ៗ អញជឿថា អ្នកឆ្លាតយល់ដឹងការណ៍ត្រូវយកហិបនេះទៅកប់ចោលវិញ ហើយឈប់នឹកនាឲ្យសោះ ៗ

ប្រពន្ធឆ្លើយថា:

---

១ អត្តទត្តបុគ្គលៈ មនុស្សដែលគិតតែប្រយោជន៍ចំពោះខ្លួន ៗ

— ក្អើ ! ឯងក្អើរួចស្រេចហើយទេតើ ដែលមិនចង់ដឹងរឿងនៅខាងក្នុងហិបនេះ ។ បើសាបចិត្តអាក្រក់ឈ្នានិះនឹងវាសនាយើង មានបំណងចង់បំផ្លាញសម្បត្តិទ្រព្យយើងដែលមាននៅក្នុងហិបនេះ ។ បើបើកទៅទទេ យើងមានខាតអ្វី ខាតតែកម្លាំងទេតើ ។ អ្នកនិយាយថាម៉េច ! ថាអន្តរាយរបស់ពីមុនដែលយើងបានហើយ? នៅជិតយើងគ្មានអ្នកដទៃទេ បើប្រសិននរណាមួយដើរមកក្បែរ ហើយប្រាថ្នាចង់បានសម្បត្តិយើង ខ្ញុំកាប់មួយពូថៅភ្លាមដោយឥតអាណិត ។

ខណៈនោះប្តីនៅតែរញួក ។ គេចង់យកហិបទៅកប់ទោលក្នុងដីវិញជាច្រើនលើកច្រើនគ្រា ។ ប៉ុន្តែប្រពន្ធទទូចហើយទទូចទៀត ម្តងអង្វរ ម្តងកំហែង ទាល់តែប្តីសម្រេចដាច់ចិត្តព្រមបើក ទោះបីម្តាយហាមឃាត់យ៉ាងដូចម្តេច ដោយពន្យល់ឲ្យសុខចិត្តត្រឹមតែមាសប្រាក់ដែលបានហើយក៏ដោយ ។ ប្តីប្រពន្ធចំរួមកម្លាំងគ្នាដើម្បីឆ្កឹះគម្របនោះឲ្យរបើក ។ ខាងក្រោយការខំប្រឹងស្ទើរដាច់សរសៃរៀងខ្លួនគ្រប់ហិបក៏របើកយ៉ាំងឡើង ។

ឥឡូវគម្របហិបរបើកហើយ មេឃដែលកំពុងតែភ្លឺថ្លាថែស ត្រឡប់ជាមានពពកខ្មៅខ្លួលមួយរំពេច ។ ភ្លៀងព្យុះយ៉ាងខ្លាំងក៏តាំងឡើង ផែនដីញាប់ញ័រឥតឧបមា ។ ប្តីប្រពន្ធភ័យតក់ស្លុតដួលសន្លប់បាត់ស្មារតី ។

លុះជនទាំងពីរត្រឡប់ដឹងខ្លួនឡើងវិញ ហិបមាសនឹងហិបប្រាក់វិនាសបាត់ ហើយមានផ្សែងយ៉ាងខ្មៅក្រាស់ហុយចេញពីក្នុងហិបទីបី ។

ស្វាមីភរិយាសំឡឹងមើលផ្សែងនោះទាំងព្រួយ ហើយបានឃើញរូបភាពមនុស្សពីរនាក់ធំក្រៃលែងនៅខាងក្នុង ។ គឺអាដាំនឹងអែវស្លៀកដណ្តប់ស្បែកសត្វឈរនៅទីនោះចំពីមុខ ។

មានឮសូរសំឡេងនិយាយថា:

– អ្នកបានធ្វើខុសនឹងវិញ្ញាសា(១)នៃអ្នក ។ ពីពេលនេះទៅត្រូវប្រយ័ត្ន កុំប្រដៅអ្នកដទៃមុនប្រដៅខ្លួនឯង ។ រឿងដែលកើតមានដល់អ្នកនេះ ប្រាកដដូចជារឿងដែលកើតមានដល់បុត្រជននៃអ្នកកាលក្នុងសម័យស្ថានសួគ៌នៅលើផែនដីដែរ ។ អ្នកឯងក៏ត្រូវធ្លាក់ក្នុងអំណាចនៃចំណង់ដែរ ។

រួចរូបភាពដ៏ធំទាំងពីរក៏អន្តរធានបាត់ទៅមួយអន្លើនឹងផ្សែង ។ គេឃើញតែហិបទទេស្ថិតនៅលើដីអាចម៍បំណះ ជាចំពោះមុខនៃជនទាំងបីដែលកំពុងតក់ស្លុត គឺប្តីប្រពន្ធនឹងម្តាយ ។

នាងម្តាយបានដឹងខ្លួនមុនគេ នាងចាប់ដៃកូនទាំងពីរដោយសេចក្តីស្នេហា ហើយពោលថា:

– ចូរកូនកុំព្រួយឲ្យសោះ អំពីរឿងទ្រព្យសម្បត្តិដែលកើតមានដល់អ្នកភ្លាម ៗ ហើយវិនាសទៅវិញក៏ដូច្នោះដែរនោះ ។ ចូរឈប់ជឿថាសម្បត្តិទ្រព្យជាប្រភពឯកនៃសេចក្តីសុខទៅ ។ អ្នកណាដែលសុខចិត្ត

---

១ វិញ្ញាសាៈអំពើឬអារម្មណ៍កើតមានឡើង ហើយយើងត្រូវតែទទួលដើម្បីបញ្ជាក់អំពីកំឡាំងប្រាជ្ញានិងចិត្តរបស់យើង ។

នឹងកសនាខ្លួន អ្នកនោះឯងហើយឈ្មោះថាជាមនុស្សមានសេចក្ដីសុខដ៏ពិត ។

មួយឆ្នាំកន្លងទៅប្រហែលអេលីនឹងសិស្សអេលីហៀ បានមកត្រង់កន្លែងស្រែនេះម្ដងទៀត ។ មានទស្សនីយភាពមួយកើតឡើងនៅចំពោះមុខលោក ។ លោកបានប្រទះជនទាំងពីរនាក់ម្ដងទៀត ម្ដាយកំពុងរៀបចំអាហារភោជនដើម្បីនឹងទទួលទាន ។ ប៉ុន្តែគេមានការៈមួយថ្មីទៀត គឺទារកដែលគេនាំគ្នាសំឡឹងមើលមុខដោយស្នេហាភាព ។

បុរសជាប្ដីចាប់លើកកូនបី ហើយថើបប្រឡែងលេង ។ រួចគេអង្គុយចុះសប្បាយចិត្តនឹងម្ហូបអាហារដែលគេរៀបទុកសម្រាប់ឲ្យ ។ ពេលបាយរួច គេនាំគ្នាសូត្រធម៌សុំពរ ដោយអរគុណចំពោះព្រះអាទិទេព នឹងសេចក្ដីសុខទាំងប៉ុន្មានដែលព្រះអង្គផ្ដល់មកឲ្យ ។

ខណៈនោះ អេលីចូលទៅជិត ហើយផ្ដឹងសួរថា:

— យីអើ អ្នកខំធ្វើការងារបែកញើសហូរញើស តាំងពីព្រលឹមទល់ព្រលប់ ប៉ុន្តែ យើងឃើញអ្នកហាក់ជាសប្បាយរីករាយពន់ពេក ។ តើទ្រព្យសម្បត្តិរបស់អ្នកប្រកបដោយធម៌ ឬ?

អ្នកស្រែឆ្លើយថា:

— ឱព្រះគុណម្ចាស់ថ្លៃអើយ ខ្ញុំបាទស្គាល់ព្រះគុណច្បាស់ ហើយ ៗ ចុះចាំបាច់សួរខ្ញុំបាទធ្វើអ្វី? ព្រះគុណជ្រាបស្រាប់ហើយថា យើងខ្ញុំគ្មាន

ទ្រព្យសម្បត្តិប៉ុន្មានទេ ។ ប៉ុន្តែអម្រែស់អម្រែមប៉ុណ្ណឹងក៏បានហើយ គួរសមហើយ ។ ពីពេលនេះទៅ យើងខ្ញុំដឹងច្បាស់ថាតួនៃសេចក្តីសុខ មិនមែនស្ថិតនៅក្នុងភោគទ្រព្យទេ គឺនៅក្នុងការសុខចិត្ត ។ មែនពិត យើងខ្ញុំសព្វថ្ងៃ សុខសប្បាយគួរសមហើយៈ យើងខ្ញុំមានដំបូលគ្រាន់នឹងជ្រក មានបំការល្មមដាំដំណាំដើម្បីចិញ្ចឹមពោះដោយគ្រប់គ្រាន់ ។ ម្យ៉ាងទៀត ព្រះជាម្ចាស់បានផ្តល់សេចក្តីសុខមួយមកទៀតដែលលើសអ្នកដទៃ គឺព្រះអង្គឲ្យយើងមានកូនមួយជាទីស្នេហាដ៏ថ្លៃថ្លាជាងមាសប្រាក់និងត្បូងពេជ្រទាំងឡាយ ។

ប្រពន្ធឱបកូនដោយការថ្នាក់ថ្នម ហើយពោលថា :

— ប្រាកដមែន យើងសព្វថ្ងៃសុខហើយ !

ឯម្តាយនិយាយដោយសំដីព្រឺព្រួចថា :

— ឥឡូវនេះ ខ្ញុំអាចទទួលមរណភាពដោយបិទភ្នែកជិតហើយ ពីព្រោះខ្ញុំបានឃើញកូនខ្ញុំសុខសប្បាយ ។

ពេញចិត្តដោយបានទាញមនុស្សទាំងពីរនាក់មកដាក់ក្នុងផ្លូវត្រង់ល្អ អេលីនឹងសិស្សអេលីហ្ស៊េ លាដៃឲ្យពរហើយក៏អន្តរធានបាត់ទៅ ។

សេចក្តីបញ្ចប់ : សូមអ្នកអានទាំងឡាយជ្រាបៈ ដែលជាតួនៃសេចក្តីសុខ នៅត្រង់ការពេញចិត្តនឹងវាសនារបស់ខ្លួននោះ មិនគឺជាឧទាហរណ៍ឲ្យយើងពល់គ្នាខ្ជិលច្រអូសក្នុងការងារទេ គឺមានសម្បត្តិប៉ុន្មាន

ហើយ គិតតែដេកអាស្រ័យសម្បត្តិប៉ុណ្ណោះដោយអាងថា “ បើមានមិនបាច់ខំ បើរលំមិនបាច់ប្រាន ” ។ យើងត្រូវតែខំបំពេញការងារតាមឋានៈរៀងខ្លួន តែក្នុងរឿងធ្វើការងារនេះ យើងមិនត្រូវញុំាងចិត្តប្រណែនឈ្នានិះឲ្យកើតមានចំពោះជនដែលមានឋានៈខ្ពង់ខ្ពស់ជាងខ្លួនឡើយ ។ សូមប្រាបថា: ភោគទ្រព្យកើតមាន ដោយអាស្រ័យហេតុពីរយ៉ាងគឺ ១-ការសេពគប់ ២-កិច្ចការ សុភាសិតបាកំងថា: “ ឯងធ្វើទៅ ទើបទេព្តាជួយ ” ។

ជើង-ជ្រឿវ

# ហ៊ាំមិនងុយដេក

មនុស្សយើងរស់នៅបានដោយអាហារបរិភោគ, ដោយដកដង្ហើម, ដោយឥតពេក...(ល) ព្រមទាំងដោយប្រើកិរិយាបថបួន ដេក, ដើរ, ឈរ, អង្គុយ ឲ្យស្មើៗគ្នាផង ។

កើតជាពាក្យសួរឡើងថា មនុស្សយើងបើមិនដេក គឺថាបើមិន "បញ្ឈប់អារម្មណ៍សម្ងំឲ្យលក់" តើបានឬទេ?

មនុស្សក្នុងពិភពលោក ដែលមិនមែនជាពុទ្ធមាមក: បានធ្វើពិសោធន៍ជាច្រើនអំពីបញ្ហានេះ ។ ខ្ញុំសូមនាំយកឧទាហរណ៍ពីរមកនិទានដូចតទៅនេះ :-

១– ក្នុង គ.ស.១៩២៧ មានពួកនិស្សិតប្រុសស្រីជាច្រើននៅទីក្រុងប៉ុណ្ណសិលវ៉ានី (អាមេរិក) បានស្រុះគំនិតប្រឡងគ្នាអត់ងងុយ ។ ក្មេងទាំងនោះសុទ្ធតែជាពាលពេញកម្លាំង តាំងលើកដៃព្រមគ្នាថា "យើងមិនត្រូវដេកចាប់តាំងពីម៉ោង ៦ ព្រឹកនេះតទៅ" ។

និស្សិតទាំងនោះចាប់អត់ងងុយ ខ្លះបានមួយថ្ងៃមួយយប់, ខ្លះបានពីរថ្ងៃពីរយប់ឈប់ទៅ នៅតែនិស្សិតប្រុសមួយស្រីមួយពូកែជាងគេ អត់ងងុយបានបួនយប់បួនថ្ងៃ នៅញញឹមដាក់គ្នានៅឡើយតែមុខស្លេកដូចត្រីឈ្លក់ទឹក សំឡឹងគ្នាធ្វើភ្នែកម៉ក់ៗ ឥតណាចាញ់ណា ។ តែដល់យប់ថ្ងៃ

ទី ៥ ដល់មកក្មាម គិតទៅបាន ១០៨ ម៉ោងគត់ និស្សិតស្រីស្រាប់តែដួលស្រុសដេកលក់តែម្តងមិនដឹងខ្លួនប្រាណ មានតែដង្ហើមដូចស្ងប់ ។ ចំណែកឯនិស្សិតប្រុសនៅបើកភ្នែកបានក្រឡេតទៅឡើយ តែមើលអ្វីមិនឃើញ ស្តាប់អ្វីមិនឮតទៅទៀតបាន១២ម៉ោងគត់ គិតទៅបាន១២១ម៉ោងក៏ដួលស្រុសទៅទៀតទៅទាំងប្រុសទាំងស្រីដេកលក់៥ថ្ងៃ៦យប់គឺ ១៣២ ម៉ោងម្នាក់ទើបភ្ញាក់ដឹងខ្លួនឡើងវិញ; ក្នុងពេលដេកលក់នោះចេះជញ្ជក់ទឹកទឹកដោះគោដែរតែមិនភ្ញាក់ ។

២ – ឧទាហរណ៍ទី ២ មានបណ្ឌិតម្នាក់ជាតិអូទ្រីស (អល្លឺម៉ង់) ឈ្មោះឧត្តុប្រីឌែរ កាលពីរបីឆ្នាំកន្លងថ្មីៗនេះ ក៏បានអត់ងងុយពិសោធមើលដែរ ។

យប់ទី ១ រាងម៉ោងបីទៅម៉ោងប្រាំក្តី មានញ័រទ្រូងអស់កម្លាំង តែដល់ព្រឹកឡើងក៏ស្រួលខ្លួនឡើងវិញជាធម្មតា ។

ថ្ងៃទី ២ និងយប់ទី ២ នៅពេលម៉ោងដែលដូចខាងលើនេះ មានផ្សាភ្នែកយ៉ាងខ្លាំង ។

ថ្ងៃទី ៣ និងយប់ទី ៣ ឮគេនិយាយជិតៗខ្លួន ឃើញគេឃើញឯងដែរ តែចេះតែកាំងៗភ្លេចៗខ្លួន ដូចជាមឹងមាំងៗ ចាំកាប់ដៃកាប់ជើងលមើល ក៏មិនកើតចេះតែភ្លេចមុខភ្លេចក្រោយមិនបានការ ។

ថ្ងៃទី ៤ នឹងយប់ទី ៤ បណ្ឌិតនេះចំត្រដរដៃទាំងពីរ ៗ យកក្រដាស មកកត់តើមានអ្វីខ្លះក្នុងខ្លួន សរសេរមិនកើតញាក់ដៃលែងកើតតាមចិត្តខ្លួន បណ្ឌិតនេះបីខែក្រោយមក បានធ្វើពិសោធន៍នេះម្តងទៀត ឃើញបាន លទ្ធផលដូចមុន គឺអត់ដង្ហើមបានតែ ១១៥ ម៉ោង ក៏ដួលគ្រែងឥតដឹងខ្លួន ដេកលក់ទៅវិញសងជា ១២០ ម៉ោង ។

តមកបណ្ឌិតនេះបានប្រកាសថា នឹងរកថ្នាំកុំឲ្យងងុយដេកបាន តែក្នុងពេលនេះគេមិនទាន់ឃើញនៅឡើយទេ ។

រឿងនេះ យើងជាពុទ្ធមាមកៈយើងមិនមានឆ្ងល់ទេ ។ ចំពោះព្រះពុទ្ធជាម្ចាស់យើង សេចក្តីជាបាលីថា "បុព្វណ្ហ បិណ្ឌបាតញ្ច ... ជាដើមគឺ :

ក) ពេលព្រឹកព្រះសម្ពុទ្ធជាម្ចាស់ទ្រង់យាងបិណ្ឌបាត;

ខ) រសៀលទ្រង់ទេសនា;

គ) ព្រលប់ទ្រង់ព្រះទានឱវាទដល់ភិក្ខុបរិស័ទ;

ឃ) អធ្រាត្រទ្រង់ដោះប្រស្នារបស់ពួកទេវតា;

ង) ទៀបភ្លឺទ្រង់រំពឹងដល់សត្វ ដែលគួរប្រោសនឹងមិនគួរប្រោសបាន ។

ត្រង់វគ្គអក្សរយ៉ាកាសាបាលីថា "អឌ្ឍរត្តេ ទេវបញ្ហំ" បទនេះនឹងបានសេចក្តីថា ព្រះអង្គទ្រង់បញ្ជប់អារម្មណ៍សម្ងំឲ្យរលត់យ៉ាងនេះ

ក៏ទេដែរ; បើតាមខ្ញុំយល់ថា ក្នុងពេលនេះ ព្រះអង្គទ្រង់ជ្រាបព្រះអង្គជានិច្ច បានជាទ្រង់កែបញ្ហាពពួកទេវតាបាន សេចក្ដីម្យ៉ាងទៀតថា ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រព្រឹត្តជាប់ជានិច្ចកាល នូវព្រះកិច្ច ៥ យ៉ាងខាងលើនេះ ទឹងមានមនុស្សទេវតាឥន្ទព្រហ្មណា ឲ្យដូចព្រះអង្គនោះគ្មានឡើយ ហើយទ្រង់ប្រព្រឹត្តកិច្ចនេះ ដោយឥតមានបន្ធូរបន្ថយ កំណត់ ៤៥ ព្រះវស្សា ត្រាតែព្រះអង្គទ្រង់យាងកាន់ព្រះនិព្វានទៅ ។ ចុះបើការណ៍នេះដូចជាបុះក្នុងការណ៍មិនប្រក្រតី ខ្ញុំនៅតែជឿជាក់ថា ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់អាចកាន់បាន ប្រព្រឹត្តបាននូវកិរិយាមិនបញ្ជាប់អារម្មណ៍សម្ងំឲ្យលក់ សូម្បីតែព្រះអរហន្ត, ព្រះបច្ចេកពុទ្ធក៏លោកមិនអាចបញ្ជាប់អារម្មណ៍សម្ងំឲ្យលក់កើតដែរ; បើលោកដុកទ័រប្រឺឌែរជាដើមចង់ដឹង សូមប្រឹងលះបង់ដំរង់ចេតនាប្រាថ្នាប្រព្រឹត្តតាមពាក្យប្រៀនប្រដៅ របស់ព្រះសម្មាសម្ពុទ្ធឲ្យមុតជ្រៅល្បងមើល បើនិស្ស័យដុកទ័រក្រាស់ដុកទ័រនឹងប្រទះជាំមិនងងុយដេកជាពិតប្រាកដមែនហោង ។

រ៉ាយ - ល្អុត

# បទភ្លេងភ្លៀងដើមឆ្នាំ

បទកាកគតិ

កង្កួកត្រពាំង គេស្រែកយ៉ាងខ្លាំង សូរសព្ទរងំ ដូចភ្លេងវង់ធំ ស្ដាប់អឺមិនទ្រ គេសប្បាយហើយ · ហាប្រៀងផ្ដោះផ្ដង ៗ អាក់គកដេអុង គឺពួកហ៊ីងកង្ក- ដើចេញចំគោន បំប៉ោងបង្កា ស្រែកថាហ៊ឹងហោង ហ៊ឹងហោងហ៊ឹងហោង លោតស្កាត់រកគ្នា ៗ សត្វនេះត្រអាល ភ្លៀងមកក្រសាល ត្រជាក់កាយា ចាប់កំឡាំជូន ប្រៀងឆោកសរសា ជំទយវេក ឆាករកដៃគូ ៗ ហ៊ឹងមួយពួកទៀត ខិតខំឆ្លាក់ឆ្មៀត ស្រែកប្រៀងធូរៗ គឺប័ក្សហ៊ឹងជា ប្រើនមង្កូត មិនសូវមានគូ ដូចជាហ៊ឹងដ័រ ៗ ក្រែត ៗ ក្រិត ៗ គឺសព្វបង្រិត បំប៉ោងស្វាបព្រាំរ ចូលផ្សំទឹងគេ ជាបទបទ្ធរ ប្រៀងឈប់ប្រៀងឈរ បន្ទរម្ដង ៗ ៗ រីឯគីងគក់ រូបរាងសក់ត្រក់ គ្រោតគ្រាតនាខ្ទង ស្រែកក្រតកាលណា ដូចមានវកពង ភ្លៀងមេឃុំគ្រង ប្រៀងគ្មានកំណាន់ ៗ យូរៗមួយគ្រា អ្នកៗផ្ទួនគ្នា ញាប់យ៉ាងរន្ទាន់ គឺមណ្ឌូកជាតិ ស្រែកព្រោងន់ ៗ ផ្សំឲ្យរង៉ាន់ បទតូរ្យតន្ត្រី ៗ ភ្លេងយើងវង់នេះ ប្រៀងកូតមិនបេះ ទាស់បទសំដី ហ៊ឹងហោងក្រែតក្រត ពេញមួយរាត្រី លេងអស់យាមបី គ្មានអស់កំឡាំង ៗ អរុណរះដល់ គេឃើញលទ្ធផល អណ្ដាតពាសទាំង ផ្ទៃទឹកត្រៀបត្រា កង្កួកត្រពាំង គឺជាកំឡាំង នៃជាងអវិជ្ជា ៗ

ផេង - គ្រីវ

# ចាបស្រុក

## បទកាកគតិ

រីបក្សីនេះ សម្បុរប្រផេះ លាយសូកូឡា ចំពុះខ្មៅស្រិល ប៉ុនវាត បក្សា ករុំលោមា សសុទ្ធមួយជុំ ៗ វាមានស្នេហា តែនឹងមនុស្សា វាធ្វើជំរុំ ពួដកៀនកោះ ក្រលៀតផ្ទាំងថ្ម ញកសំយាបរុំ ពទ្វ័ជាសំបុក ៗ ឬនៅក្នុងវន្ត ឬស្បីតត្រុន ជាគុហាគុក ឲ្យតែជាផ្ទះ សម្បែងបន្ទុក នៃមនុស្សវាសុខ ចិត្តព្រមប្រស្រ័យ ៗ ចាបនេះចំឡែក ចិត្តពុំកវែក ពុំគិតអាល័យ បើឃើញផ្ទះថ្មី ចូលនៅអាស្រ័យ គ្មានទឹកសង្ស័យ ដល់កន្ទ្វង់ចាស់ ៗ វាត្រេកត្រអាល វាចង់ក្រសាល តែប្រាសាទផ្ទះ ណាទើបសង់ថ្មី វាពេញចិត្តណាស់ យំចេបចាបដាស ពាសពេញដំបូល ៗ អាខ្លះស្រែកចិច អាខ្លះហើរប្រិច ទៅផ្តុំជុំមូល ជជែកឆ្លើយឆ្លង អាខ្លះស្រែកបួល ប្រិច ៗ ប្រាចប្រួល ស្ទុះហិចហើរលេង ៗ ប្រិច ៗ ប្រាលប្រឹល វាស្ទុះហើរកិល ក្អូតឥតគិតក្រែង ពីផ្ទះទៅដី ប្រឹកគ្នាលេង ផ្លូចផ្លូចដូចក្មេង ហើរទៅហើរមក ៗ រីឯអាហារ ក្បែរ ៗ គ្រឹះហា ដែលវានៅជ្រក គ្រាប់ស្រូវអង្ករ គ្រាប់ប្រាយជ្រុះស្អិក សំណល់សល់មក ពីដែលមនុស្សស៊ី ៗ ឬអង្ករបុង លាយឲ្យនៅក្នុង អង្កាមនាដី វាចឹកកកាយ ផាត់ផាយវែកវី ញាំងជីវិតិន្ទ្រិយ ឲ្យប្រព្រឹត្តបាន ៗ ចាបនេះនិរភ័យ ឥតមានសង្ស័យ ដល់ព្រេងអាត្ម័ន តែងតែទុកចិត្ត ប្រពៃចំណាន លើមិត្រកល្យាណ គឺមនុស្សគូតា ៗ

ផេង — ជ្រីវ

(តពីសៀវភៅលេខ ៣.៨.៩ ឆ្នាំ ១៩៥២)

---

# កថាទី ៩

## រឿងសីហៈនឹងទន្សាយ

ក្នុងព្រៃមួយ មានសីហៈមួយឈ្មោះភាសុរកៈ(១) អាស្រ័យនៅ ។ សីហៈនោះមានព្យាយាមក្លៀវក្លាណាស់ តែងដើរបរបាញ់សម្លាប់សត្វទាំង-ឡាយដ៏ច្រើនមានម្រឹគទន្សាយជាដើមជានិច្ច ។ ថ្ងៃមួយ សត្វទាំងឡាយដែលអាស្រ័យនៅក្នុងព្រៃនោះគឺៈ ម្រឹគ ជ្រូកព្រៃ ទន្សាយ ក្របីជាដើមមកប្រជុំប្រឹក្សាគ្នា ប្រឹក្សាហើយបបួលគ្នាទៅសុំជួបសីហៈនោះ ទៅដល់និយាយអង្វរករថា: " លោកម្ចាស់! ហេតុអ្វីក៏លោកចូលចិត្តសម្លាប់សត្វម្ដង ៗ អីច្រើនម្ល៉េះ បើលោកសម្លាប់តែមួយម្ដង ៗ ក៏អាចបំពេញផ្ទៃលោកឲ្យឆ្អែតបានដែរ? ហេតុដូច្នេះបានជាយើងខ្ញុំចូលមកសូមធ្វើសម័យធម៌ (កតិកសញ្ញា) ជាមួយនឹងលោក គឺថា ចាប់តាំងពីថ្ងៃនេះតទៅ លោកម្ចាស់នៅសម្រាកកម្លាំងស្ងៀមក្នុងទីនេះឲ្យបានសុខស្រួលចុះ យើងខ្ញុំនឹងបញ្ជូនសត្វមួយ ៗ មកជូនលោកជាអាហាររាល់ ៗ ថ្ងៃ បើលោកសម្រេចធ្វើតាមសន្ធិសញ្ញានេះ លោកម្ចាស់មិនព្រួយលំបាកនឹងដើរបរបាញ់ម្រឹគយកមកចិញ្ចឹមជីវិតលោកទេ ឯចំណែកខាងយើងខ្ញុំវិញ យើងខ្ញុំមិន

---

១ វីរបុរស ។

របស់ខូចខាតពូជធារផង         អំពើដែលធ្វើដូច្នេះសមទៅតាមរាជធម៌គឺ
ប្រវេណីស្ដេចផង, ព្រោះថា :

២១៥ – “ព្រះរាជាអង្គណា សោយរាជ្យ[១] បន្តិចៗ តាមសមគួរដល់កម្លាំងដូចជាគេប្រើថ្នាំឲ្យមានជីវិតរស់នៅយូរ ព្រះរាជាអង្គនោះ ជាអ្នកប្រាជ្ញអាចសម្រេចសេចក្ដីចំរើនដ៏ក្រៃលែង ។

២១៦ – ផែនដី សូម្បីក្រៀមក្រស់ កាលបើគេជួយទឹងប្រកបដីត្រឹមត្រូវតាមវិធីហើយ តែងនឹងឲ្យផលសមតាមប្រាថ្នា ដូចពំនូតភ្លើងឲ្យភ្លើងដូច្នោះ ។

២១៧ - ការគ្រប់គ្រងប្រជាជនទាំងឡាយដោយល្អ ជាមធ្យោបាយដ៏ប្រសើរដែលនាំទៅកាន់ឃ្លាំងគឺឋានសួគ៌, ការសង្កត់សង្កិនប្រជាជនខ្លាំងជាផ្លូវនាំឲ្យវិនាសសេចក្ដីចំរើន ឲ្យកើតសេចក្ដីអាក្រក់ទឹងការអត់ឃ្លាន ។

២១៨ – ព្រះរាជា ទុកដូចជាម្ចាស់គោ ត្រូវរឹតទឹកដោះគោគឺទ្រព្យសម្បត្តិបន្តិចម្ដងៗ អំពីប្រជាជនដែលទុកដូចជាមេគោ ត្រូវទុកទឹកដោះខ្លះគឺទ្រព្យខ្លះផង ព្រមទាំងចិញ្ចឹមប្រជាជនឲ្យរស់នៅផង ធ្វើដូចម្ដេចឲ្យប្រជាជនអាចមានជីវភាពគួរល្អមើលតាមទីតផង ។

២១៩ – ព្រះរាជាអង្គណា សម្លាប់ប្រជាជនរបស់ព្រះអង្គដោយការរឹបជាន់យកទ្រព្យសម្បត្តិតែម្ដងដូចជាគេសម្លាប់ពពែស៊ី ព្រះរាជាអង្គនោះ

---

១ គ្រប់គ្រងផែនដី ។

បានសោយតែមួយលើកទេ ដល់លើកទីពីរក្រោយ ចាំបាច់និយាយថ្វី
ឡើយ ហីនហោចហើយហោង ។

២២០ – ព្រះនរបតីដែលប្រាថ្នាផលគឺសេចក្ដីចំរើន គប្បីប្រយ័ត្ន ប្រយែងថែរក្សាព្រោះព្រៃប្រជាជនទាំងឡាយ ដោយទឹកគឺការព្រះរាជទាន និងការប្រោសប្រាណកប់អានជាដើម ដូចមាលាការស្រោចទឹកព្រោះព្រៃ ដើមឈើតូច ៗ ទាំងឡាយ ។

២២១ – ប្រទីបពោលគឺព្រះរាជា កាលដែលទាញយកប្រេងគឺ ទ្រព្យសម្បត្តិឥតមាននរណាមួយមើលឃើញទេ ដោយមានគុណសម្បត្តិ ដ៏ល្អដែលបិតនៅខាងក្នុង (ស្រាប់តែឃើញតេះក្ដីស្វាងគឺទ្រព្យតែម្ដង) ។

២២២ – ម្ចាស់គោ រីតយកទឹកដោះគោក្នុងកាលគួរ ហើយថែរក្សាគោ យ៉ាងណា ព្រះរាជាក៏គប្បីរីតយកទឹកដោះ គឺទ្រព្យពីប្រជាជនហើយថែរក្សា យ៉ាងនោះដែរ ឬដូចគេស្រោចទឹកដំណាំហើយទើបគេបេះយកផ្កាផ្លែ ។

២២៣ – ពន្ធកពូជល្អិតធ្មារណាស់ គេត្រូវថែរក្សាដោយប្រយ័ត្ន ជាបំផុតទើបបានផលទៅតាមកាលគួរមានឧបមាយ៉ាងណា ឯប្រជាជនក៏ ទុកជាពន្ធកពូជគេក៏ត្រូវរក្សាឲ្យល្អយ៉ាងនោះដែរ ទើបបានផលក្នុង កាលគួរ ។

២២៤ – ប្រាក់មាស ស្រូវអង្ករឬវត្ថុមានប្រការផ្សេង ៗ ទាំងឡាយ ពុំនោះវត្ថុទាំងឡាយដទៃផ្សេងទៀត ទាំងអស់នេះ ព្រះរាជា តែងបានមកពីប្រជាជនដោយពិត ។

៦២៥ - ព្រះរាជាទាំងឡាយ ដែលធ្វើសេចក្ដីអនុគ្រោះដល់ប្រជាជនទាំងឡាយ ទ្រង់តែងបានសេចក្ដីចំរើនពិតប្រាកដ កាលបើទ្រង់បំផ្លិចបំផ្លាញប្រជាជនទាំងឡាយឲ្យវិនាសហើយ ទ្រង់នឹងដល់នូវសេចក្ដីសាបសូន្យឥតសង្ស័យឡើយ" ។

កាលនោះ, កាសុរកៈបានស្ដាប់ពាក្យសត្វទាំងឡាយនេះហើយ ឆ្លើយតបភាមថា: " អើពាក្យដែលឯងទាំងឡាយនិយាយនេះពេញជាត្រូវណាស់ហើយ ប៉ុន្ដែបើយើងនៅតែទំនេរ មិនចេញទៅចាប់ម្រឹគទេ ហើយឯងទាំងឡាយក៏មិនបញ្ជូនសត្វមួយ ៗ មក ដើម្បីជាអាហារយើងរាល់ថ្ងៃទេ នុះត្រូវឲ្យយើងសម្លាប់ឯងទាំងអស់គ្នាវិញចុះ ទើបអញព្រម" ។ សត្វទាំងឡាយ ព្រមព្រៀងធ្វើកតិកសញ្ញា យ៉ាងនេះស្រេចហើយ នៅជាសុខសប្បាយក្សេមក្សាន្ដ ត្រេចចរទៅក្នុងពនាល័យខាងនេះខាងនោះ លែងខ្លាចរអែងរអាផ្លូវដូចកាលមុនឡើយ ។ សត្វណាដែលត្រូវជាសួយ គឺសត្វខ្លាចាស់ជរា ឬសត្វដែលចង់លះបង់តណ្ហាក្នុងលោកនេះពេល ពុំនោះសត្វដែលកើតទុក្ខព្រួយបៀតបៀន ពុំនោះសោកទៀត សត្វក្ដៅក្រហាយដោយទុក្ខពីការខូចបង់ប្រពន្ធកូនចៅ សត្វទាំងឡាយនោះតែងចូលទៅកាន់សំណាក់សីហៈរាល់ ៗ ថ្ងៃ ម្ដងមួយ ៗ ដើម្បីជាគ្រឿងបណ្ណាការដល់សីហៈ ។ ក្នុងកាលនោះ ទន្សាយមួយដល់វេនដោយលំដាប់ តែមិនចង់ទៅសោះ បើទុកជាខ្លួនមិនចង់ទៅក៏ដោយក៏សត្វទាំងឡាយ

ដាវៃទបន្ទិចឡើងទៅ ៗ ទន្សាយនោះចរចេញទៅតាំងទុក្ខព្រួយក្រៀមក្រំ ដើរសន្សឹម ៗ បន្តិច ៗ ដើរបណ្ដើរគិតរកឧបាយសម្លាប់សីហៈបណ្ដើរ ដល់ពាក់កណ្ដាលផ្លូវ ឃើញអណ្ដូងមួយទឹកថ្លាថ្លុះស្រះមោលយល់ដី កើតគំនិតភ្លាមថា "អាត្មាបានអណ្ដូងនេះហើយជាឧបាយសម្លាប់សីហៈនេះ" អាល័យតែគិតឃើតដំណើរទៅមិនទាន់ពេលដែលគេមត់គ្នាទុក ទាល់តែសាយណ្ហ-សម័យទៅហើយទើបបានទៅដល់សំណាក់សីហៈនោះ ។ ឯសីហៈនេះតែទន្ទឹងចាំមើលផ្លូវ ចាំបាត់ ៗ ណាមួយសេចក្ដីស្រេកឃ្លានកើតឡើងខ្លាំងផង ណាមួយវេលាដែលមត់គ្នាក៏កន្លងហួសផង ក៏កើតក្ដៅក្រហាយចិត្តខ្លាំងណាស់ នេះតែលិទ្ធបង្គូមហើយគិតថា: "ថ្ងៃស្អែកនេះ អញនឹងសម្លាប់សត្វទាំងឡាយនេះឲ្យអស់ពូជ កុំឲ្យសល់មួយនៅក្នុងព្រៃ" ។ ក្នុងពេលដែលសីហៈកំពុងតែត្រិះរិះគិតដូច្នេះ ទន្សាយទៅដល់ ដើរសន្សឹមៗចូលទៅក្រាបប្រណិប័តន៍ដោយអស្ដាក្គបាទ ហើយស្ថិតនៅចំពោះមុខសីហៈ ។ សីហៈ, កាលឃើញទន្សាយទៅដល់ហួសពេលវេលា ហើយមួយទៀតខ្លួនវាតូចជាងសត្វឯទៀតផង ក៏ក្រេវក្រោធប្រឡោតខឹងតូងរិតតែខ្លាំងឡើងរៃស្រែកគំហែងសន្ធាប់ទន្សាយថា: "នែអាចង្រៃ! អាឯងអីក៏ក្រមកដល់ម៉្លេះ? ខ្លួនឯងតូចហើយមកតែមួយផង មកដល់កន្លងហួសពេលមត់ទៀតផង ដោយហេតុដែលឯងមើលងាយអញយ៉ាងនេះ អញសម្លាប់ឯងមុនហើយថ្ងៃស្អែកអញនឹងសម្លាប់សត្វទាំងអស់ឯទៀតកុំឲ្យសល់

កូនតូចមួយ" ។ កាលនោះ ទន្សាយធ្វើជាភ័យញ័រ ក្រាបប្រណិប័តន៍
សីហៈដោយគោរពហើយនិយាយថា: "បពិត្រលោកជាស្តេចចតុប្បាទ!
រឿងនេះមិនមែនជាទោសខ្ញុំបាទទេ ជាទោសនៃអស់សត្វទាំងឡាយនោះទេ
សូមលោកម្ចាស់មេត្តាស្តាប់ពាក្យខ្ញុំបាទដំរាបលោកម្ចាស់សិន" ។ សីហៈ
ឆ្លើយគំរាមថា: "អើ! អាឯងនិយាយមកមើល! និយាយឲ្យឆាប់ៗ
ទៅ ថាម្តេច? មុនខ្លួនឯងមិនទាន់ចូលគងចង្កូមអញ" ។ ទន្សាយឆ្លើយ
ក្រាបថា: "សត្វទាំងអស់ផងឆ្បាស់ថា ថ្ងៃនេះត្រូវវេនខ្ញុំបាទតាមលំដាប់
តែដោយខ្ញុំបាទតូចពេក គេត្រូវជាះឲ្យទន្សាយ៥មកជាមួយផង កាល
ដែលខ្ញុំបាទនឹងទន្សាយ ៥ ទៀតបបួលគ្នាដើរមកនោះ បានជួបនឹងសីហៈ
មួយធំចេញមកពីរូងភ្នំហើយកំញើញយើងខ្ញុំថា: "នែទន្សាយ! ឯងបបួល
គ្នាទៅណាហ្នឹង? ឯងមិននឹកឃើញទេវតាប្រចាំខ្លួនឯងទេឬអ្វី?" ។
ពេលនោះ ខ្ញុំបាទឆ្លើយក្រាបថា: "បពិត្រលោក! យើងបបួលគ្នាទៅ
ធ្វើតាមកតិកសញ្ញាសីហៈជាម្ចាស់យើងឈ្មោះភាសុរកៈ ដើម្បីធ្វើជាចំណី
អាហារលោក" ។ សីហៈកំណាចនោះឆ្លើយតបយើងខ្ញុំវិញក្លាមថា:
"អើ! ព្រៃនេះជាអាណាចក្ររបស់អញ បើដូច្នេះ ចូរឯងទាំងអស់ធ្វើ
កតិកសញ្ញានឹងឲ្យសត្វជាអាហារអញផងទើបបាន ឯអាភាសុរកៈនេះវា
ជាចោរទេ ថាបើឯងយល់ថាវាជាស្តេចនៅក្នុងព្រៃនេះ ត្រូវឯងទុក
ទន្សាយ ៤ នៅទីនេះសិនជាស្នួយឲ្យយើងទុកចិត្ត ខ្លួនឯងទៅជួបវាតែម្នាក់

ឯងចុះ ឯងទៅហៅវាមក ហើយត្រឡប់វិលវិញ មកជួបយើងឆាប់ ដើម្បីល្បងមើលតេជដៃគ្នាឲ្យដឹង អ្នកណាមានថ្វីដៃ អ្នកនោះត្រូវបានធ្វើស្ដេច ស៊ីសត្វទាំងឡាយក្នុងទីនេះទាំងអស់ ទន្សាយរៀបរាប់ប្រាប់សីហៈភាសុរកៈ ហើយពោលបញ្ចប់ថា ដោយហេតុដែលខ្ញុំបាទពោលនេះ បានជាខ្ញុំបាទយឺតយូរក្រ បានមកដល់ឲ្យទាន់ពេលវេលាកំណត់ ពេលនេះសូមលោកម្ចាស់ពិចារណាមើលចុះ បើលោកបង្គាប់យ៉ាងណា ខ្ញុំបាទនេះតែធ្វើតាមបង្គាប់ទាំងអស់” ។ សីហៈបានស្ដាប់ពាក្យទន្សាយហើយ ក្រេវក្រោធខ្លាំងក្រៃ និយាយទៅកាន់ទន្សាយថា: “សម្លាញ់ បើដូច្នេះចូរឯងប្រាប់ទីកន្លែងសីហៈពាលកំណាចនោះមកយើងឲ្យឆាប់ អញនឹងទៅបង្ក្រាបវាឲ្យតាលតាញ់តេជដៃឥឡូវនេះ ហើយនឹងឲ្យអភ័យទោសដល់សត្វទាំងឡាយ ដើម្បីនឹងបាននៅសោយរាជ្យក្នុងទីនេះសុខស្រួល ព្រោះថា:-

២២៦ - ជនធ្វើសង្គ្រាមព្រោះហេតុតែ ៣ ប្រការគឺ ផែនដី ១, មិត្រ ១ និងមាសប្រាក់ ១ បើឥតមានហេតុទាំង ៣ នេះ ឬហេតុណាមួយទេ គេមិនធ្វើសង្គ្រាមសោះទេ ។

២២៧ - ទីណា មិនមានផលចំរើនច្រើនទេ ទីនោះមានតែសេចក្ដីវិនាសម្យ៉ាង អ្នកមានប្រាជ្ញា មិនព្រមបង្កើតឲ្យកើតជាសង្គ្រាមក្នុងទីនោះទេ ។

ទន្សាយឆ្លើយតបថា: "បពិត្រលោកម្ចាស់ ! សេចក្ដីពិតដូច្នេះមែន ហើយគឺថា: ព្រោះតែផែនដីគេ នឹងទ្រព្យសម្បត្តិគេនេះជាដើមហេតុ បានជាអ្នកចម្បាំងទាំងឡាយតតាំងច្បាំង ឯសីហ:គាបនេះអាស្រ័យនៅក្នុងរូងភ្នំយ៉ាងមាំ កាលណាបើវាចេញមកពីរូងភ្នំ វាចាប់យើងទាំងឡាយស៊ីជាអាហារ បើចូលទៅនៅក្នុងរូងភ្នំវិញ ឥតមាននរណាមួយអាចហានក្រាបចូលទៅប្រហារវាបានឡើយ ព្រោះថា :–

២២៨ – ព្រះរាជាអង្គណា បើមិនអាចយកឈ្នះសត្រូវដោយដំរីមួយពាន់ឬក៏ដោយសេះមួយសែនបានទេ ព្រះរាជាអង្គនោះត្រូវគិតរកយកត្រឹមតែបន្ទាយមាំតែមួយឲ្យសម្រេចបានហើយ ។

២២៩ – ខ្មាន់ធ្នូតែម្នាក់ ឋិតនៅក្នុងបមប្រាការ អាចធន់ទ្រាំតស៊ូយកឈ្នះសត្រូវដល់ទៅមួយរយនាក់បាន ព្រោះហេតុនោះបានជាអ្នកប្រាជ្ញចេះដឹងនីតិសាស្ត្រតែងសរសើរតែជនណាអាចយកបន្ទាយតែមួយបាន ។

២៣០ - កាលពីបុរាណកាល ព្រះឥន្ទ្រាធិរាជរកយកបន្ទាយមួយបាន ព្រោះធ្វើតាមពាក្យណែនាំព្រះគ្រូ (ព្រះព្រហស្បតិ៍) ផង ព្រោះខ្លាចក្រែងព្រះហិរណ្យកសិបុ:(១)ផង នឹងព្រោះការប៉ុនប្រសប់ព្រះវិស្វកម្ម(២)ផង ។

២៣១ – ព្រោះហេតុនោះ បានជាសក្ករទេវរាជប្រទានពរថា: សូមឲ្យព្រះរាជាទាំងឡាយធ្វើបន្ទាយ ច្រើនដើម្បីឲ្យមានជ័យជាដរាប ដូច្នេះ

---

១ ទៃត្យ:ជាសត្រូវទេវតា ដែលព្រះនារាយណ៍សម្លាប់បាន គឺកាលដែលព្រះនារាយណ៍អវតារជានរសីហ:ទៅសម្លាប់ទៃត្យ:។ ២ កូនព្រះព្រហ្មត្រូវជាវិស្វករនៃទេវតា ។

ត្រូវធ្វើដូចម្ដេចឲ្យមានបន្ទាយ យ៉ាងច្រើន ដល់ទៅកប់ពាន់កប់មុឺន ទើបប្រពៃ ។

២៣២ – ព្រោះថាអង្គណាមិនមានបន្ទាយទេ ព្រោះថាអង្គនោះ ទុកដូចជាទៅក្នុងអាណាចក្រគេស្រេចហើយ ដូចជាពស់ឥតចង្កូមឬដូចដំរីមិនចុះប្រេង ។

ភិក្ខុ ប៉ាង-ខាត់

(មានគ)

ទស្សនាវដ្ដីនេះ ល្អឥតក្ចឹង

ដោយផ្សាយដំណឹង ជា ២ ផ្នែក:

១- ពុទ្ធសាសនា យ៉ាងល្អឯក;

២- ខាងចំណែក អក្សរសាស្ត្រ ។

លោកអ្នកបើបាន អានសិក្សា
មេត្តាកុំភ្លេច ជួយប្រកាស
ប្រាប់គេឲ្យជាវ ច្រើនដេរដាស
ជួយអក្សរសាស្ត្រ, ពុទ្ធសាសនា ។

...... ភ្នំពេញ ......

. រោងពុម្ពព្រះបរមរាជវាំង .

...... ១៩៥២ ......


ដម្លៃជាវប្រចាំឆ្នាំ :

ក្នុងកម្ពុជរដ្ឋ .... ១២០៛,០០

ក្រៅកម្ពុជរដ្ឋ.... ១៥០ ,០០